**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
UNIVERSITÉ ROYALE DE DROIT ET DE SCIENCES ECONOMIQUES
ROYAL UNIVERSITY OF LAW AND ECONOMICS

# របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ឥណទានខ្នាតតូច

កម្មសិក្សាពីថ្ងៃទី ០២ ឧសភា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៧ ឧសភា ឆ្នាំ ២០១៩

ឈ្មោះស្ថាប័ន៖ **ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខ**

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ឈួន វិឆ័យ**
ថ្នាក់បរិញ្ញាបត្រ ធនាគារ និង ហិរញ្ញវត្ថុ
ជំនាន់ទី១៣

សាស្ត្រាចារ្យណែនាំ
លោក **ព្រុំ សុគុណា**
ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេររបាយការណ៍ ២០១៩

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ឈួន វិជ័យ** ជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ថ្នាក់បរិញ្ញាប័ត្រ ផ្នែកធនាគារ និងហិរញ្ញវត្ថុ ឆ្នាំទី៤ ជំនាន់ទី១៣ ក្រុមB4C1 សូមសម្តែងនូវការដឹងគុណ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

ជាបឋម ខ្ញុំសូមថ្លែងនូវសេចក្តីគោរពដឹងគុណ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ **លោកអ្នកមានគុណទាំងពីរ** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ប្រៀនប្រដៅ និងឧបត្ថម្ភគ្រប់បែបយ៉ាង ដល់ខ្ញុំទាំងស្មារតី និងសម្ភារៈតាំងពីកុមារភាពរហូតមក។

សូមថ្លែងអំណរគុណចំពោះ **ឯឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រី ប្រធាន ការិយាល័យ និង អនុប្រធានការិយាល័យ សាស្រ្តាចារ្យ និងបុគ្គលិក**ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន និង ផ្តល់ដំបូន្មានល្អៗ ដល់ខ្ញុំយ៉ាងយកចិត្តទុកដាក់។

សូមថ្លែងអំណរគុណចំពោះ លោកសាស្រ្តាចារ្យ **ព្រុំ សុគុណ** ដែលបានចំណាយពេលដ៏មានតម្លៃរបស់លោកក្នុងការបង្ហាត់បង្ហាញផ្តល់នូវដំបូន្មានល្អៗសម្រាប់ស្ថាបនា និង ជួយកែលម្អនូវរាល់កំហុសឆ្គងដែលកើតមានដើម្បីឲ្យរបាយការណ៍នេះបានល្អប្រសើរ។

សូមថ្លែងអំណរគុណចំពោះ **លោកនាយកប្រតិបត្តិ នាយកមជ្ឈមណ្ឌលហ្វឹកហ្វឺន ធនាគារ អេស៊ីលីដា ការិយាល័យកណ្តាល និងលោកប្រធានផ្នែករដ្ឋបាល លោកប្រធានផ្នែកឥណទាន ព្រមទាំងបុគ្គលិក**ទាំងអស់ដែលបំរើការនៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខ ដែលបានអនុញ្ញាតឲ្យខ្ញុំចុះកម្មសិក្សា ផ្តល់នូវឯកសារ និងខិតខំយកចិត្តទុកដាក់ពន្យល់ណែនាំដើម្បីបង្កភាពងាយស្រួលក្នុងការសរសេររបាយការណ៍កម្មសិក្សានេះ។

សូមថ្លែងអំណរគុណចំពោះ **មិត្តរួមថ្នាក់** និង **មិត្តនិស្សិត** ទាំងអស់ដែលបានជួយគាំទ្រលើកទឹកចិត្ត និងផ្តល់ជាគំនិតល្អៗដល់ខ្ញុំ។

ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរដល់លោកអ្នកដ៏មានគុណទាំងអស់នោះឲ្យទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

វិស័យហិរញ្ញវត្ថុ ជាផ្នែកមួយយ៉ាងសំខាន់ខ្លាំងណាស់ក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសឲ្យរីកចម្រើន។ ពោលគឺយើងអាចនិយាយបានថាបើប្រទេសមួយមានប្រព័ន្ធហិរញ្ញវត្ថុល្អប្រទេសនោះប្រាកដជាមានសេដ្ឋកិច្ចរីកចម្រើនជាក់ជាពុំខាន។ ដូចនេះប្រព័ន្ធហិរញ្ញវត្ថុពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងការធានាអោយមានចេរភាពនៃកំណើនសេដ្ឋកិច្ច។ ចំពោះប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ប្រព័ន្ធហិរញ្ញវត្ថុពិតជាចាំបាច់ណាស់ក្នុងការជំរុញអោយប្រទេសមានការរីកចម្រើន ជាពិសេសផ្នែកសេដ្ឋកិច្ច។

ទន្ទឹមនឹងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាដែលកំពុងរីកចម្រើននោះ គេសង្កេតឃើញមានស្ថាប័នហិរញ្ញវត្ថុជាច្រើនដូចជាធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុដែលបាននឹងកំពុងបម្រើសេវាហិរញ្ញវត្ថុជាច្រើនក្នុងនោះសេវាឥណទានបានដើរតួយ៉ាងសំខាន់ សម្រាប់ផ្តល់ជាមូលធនដល់ពលរដ្ឋក្នុងការបង្កើត និងពង្រីកនូវអាជីវកម្មរបស់ពួកគេ។

ដោយយល់ឃើញដូច្នេះ ខ្ញុំបាទក៏បានសម្រេចចិត្តជ្រើសរើសយកប្រធានបទដែលស្តីអំពី **"ឥណទានអាជីវកម្ម"** របស់ធនាគារអេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខ នៅក្នុងការសិក្សាស្រាវជ្រាវនេះ ដើម្បីទុកជាឯកសារដល់អ្នកសិក្សាទាំងឡាយធ្វើការឈ្វេងយល់បន្ថែម និងមួយចំណែកទៀតសម្រាប់ជាគន្លឹះដល់អ្នកអានដើម្បីយល់ដឹងអោយកាន់តែច្បាស់ អំពីវិស័យឥណទាននៅក្នុងប្រទេសកម្ពុជា។

ខ្ញុំសង្ឃឹមថាការសិក្សាស្រាវជ្រាវនេះ ពិតជាអាចផ្តល់ផលប្រយោជន៍ដល់អ្នកសិក្សា និងអ្នកអានទាំងអស់គ្នា។ បើទោះបីជាខ្ញុំបានខិតខំប្រឹងប្រែងក្នុងការស្រាវជ្រាវយ៉ាងណាក៏ដោយ ខ្ញុំនៅតែគិតថាមានចំនុចខ្វះខាត និងកំខុសឆ្គងជាក់ជាមិនខាន។ ដូចនេះខ្ញុំរង់ចាំទទួលដោយក្តីរីករាយ នូវការផ្តល់យោបល់និងមតិរិះគន់ក្នុងន័យស្ថាបនាពរាល់កង្វះខាត និងកំហុសខុសឆ្គងដែលកើតមានឡើងនៅក្នុងការសិក្សាស្រាវជ្រាវរបស់ខ្ញុំនេះ។

## មាតិកា

## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ............................................................................................................................................១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ.........................................................................................................................................២
៣. គោលបំណងនៃការស្រាវជ្រាវ...........................................................................................................................................២
៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ.....................................................................................................................២
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ.................................................................................................................................................៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ...........................................................................................................................................៣
    ៦.១. ចំពោះក្រុមសិក្សាស្រាវជ្រាវ និងនិស្សិត..........................................................................................................៣
    ៦.២. ចំពោះសាធារណៈជន ........................................................................................................................................៤
    ៦.៣. ចំពោះធនាគារ ..................................................................................................................................................៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.............................................................................................................................................៤


## ជំពូកទី១

## រំលឹកទ្រឹស្តី


១.១. លក្ខណៈទូទៅនៃធនាគារ.............................................................................................................................................៥
១.២. ធនាគារកណ្តាល .........................................................................................................................................................៥
១.៣. ធនាគារពាណិជ្ជ............................................................................................................................................................៦
    ១.៣.១. មុខងារធនាគារពាណិជ្ជ .....................................................................................................................................៧
១.៤. ធនាគារឯកទេស ..........................................................................................................................................................៩
១.៥. ស្ថាប័នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ......................................................................................................................................៩
១.៦. លក្ខណៈទូទៅនៃឥណទាន.............................................................................................................................................៩
    ១.៦.១. និយមន័យឥណទាន .............................................................................................................................................៩
    ១.៦.២. អត្ថប្រយោជន៍របស់ឥណទាន ...........................................................................................................................១០
        ក. សម្រាប់ធនាគារ .................................................................................................................................................១០
        ខ. ចំពោះអតិថិជន .................................................................................................................................................១០
        គ. ចំពោះសង្គម .......................................................................................................................................................១០
        ឃ. តួនាទីឥណទាននៅក្នុងសេដ្ឋកិច្ច........................................................................................................................១០
    ១.៦.៣. ប្រភេទនៃឥណទាន ..........................................................................................................................................១១
    ១.៦.៤. ការចាត់ជាក្រុមនៃឥណទាន..............................................................................................................................១១
        ១.៦.៤.១. ឥណទានឯកជន .......................................................................................................................................១១
        ១.៦.៤.២. ឥណទានសាធារណៈ ...............................................................................................................................១៣
    ១.៦.៥. ដំណើរការនៃការផ្តល់ឥណទាន .........................................................................................................................១៣
        ១.៦.៥.១. ការវិភាគឯកសារឥណទាន ......................................................................................................................១៣
        ១.៦.៥.២. ការវិភាគឥណទាន....................................................................................................................................១៤

១.៦.៥.៣. ប្រភេទនៃវត្ថុបញ្ចាំ ........ ១៧
១.៦.៦. ដំណើរការនៃការគ្រប់គ្រងឥណទាន ........ ១៧
១.៦.៦.១. ការផ្សព្វផ្សាយ........ ១៧
១.៦.៦.២. ការទាក់ទាញទឹកចិត្ត........ ១៨
១.៦.៦.៣. ការជ្រើសរើសពាក្យស្នើសុំ ........ ១៨
១.៦.៦.៤. កាស៊ើបអង្កេតឥណទាន........ ១៨
១.៦.៦.៥ ការសម្រេចឥណទាន........ ១៩
១.៦.៦.៦. ការត្រួតពិនិត្យគណនី........ ១៩
១.៦.៦.៧. ការប្រមូល ........ ១៩
១.៦.៧. ហានិភ័យឥណទាន........ ២០
១.៦.៧.១ ប្រភពនៃហានិភ័យឥណទាន ........ ២០
១.៦.៧.២ វិធីសាស្ត្រទប់ស្កាត់ហានិភ័យឥណទាន........ ២១

## ជំពូកទី២

## ស្ថានភាពទូទៅរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

២.១. ប្រវត្តិរបស់ធនាគារអេស៊ីលីដាភីអិលស៊ី ........ ២៣
២.២. និមិត្តសញ្ញា និងអត្ថន័យ ........ ២៥
២.២.១. និមិត្តសញ្ញា ........ ២៥
២.២.២. អត្ថន័យនៃពាក្យ អេស៊ីលីដា........ ២៥
២.៣. ទស្សនៈ........ ២៥
២.៤. បេសកកម្ម ........ ២៦
២.៥. វប្បធម៌ការងារ........ ២៦
២.៦. គោលដៅ........ ២៦
២.៧. ផលិតផល និងសេវាកម្ម........ ២៦
២.៨. ភាគទុនិក........ ២៧
២.៨.១. ភាគទុនិកក្នុងស្រុក (កាន់កាប់ភាគហ៊ុន ៥១%)........ ២៧
២.៨.២. ភាគទុនិកបរទេស (កាន់កាប់ភាគហ៊ុន ៤៩%)........ ២៧
២.៩. ប្រវត្តិ និងទីតាំងភូមិសាស្ត្ររបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខ ........ ២៨
ក. ប្រវត្តិ........ ២៨
ខ. ទីតាំងភូមិសាស្ត្រ........ ២៨
២.១០. រចនាសម្ព័ន្ធគ្រប់គ្រង និងអង្គការលេខសាខា ........ ២៩

## ជំពូកទី៣

## គោលការណ៍ប្រតិបត្តិការឥណទានខ្នាតតូច

៣.១. សេចក្តីផ្តើម........ ៣០
៣.២. គោលបំណង........ ៣០

៣.៣. ទំហំឥណទាន ..... ៣០
៣.៣.១. ឥណទានជាប្រាក់រៀល ..... ៣០
៣.៣.២. ឥណទានជាប្រាក់បាត ..... ៣១
៣.៣.៣. ឥណទានជាប្រាក់ដុល្លាអាដមេរិក ..... ៣១
៣.៤. សោហ៊ុយឥណទាន និងអត្រាការប្រាក់ ..... ៣១
៣.៤.១. សោហ៊ុយឥណទាន ..... ៣១
៣.៤.២. អត្រាការប្រាក់ ..... ៣២
ក. ឥណទានជាប្រាក់រៀលខ្មែរ ..... ៣២
ខ. ឥណទានជាប្រាក់បាត ..... ៣២
គ. ឥណទានជាប្រាក់ដុល្លារអាមេរិក ..... ៣២
ឃ. ការគណនាការប្រាក់ ..... ៣៤
៣.៥. រយៈពេលខ្ចី ..... ៣៤
៣.៥.១. ឥណទានជាប្រាក់រៀល ..... ៣៤
៣.៥.២. ឥណទានជាប្រាក់បាត ..... ៣៤
៣.៥.៣. ឥណទានជាប្រាក់ដុល្លាអាមេរិក ..... ៣៥
៣.៦. លក្ខខណ្ឌកំណត់ទំហំឥណទាន និងការដាក់ធានា ..... ៣៥
៣.៦.១. ការកំណត់ទំហំឥណទាន ..... ៣៦
៣.៦.២. ការដាក់ទ្រព្យសម្បត្តិធានា ..... ៣៦
៣.៦.៣. ការទទួលយកទ្រព្យដាក់បញ្ចាំផ្សេងទៀត ..... ៣៧
៣.៦.៤. អំពីលទ្ធកម្មនៃទ្រព្យដាក់ធានា ..... ៣៧
៣.៧. ការសងត្រឡប់មកវិញនៃឥណទាន ..... ៣៨
៣.៧.១. របៀបសងប្រាក់ ..... ៣៨
៣.៧.២. ការសងត្រឡប់មកវិញនៃឥណទាន ..... ៣៨
៣.៧.៣. ការធ្វើតារាងកាលវិភាគសងប្រាក់ឡើងវិញ ..... ៣៩
៣.៧.៤. រយៈពេលអនុគ្រោះ ..... ៣៩
៣.៧.៥. ការផ្តល់ឥណទានបន្ថែម ..... ៣៩
៣.៨. ការខកខានសង និងការពិន័យ ..... ៣៩
៣.៨.១. ការខកខានសង ..... ៣៩
៣.៨.១.១. ការខកខានសងកម្រិតស្រាល (Minor Default) ..... ៤០
៣.៨.១.២. ការខកខានសងធ្ងន់ធ្ងរ (Major Default) ..... ៤០
៣.៨.២. ការពិន័យ ..... ៤០
៣.៨.២.១. ពិន័យ ..... ៤០
៣.៨.២.២. ការលុបចោលប្រាក់ពិន័យ ..... ៤០
៣.៩. ការផ្សព្វផ្សាយ ..... ៤១

៣.១០. ទីផ្សារគោលដៅ ..................................................................................................... ៤១
៣.១១. លក្ខណមនុស្សដែលអាចទទួលឥណទាន.......................................................................... ៤២
៣.១២. តម្រូវការ និង សុវត្ថិភាពឥណទាន ............................................................................. ៤៣
ក. តម្រូវការសម្រាប់អ្នកខ្ចី............................................................................................. ៤៣
ខ. តម្រូវការសម្រាប់ធានាសុវត្ថិភាពឥណទាន .................................................................. ៤៣
៣.១៣. ការវាយតម្លៃឥណទាន................................................................................................ ៤៣
ក. ការចុះសិក្សាដល់លំនៅឋាន និងទីកន្លែងប្រកបអាជីវកម្មរបស់អតិថិជន............................. ៤៤
គ. ការសិក្សាអំពីបំណុលហួសកម្រិត (Over-indebtedness) ............................................. ៤៦
៣.១៤. ឥណទានដែលត្រូវទទួលបានការលើកលែង ................................................................ ៤៦
ក- ស្វែងរក Consumer Credit Report ពីការិយាល័យឥណទាន "កម្ពុជា"................................ ៤៦
ខ- លក្ខខណ្ឌក្នុងការផ្ដល់ប្រាក់កម្ចី................................................................................ ៤៦
គ. លក្ខខណបន្ថែម ....................................................................................................... ៤៧
៣.១៥. ភាគីខ្ចីប្រាក់..........................................................................................................៤៧
៣.១៦. ការទទួលខុសត្រូវ និងសិទ្ធិអនុម័តឥណទាន................................................................ ៤៨
ក- នាយក-នាយិកាសាខា "ខ" និងប្រធានភ្នាក់ងារឥណទានសាខា "ក" ធនាគារ មានសិទ្ធិអនុម័តៈ.... ៤៨
ខ- នាយក-នាយិកាសាខា "ក" ធនាគារ អេស៊ីលីដា ភីអិលស៊ី មានសិទ្ធិអនុម័ត ............................ ៤៨
៣.១៧. ការតាមដាន-ត្រួតពិនិត្យ ........................................................................................... ៤៨
៣.១៧.១. ដំណើរការត្រួតពិនិត្យ ........................................................................................ ៤៨
៣.១៧.២. ប្រព័ន្ធត្រួតពីនិត្យឥណទាន .................................................................................. ៤៩
៣.១៧.៣. ការត្រួតពិនិត្យឥណទាន...................................................................................... ៥០
៣.១៧.៣.១. ការត្រួតពិនិត្យប្រចាំថ្ងៃ....................................................................................៥០
៣.១៧.៣.២. ការត្រួតពិនិត្យឥណទាន (Credit Review)............................................................ ៥០
៣.១៨. ការធ្វើចំណាត់ថ្នាក់ឥណទាន ឥណទានរៀបចំឡើងវិញ និងការធ្វើសំវិធានធន .......................... ៥០
ក. ការធ្វើចំណាត់ថ្នាក់ឥណទាន (Loan Classification)......................................................... ៥០
ខ. ឥណទានរៀបចំឡើងវិញ (Restructured Loans) ............................................................ ៥៤
គ. ការធ្វើសំវិធានធន (Provisioning)............................................................................... ៥៥
៣.១៩. ផ្សេងៗ................................................................................................................... ៥៦
ក-អត្រាហានិភ័យឥណទាន ............................................................................................. ៥៦
ខ-អត្រានៃការសងមកវិញ ............................................................................................... ៥៧
គ-បំណុលលុបចេញពីបញ្ជី (Write Off)............................................................................ ៥៧
៣.២០. ដំណើរការនៃការផ្ដល់ឥណទានខ្នាតតូច ......................................................................... ៥៨
១-ការដាក់ពាក្យសុំចុះឈ្មោះខ្ចីប្រាក់ ................................................................................ ៥៨
២-ការចុះទៅពិនិត្យដល់ផ្ទះអតិថិជន និងការវាយតម្លៃឥណទាន ............................................. ៥៩
៣-ការផ្ទៀងផ្ទាត់ព័ត៌មាន ................................................................................................ ៥៩

៤-ការរៀបចំឯកសារឥណទាន ........ ៥៩
៥-ការអនុម័តឥណទាន ........ ៦០
៦-ការរៀបចំកិច្ចសន្យា........ ៦០
៧-ការរៀបចំបញ្ចូលទិន្នន័យ........ ៦០
៨-ការបញ្ចេញឥណទាន........ ៦១
៣.២១. លទ្ធផលនៃការបញ្ចេញឥណទាន........ ៦១
៣.២១.១. សមតុល្យឥណទានអាជីវកម្មខ្នាតតូចរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខ ........ ៦១
៣.២១.២.ចំនួនអតិថិជនប្រើប្រាស់ឥណទានអាជីវកម្មខ្នាតតូច ........ ៦២
៣.២១.៣. អត្រាហានិភ័យឥណទាន ឆ្នាំ២០១៣-២០១៥ ........ ៦៣
៣.២២.ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ ........ ៦៤

**សេចក្ដីសន្និដ្ឋាន និង ការផ្ដល់អនុសាសន៍**

១.សេចក្តីសន្និដ្ឋាន ........ ៦៦
២.ការផ្តល់អនុសាសន៍........ ៦៦

# បញ្ជីតារាង

តារាងទី ២-១ ភាគទុនិករបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨.........២៧
តារាងទី ៣-១ តារាងសង្ខេបសោហ៊ុយឥណទាន និង អត្រាការប្រាក់...........................................៣៣
តារាងទី ៣-២ ចំណាត់ថ្នាក់ឥណទាន...........................................................................................៥២
តារាងទី ៣-៣ សមតុល្យឥណទាន ពីឆ្នាំ ២០១៣-២០១៥.............................................................៦១
តារាងទី ៣-៤ ចំនួនអតិថិជនប្រើប្រាស់ឥណទានអាជីកម្មខ្នាតតូចឆ្នាំ២០១៣-២០១៥.....................៦២
តារាងទី ៣-៥ ហានិភ័យឥណទាន(PAR)........................................................................................៦៣

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ កិច្ចសន្យាខ្ចីប្រាក់
ឧបសម្ព័ន្ធទី២ ៖ ពាក្យស្នើសុំឥណទាន
ឧបសម្ព័ន្ធទី៣ ៖ ទម្រង់វាយតម្លៃទ្រព្យដាក់ធានាប្រភេទជាអចលនទ្រព្យ
ឧបសម្ព័ន្ធទី៤ ៖ ទម្រង់សម្ភាសន៍
ឧបសម្ព័ន្ធទី៥ ៖ គម្រោងជំនួយ
ឧបសម្ព័ន្ធទី៦ ៖ កិច្ចសន្យាព្រមព្រៀងធានា

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍជាច្រើននៅក្នុងសាកលលោក។ ទទឹមនឹងនេះ វិស័យសេដ្ឋកិច្ចកំពុងរីកលូតលាស់គួរអោយកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ដែលក្នុងនោះវិស័យធនាគារនិងហិរញ្ញវត្ថុក៏បានដើរតួនាទីយ៉ាងសំខាន់ដោយបានធ្វើជាចលករមួយជំរុញឲ្យប្រព័ន្ធសេដ្ឋកិច្ចមានការអភិវឌ្ឍ និងមានភាពរឹងមាំ។

ជាមួយនឹងការរីកចម្រើននេះ វាបានឆ្លុះបញ្ចាំងអោយយើងឃើញថាសាធារណៈជនបានបង្កើននូវជំនឿទុកចិត្តរបស់ខ្លួនចំពោះវិស័យធនាគារនៅកម្ពុជានាពេលបច្ចុប្បន្ន តួយ៉ាងធនាគារពាណិជ្ជក៏មានតួនាទីជំរុញអោយមានការផ្តល់ឥណទាន និងសេវាកម្មដទៃទៀតរបស់ខ្លួនទៅដល់សាធារណៈជនសំរាប់ផ្គត់ផ្គង់ហិរញ្ញប្បទានដល់អាជីវកម្មរបស់ពួកគេ ដែលបានជួយសម្រួលដល់ដំណើរការអាជីវកម្ម ឬការវិនិយោគលើផលិតកម្ម សេវាកម្មឲ្យមានភាពរីកចម្រើនឡើងមួយកម្រិតទៀត។ ជាក់ស្តែងណាស់ធនាគារពាណិជ្ជក៏បានបង្កើតនូវផលិតផល និង សេវាកម្មជាច្រើន និងមានប្រតិបត្តិការទូទាំងប្រទេសដែលបានផ្តល់ឱកាលដល់អ្នកដែលមានសមត្ថភាព និងជំនាញតែខ្វះដើមទុនដើម្បីឲ្យពួកគាត់ទាំងនោះចាប់ផ្តើមនិងមានមូលនិធិបន្ថែមលើដំណើរការអាជីវកម្ម។ បន្ថែមពីនេះទៀតធនាគារពាណិជ្ជបានផ្តល់នូវប្រភពហិរញ្ញវត្ថុដ៏ធំមួយ និង បានចូលរួមចំណែកយ៉ាងសកម្មក្នុងការជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនតាមរយៈការផ្តល់ឥណទានដល់សាធារណៈជននៅគ្រប់មជ្ឈដ្ឋានដើម្បីបង្កើត និងពង្រីកអាជីវកម្មគ្រប់ប្រភេទឲ្យមានលទ្ធភាពបង្កើនប្រាក់ចំណូលសកម្មភាពជំនួញរបស់ខ្លួន ជាពិសេសនោះគឺធ្វើឲ្យជីវភាពប្រជាជនក្នុងស្រុកមានភាពធូរស្រាលមួយកំរិតទៀត ធនាគារក៏បានជួយដោះស្រាយពេលមានអាសន្ននៅពេលដែលពួកគេមានតម្រូវការទុនបង្វិល និង ផ្តល់ភាពងាយស្រួលក្នុងការទិញទំនិញដោយមិនបាច់មានសាច់ប្រាក់ក្នុងដៃ។

ដើម្បីឆ្លើយតបទៅនឹងស្ថានភាពរីកចម្រើនដូចបានរៀបរាប់ខាងលើ និង មើលឃើញតម្រូវការបែបនេះទើបធនាគារអេស៊ីលីដាភីអិលស៊ីបានខិតខំបង្កើត និងពង្រីកសាខាការិយាល័យរបស់ខ្លួនគ្រប់២៤ខេត្ត ក្រុង និងបានកំពុងអភិវឌ្ឍសេវាកម្ម និងផលិតផលរបស់ខ្លួនដែលក្នុងនោះរួមមានផលិតផលឥណទានជាច្រើនត្រូវបានប្រើប្រាស់ដោយអតិថិជន។ ម្យ៉ាងទៀតក្នុងការលើកស្ទួយជីវភាពរស់នៅឲ្យកាន់តែប្រសើឡើងនោះភាគទុនិក និងសហគ្រិននានាត្រូវការទុនចាំបាច់ពីធនាគារពាណិជ្ជដើម្បីមានលទ្ធភាពចាប់ផ្តើម និងពង្រីកមុខរបរជំនួញរបស់ពួកគេ។ ដោយយល់ឃើញថាការផ្តល់ឥណទានបាន

ផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ និង ជួយសំរួលដល់អាជីវកម្មរបស់ប្រជាពលរដ្ឋពីគ្រប់មជ្ឈដ្ឋាន ទើបខ្ញុំបានសម្រេចចិត្តជ្រើសរើសសិក្សាស្រាវជ្រាវលើប្រធានបទស្តីអំពី **"ឥណទានអាជីវកម្មខ្នាតតូច"** របស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ធនាគារ អេស៊ីលីដា ភីអិលស៊ី មានផលិតផលឥណទាន និងសេវាកម្មជាច្រើនប្រភេទសម្រាប់បំពេញសេចក្តីត្រូវការរបស់អតិថិជន។ ពិតណាស់ឥណទានបានផ្តល់នូវប្រភពចំណូលយ៉ាងធំចំពោះធនាគារ អតិថិជន និងសេដ្ឋកិច្ចជាតិ ប៉ុន្តែបើគ្រប់គ្រងមិនបានល្អ វាក៏ជះឥទ្ធិពលអាក្រក់ផងដែរ។ ដូច្នេះហើយទើបខ្ញុំបានសម្រេចចិត្តជ្រើសរើសសិក្សាស្រាវជ្រាវលើប្រធានបទខាងលើដើម្បីធ្វើការសិក្សា និងឆ្វេងយល់ថាតើ ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខ មានយុទ្ធសាស្ត្របែបណាក្នុងការគ្រប់គ្រងឥណទានអាជីវកម្មខ្នាតតូច។

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើផ្នែកឥណទានមួយប្រភេទ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខ តែប៉ុណ្ណោះ គឺឥណទានអាជីវកម្មខ្នាតតូច ។ កម្មវត្ថុនៃការសិក្សាស្រាវជ្រាវនេះមានទាក់ទងនឹងចំណុចសំខាន់ៗដូចខាងក្រោម៖

- ឆ្វេងយល់ពិស្ថានភាពទូទៅរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ឆ្វេងយល់ពីផលិតផលឥណទានអាជីវកម្មខ្នាតតូចរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី
- សិក្សាពីនីតិវិធីក្នុងការផ្តល់ឥណទានអាជីវកម្មខ្នាតតូច
- សិក្សាពីគោលការណ៍នៃការផ្តល់ឥណទានអាជីវកម្មខ្នាតតូច
- សិក្សាពីវិធីសាស្ត្រក្នុងការប្រមូលបំណុលរបស់មន្ត្រីឥណទាន
- ឆ្វេងយល់ពីហានិភ័យឥណទាន វិធីសាស្ត្រទប់ស្កាត់ និងដំណោះស្រាយ
- សិក្សាពីការលទ្ធផលនៃការបញ្ចេញឥណទានខ្នាតតូច

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ធនាគារ អេស៊ីលីដា ភីអិលស៊ី មានផលិតផល និងសេវាកម្មច្រើនប្រភេទ សំរាប់បម្រើជូនដល់អតិថិជន និងមានសាខាគ្របដណ្តប់ ២៤ខេត្ត-ក្រុង ប៉ុន្តែក្នុងរបាយការណ៍កម្មសិក្សានេះខ្ញុំសិក្សាស្រាវជ្រាវតែទៅលើផ្នែកឥណទានអាជីវកម្មខ្នាតតូចរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមាន

ចតុមុខ តែប៉ុណ្ណោះដែលកម្មសិក្សាស្រាវជ្រាវនេះមានរយៈពេលកកន្លះខែ គឺចាប់ពីថ្ងៃទី ០២ ខែឧសភា ដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវនេះ ទិន្នន័យដែលខ្ញុំទទួលបាន នឹងយកមកប្រើប្រាស់ក្នុងរបាយការណ៍កម្មសិក្សានេះ គឺធ្វើតាមវិធីសាស្ត្រពីរយ៉ាង រួមមានការប្រើប្រាស់ទិន្នន័យចំបង និង ការប្រើប្រាស់ទិន្នន័យបន្ទាន់បន្សំ។

- ទិន្នន័យចំបង គឺជាទិន្នន័យដែលយើងទទួលបានពីការចុះសម្ភាសន៍ផ្ទាល់ជាមួយលោកប្រធាន និងអនុប្រធាន ព្រមទាំងភ្នាក់ងារឥណទានដទៃទៀតក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខ។
- ទិន្នន័យបន្ទាបើបន្សំ គឺជាទិន្នន័យដែលមានស្រាប់ដូចជាឯកសារមួយចំនួនដែលបានមកពីធនាគារ អេស៊ីលីដា ភីអិលស៊ីទាក់ទងនឹងផ្នែកឥណទាន និងមួយចំនួនទៀតបានមកពីការស្រាវជ្រាវតាមរយៈ អ៊ិនធឺណេត និងបានមកពីសៀវភៅមួយចំនួនដែលមាននៅក្នុងបណ្ណាល័យ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

បន្ទាប់ពីការស្រាវជ្រាវនេះ ត្រូវបានបញ្ចប់រួចរាល់ជាស្ថាពរខ្ញុំសង្ឃឹមថាឯកសារនេះនឹងរួមចំណែកក្នុងការផ្តល់ចំណេះដឹងក្នុងការផ្សាភ្ជាប់រវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែងជាពិសេសចំពោះនិស្សិតដែលចង់ឆ្វេងយល់អំពីឥណទានអាជីវកម្មនេះ។ ជាមួយនឹងការបង្កើតឡើងនៃការស្រាវជ្រាវនេះនឹង ធ្វើអោយបណ្តាអ្នកសិក្សាផ្សេងទៀតមានការចាប់អារម្មណ៍លើប្រធានបទនេះព្រមទាំងអាចទុកជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយដើម្បីយកទៅសិក្សាស្រាវជ្រាវបន្ថែមទៀត។ ផលប្រយោជន៍នៃការសិក្សាស្រាវជ្រាវនេះរួមមានៈ

### ៦.១. ចំពោះក្រុមសិក្សាស្រាវជ្រាវ និងនិស្សិត

- ផ្សារភ្ជាប់ទ្រឹស្តីដែលបានសិក្សាកន្លងមកទៅនឹងការអនុវត្តជាក់ស្តែង
- ទទួលបាននូវបទពិសោធល្អៗ ដែលទាក់ទងនឹងមុខជំនាញដែលយើងកំពុងសិក្សាដើម្បីយកទៅអនុវត្តន៍នៅពេលអនាគត
- បង្កើននូវចំណេះដឹងបន្ថែមលើវិស័យធនាគារ ជាពិសេសផ្នែកឥណទាន
- ទុកជាឯកសារសម្រួលដល់ការសិក្សាដល់និស្សិតជំនាន់ក្រោយ។

### ៦.២. ចំពោះសាធារណៈជន

- បានយល់ដឹងអំពីបែបបទនៃកសារស្នើសុំឥណទានពីធនាគារ អេស៊ីលីដា ភីអិលស៊ី
- ផ្តល់នូវចំណេះដឹងដល់អ្នកអាន និងអ្នកដែលចង់ឆ្វេងយល់អំពីនីតិវិធីនៃការផ្តល់ឥណទានរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ផ្តល់ទំនុកចិត្តដល់អ្នកដែលមានបំណងចង់ប្រើប្រាស់សេវាកម្មនេះ
- ផ្តល់នូវចំណេះដឹងផ្នែកឥណទាន និងចេះប្រើប្រាស់វាឲ្យមានប្រយោជន៍។

### ៦.៣. ចំពោះធនាគារ

- ធ្វើការរៀបចំឯកសារយុទ្ធសាស្ត្រតាមរយៈការផ្តលយោបល់
- ស្គាល់ពីចំនុចខ្លាំង និងចំនុចខ្សោយរបស់ធនាគារ
- ជួយផ្សព្វផ្សាយកិត្តិនាមរបស់ធនាគារ

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីធ្វើឲ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំកាន់តែមានភាពងាយស្រួល ខ្ញុំបានបែងចែកចេញជាបីជំពូកធំៗដូចខាងក្រោម ៖

- **សេចក្តីផ្តើម** : រួមមាន លំនាំបញ្ហា ចំណោទបញ្ហា គោលបំណង ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ
- **ជំពូកទី១** : ការរំលឹកទ្រឹស្តី
- **ជំពូកទី២** : ស្ថានភាពទូទៅរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី (ប្រវត្តិ ទស្សនៈ បេសកម្ម វប្បធម៌ការងារ និងគោលបំណងរបស់ធនាគារ)
- **ជំពូកទី៣** : គោលការណ៍ប្រតិបត្តិការឥណទានអាជីវកម្មខ្នាតតូចរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខ
- **សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍** : ធ្វើការវិភាគ និងសំយោគនូវរាល់ចំនុចសំខាន់ៗដែលបានមកពីការចុះកម្មសិក្សា។

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. លក្ខណៈទូទៅនៃធនាគារ

ធនាគារ គឺជាស្ថាប័នហិរញ្ញវត្ថុមួយក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុទាំងអស់ដែលមាននីតិសម្បទាពិសេសក្នុងការជ្រើសរើសយកប្រតិបត្តិការមកប្រតិបត្តិជាប្រក្រតី ម្យ៉ាងទៀតធនាគារគឺជាស្ថាប័នហិរញ្ញវត្ថុដែលជួយអោយមានចរាចរសាច់ប្រាក់ និងធ្វើឲ្យមានកំនើនសេដ្ឋកិច្ច។[1] សកម្មភាពសំខាន់ៗរបស់ធនាគាររួមមាន៖

- ផ្តល់សេវាឥណទានជាច្រើនប្រភេទដល់សាធារណៈជន
- ទទួលប្រាក់បញ្ញើពីសាធារណៈជន
- សេវាផ្ទេរប្រាក់
- ផ្តល់សេវាសម្រាប់ការទូទាត់
- សេវាផ្តល់ប្រឹក្សាផ្នែកហិរញ្ញវត្ថុ
- សេវាប្តូរប្រាក់
- ផ្តល់សេវាដើងសារជំនួញមូលបត្រ។

### ១.១.១. ប្រភពទុនរបស់ធនាគារ

ប្រភពទុនរបស់ធនាគារបានមកពី៖

- ប្រភពទុនបានមកពីប្រាក់បញ្ញើ
- ប្រភពទុនបានមកពីកម្ចីពីធនាគាផ្សេងទៀត
- បានពីការចូលរួមហ៊ុនរបស់ភាគទុនិក
- បានពីការបោះផ្សាយប័ណ្ណភាគហ៊ុន។

## ១.២. ធនាគារកណ្តាល

ធនាគារកណ្តាល ធនាគារបម្រុង ឬអាជ្ញាធររូបិយវត្ថុ គឺជាស្ថាប័នសាធារណៈដែលតែងតែបោះពុម្ពរូបិយវត្ថុ គ្រប់គ្រងលើការផ្គត់ផ្គង់រូបិយវត្ថុ និងគ្រប់គ្រងអត្រាការប្រាក់។ ធនាគារកណ្តាលក៏តែងតែ

[1] ធនាគារជាតិនៃកម្ពុជា,(១៩៩៩),ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ,មាត្រា១

គ្រប់គ្រងលើប្រព័ន្ធធនាគារពាណិជ្ជកម្មនៅក្នុងស្រុកផងដែរ។ ធនាគារកណ្ដាលខុសពីធនាគារពាណិជ្ជត្រង់ដែលវាអាចមានសិទ្ធិផ្ដាច់មុខលើការបោះពុម្ពរូបិយវត្ថុជាតិ។

តួនាទីចំបងរបស់ធនាគារជាតិគឺផ្គត់ផ្គង់រូបិយវត្ថុជាតិ គ្រប់គ្រងអត្រាការប្រាក់ និងជាឥណទាយិកចុងក្រោយនៃវិស័យធនាគារក្នុងពេលមានវិបត្តិហិរញ្ញវត្ថុ។ វាក៏មានអំណាចគ្រប់គ្រងផងដែរ ដើម្បីធ្វើឲ្យប្រាកដថាធនាគារទាំងឡាយ និងស្ថាប័នហិរញ្ញវត្ថុដទៃទៀតមិនមានការធ្វេសប្រហែស និងមិនកេងបន្លំ។

ប្រទេសអភិវឌ្ឍន៍ភាគច្រើនមានធនាគារជាតិ "ឯករាជ្យ" ដែលដំណើរការក្រោមច្បាប់ដោយឡែកមួយដើម្បីជៀសវាងការជ្រៀតជ្រែកបែបនយោបាយ។ ឧទាហរណ៍ដូចជា ធនាគារកណ្ដាលសហគមន៍អឺរ៉ុប និងប្រព័ន្ធបម្រុងសត្តិភូមិរបស់សហរដ្ឋអាមេរិក។[2]

### ១.២.១. មុខងាររបស់ធនាគារកណ្ដាលរួមមាន:

- ប្រតិបត្តិគោលនយោបាយហិរញ្ញវត្ថុ
- កំណត់អត្រាការប្រាក់ ដើម្បីគ្រប់គ្រងអតិផរណា និងអត្រាប្ដូរប្រាក់ ដើម្បីធ្វើឲ្យប្រាកដថាអត្រាប្ដូរ ប្រាក់នេះមានប្រសិទ្ធភាពតាមរយៈយន្តការគោលនយោបាយផ្សេងៗ
- គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុទូទាំងប្រទេស
- ឥណទាយិកចុងក្រោយ
- គ្រប់គ្រងការប្ដូរប្រាក់អន្តរជាតិរបស់ប្រទេស ការស្តុកទុកមាស និងការចុះបញ្ជីប័ណ្ណភាគហ៊ុនរបស់រដ្ឋាភិបាល
- ដាក់បញ្ញត្តិ និងគ្រប់គ្រងលើឧស្សាហកម្មធនាគារ។

## ១.៣. ធនាគារពាណិជ្ជ

ធនាគារពាណិជ្ជមាននិយមន័យច្រើន យើងលើកយកតែនិយមន័យមួយចំនួនដូចខាងក្រោម៖

**និយមន័យទី១** ធនាគារពាណិជ្ជ គឺជាស្ថាប័នហិរញ្ញវត្ថុដែលផ្គត់ផ្គង់នូវសេវាហិរញ្ញវត្ថុ ដូចជាការផ្ដល់ឥណទាន ការទទួលប្រាក់បញ្ញើ បម្រើសេវាទូទាត់ និងសេវាកម្មជាច្រើនទៀត។

[2] https://km.wikipedia.org/wiki/ធនាគារកណ្ដាល (ចូលមើលថ្ងៃទី ០១ ឧសភា ២០១៩)

**និយមន័យទី២** ធនាគារពាណិជ្ជ គឺជានីតិបុគ្គលដែលមាននីតិសម្បទាពិសេសក្នុងការអនុវត្តជាប្រក្រតី នូវប្រតិបត្តិការទាំងបីរបស់ធនាគារ គឺការផ្តល់ឥណទានគ្រប់ប្រភេទចំពោះសាធារណជន ការទទួលប្រាក់បញ្ញើ និងការប្រ-ព្រឹត្តិកម្ម និងដាក់ឲ្យអតិថិជនប្រើប្រាស់មធ្យោបាយទូទាត់។

**និយមន័យទី៣** ធនាគារពាណិជ្ជ គឺជាស្ថាប័នដែលទទួលប្រាក់បញ្ញើ ផ្តល់កម្ចីអាជីវកម្ម និងផ្តល់សេវាកម្មទាក់ទងផ្សេងៗទៀត។ ជានិច្ចកាល ធនាគារពាណិជ្ជ អនុញ្ញាតឲ្យផ្តល់គណនីប្រាក់បញ្ញើជាច្រើនប្រភេទ ដូចជា គណនីមូល ប្បទានបត្រ គណនីសន្សំ និងគណនីមានកាលកំណត់។ នៅពេលដែលធនាគារពាណិជ្ជផ្តល់សេវាដល់បុគ្គលទាំងឡាយ ជាបឋម ពួកគេទាក់ទងជាមួយការទទួលប្រាក់បញ្ញើ និងការផ្តល់កម្ចី ដល់ក្រុមហ៊ុនអាជីវកម្ម។

**និយមន័យទី៤** ធនាគារពាណិជ្ជ គឺជាប្រភេទមួយនៃអន្តរការីហិរញ្ញវត្ថុ និងប្រភេទមួយរបស់ធនាគារ ដែលផ្តល់គណនីមូលប្បទានបត្រ គណនីសន្សំ គណនីទីផ្សាររូបិយវត្ថុ និងទទួលគណនីមានកាលកំណត់ដល់សាធារណៈជន។

ចំពោះប្រទេសកម្ពុជាយើង និយមន័យធនាគារពាណិជ្ជ ត្រូវបានសំដែងឡើងនៅក្នុងច្បាប់ស្តីពីគ្រឹះស្ថានហិរញ្ញវត្ថុ ដែលលើកឡើងដោយធនាគារជាតិនៃកម្ពុជា និងអនុម័តដោយរដ្ឋសភាជាតិកម្ពុជា នៅឆ្នាំ ១៩៩៩ គឺ "ធនាគារពាណិជ្ជ គឺជានីតិបុគ្គលដែលមាននីតិសប្បទា ពិសេសក្នុងការអនុវត្តន៍ជាប្រក្រតីនូវប្រតិបត្តិការទាំងបី របស់ធនាគារ គឺការផ្តល់គ្រប់ប្រភេទចំពោះសាធារណៈជន ការទទួលប្រាក់បញ្ញើរ និងការប្រព្រឹត្តកម្ម និងដាក់ឲ្យអតិថិជនប្រើប្រាស់មធ្យោបាយទូទាត់"។

### ១.៣.១. មុខងារធនាគារពាណិជ្ជ

មានមុខងារមួយចំនួន ដែលចាត់ទុកថាជាផ្នែកដ៏សំខាន់របស់ធនាគារនោះគឺ៖[3]

- **មុខងារអន្តរការីហិរញ្ញវត្ថុ** : តាមរយៈប្រតិបត្តិការរបស់ធនាគារបានផ្ទេរលុយសន្សំរបស់អតិថិជនទៅជាលុយសម្រាប់អ្នកវិនិយោគ។ អ្នកដែលមានការចំណាយច្រើន និងអ្នកវិនិយោគលើមូលធនផ្ទាល់ខ្លួន ដូចនេះគេត្រូវការមូលធនបន្ថែម រីឯអ្នកដែលមានមូលធនច្រើនជាងការចំណាយ រឺចំណូលច្រើនពួកគេត្រូវការសន្សំលុយទុក ដូច្នេះហើយគេយកលុយរបស់ពួកគេទៅផ្ញើរក្នុងធនាគារដើម្បីទទួលបានការប្រាក់។ ធនាគារបានដើរតួយ៉ាងសំខាន់ជាអន្តរការីសម្រាប់ទទួលប្រាក់បញ្ញើរពីសាធារណៈជន ហើយប្រែលុយទាំងអស់ទៅជាឥណទាន

[3] សួនចំរើន,(២០១៣),រូបិយវត្ថុ និងធនាគារ ទំព័រ៨-៩

ដែលជាមូលធនដ៏ធំសម្រាប់អ្នកវិនិយោគ ដែលអាចអោយពួកគេពង្រីកអាជីវកម្មរបស់គេកាន់តែធំឡើងៗ។

- **មុខងារមធ្យោបាយទូទាត់:** លុយ និងមាស មានមុខងារសំខាន់បំផុតគឺធ្វើជាមធ្យោបាយទូទាត់។ បណ្តាធនាគារបានបង្កើតឡើងមិនអាចបង្កើតនូវលុយលោហៈធាតុ ដូចនេះបណ្តាធនាគារបានបង្កើតមធ្យោបាយទូទាត់ដោយបោះផ្សាយ នូវក្រដាសបំណុល។ ក្រដាសបំណុលនេះបានក្លាយទៅជាឧបករណ៍ទូទាត់ ដែលត្រូវបានអតិថិជនទទួលស្គាល់។ ដំបូងធនាគារបានបង្កើតក្រដាសបំណុលនេះឡើងដើម្បីជំនួសអោយរូបិយវត្ថុលោហៈធាតុដែលកំពុងចរាចរ ប៉ុន្តែក្រោយមក ក្រដាសបំណុលនេះក៏ត្រូវប្រើប្រាស់ជំនួសឲ្យរូបិយវត្ថុលោហៈធាតុទាំងស្រុង ដូចនេះក្រដាសបំណុលនេះបានក្លាយជាក្រដាសប្រាក់។ ចំពោះការបោះផ្សាយ ក្រដាសប្រាក់ គឺទទួលបានផលចំណេញច្រើនណាស់។ ដោយសារតម្រូវការក្រដាសប្រាក់តំណាងដោយប្រទេសមួយ ដូចនេះត្រូវផ្ទេរតួនាទីទៅអោយធនាគារកណ្តាលវិញ។ ធនាគារក៏ក្លាយអន្តរការីទូទាត់ធំជាងគេនៅបណ្តាប្រទេសជាច្រើន។ ធនាគារទូទាត់ជំនួសអតិថិជនរបស់ខ្លួននូវតម្លៃទំនិញឬសេវា។ ដើម្បីឲ្យការទូទាត់បានឆាប់រហ័ស និងងាយស្រួល ធនាគារបានផ្តល់នូវឧបករណ៍ទូទាត់ជាច្រើនប្រភេទដល់អតិថិជនដូចជា Cheque, Letter of credit, Credit card, Debit card, E-banking។
- **មុខងារផ្ទេរប្រាក់ និង ប្តូរប្រាក់:** ធនាគារបានធ្វើប្រតិបត្តិការ ផ្ទេរប្រាក់ជំនួសអោយអតិថិជនរបស់ខ្លួនទាំងក្នុង និងក្រៅប្រទេស។ ធនាគារក៏បានធ្វើប្រតិបត្តិការប្តូរប្រាក់ជំនួសអោយអតិថិជនរបស់ខ្លួនពីរូបិយប័ណ្ណប្រទេសមួយ ទៅជារូបិយប័ណ្ណប្រទេសមួយផ្សេងទៀត។
- **មុខងារជាអ្នកធានា:** ធនាគារជាអ្នកធានាដល់ភាគីទី៣ណាមួយអំពីលទ្ធភាពទូទាត់បំណុលរបស់អតិថិជនរបស់ខ្លួនដោយធនាគារអាចចេញលិខិតឥណទានជាដើម។ ធនាគារអាចធានាថាអតិថិជនរបស់ខ្លួននឹងមានលទ្ធភាពទូទាត់សងបំណុលដល់ភាគីទី៣។ ក្នុងករណីដែលអតិថិជនគ្មានលទ្ធភាពសងធនាគារនឹងចេញមុខទទួលខុសត្រូវលើបំណុលនោះ។
- **មុខងារជាភ្នាក់ងារ:** ធនាគារដើរតួនាទីជំនួសឲ្យអតិថិជនរបស់ខ្លួនក្នុងការគ្រប់គ្រង និងថែរក្សាទ្រព្យសម្បត្តិ ហើយធនាគារក៏ជាភ្នាក់ងារមួយដែលបម្រើសេវាកម្មជូនអតិថិជនក្នុងការទិញនិងលក់ទៅវិញនូវឧបករណ៍ហិរញ្ញវត្ថុផងដែរ។

- **មុខងារជាអ្នកអនុវត្តគោលនយោបាយ:** ក្រៅពីមុខងារខាងលើធនាគារពាណិជ្ជក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលគោលនយោបាយទាំងអស់នោះត្រូវបានចេញដោយធនាគារកណ្តាល ឬរតនាគារជាតិក្នុងគោលបំណងគ្រប់គ្រងកំណើនសេដ្ឋកិច្ចជាតិ ក៏ដូចជាសម្រេចឲ្យបាននូវគោលដៅសង្គមនានា។

## ១.៤. ធនាគារឯកទេស

ធនាគារឯកទេស ជានីវិបុគ្គលដែលមាននីតិសម្បទាក្នុងការជ្រើសរើសយកនូវប្រតិបត្តិការតែមួយប៉ុណ្ណោះដូចជាទទួលប្រាក់បញ្ញើ និងការផ្តល់ឥណទានជាដើម។

## ១.៥. ស្ថាប័នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ស្ថាប័នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាស្ថាប័នហិរញ្ញវត្ថុមានលក្ខណៈ ជានីតិបុគ្គលដែលមាននីតិសម្បទាពិសេសក្នុងការជ្រើសរើសប្រតិបត្តិការមួយចំនួនជាមុខរបរជាប្រក្រតី។ ស្ថាប័នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺទទួលបាននូវមូលនិធិរដ្ឋាភិបាល ឬបណ្តាអង្គការក្រៅស្រុក ដើម្បីផ្តល់ឥណទានដល់គ្រួសារ និងមុខជំនួញតូចតាច។ ស្ថាប័នមិនអនុញ្ញាតឲ្យផ្តល់ឥណទានភតិសន្យា ធ្វើប្រតិបត្តិការលើឧបករណ៍និស្សន្ទ និងសេដ្ឋកិច្ចពាណិជ្ជកម្មដទៃទៀតមានការកំណត់ទៅលើលោហៈធាតុមានតម្លៃ ទំនិញធ្យូងថ្មមានតម្លៃវត្ថុធាតុដើម។

## ១.៦. លក្ខណៈទូទៅនៃឥណទាន

### ១.៦.១. និយមន័យឥណទាន

ឥណទាន គឺជាការផ្តល់កម្ចីដល់សាធារណៈជនក្នុងរយៈពេលជាក់លាក់ណាមួយ និងសន្យាសងត្រលប់មកវិញទាំងប្រាក់ដើម និងការប្រាក់តាមកិច្ចសន្យាដែលបានកំណត់។[4]

លក្ខណៈពិសេសបីយ៉ាងនៃឥណទានមានដូចជា៖

- ការផ្ទេរកម្មសិទ្ធិប្រើប្រាស់ ពីម្ចាស់កម្មសិទ្ធិស្របច្បាប់ទៅអោយជនម្នាក់ទៀត
- ការផ្ទេរសិទ្ធិប្រើប្រាស់នេះ ជាការផ្ទេរកម្មសិទ្ធិបណ្តោះអាសន្នតែប៉ុណ្ណោះ
- ដល់ពេលកំណត់ អ្នកខ្ចីត្រូវធ្វើការទូទាត់នូវចំនួនដែលបានខ្ចីជាមួយនឹងថ្លៃឈ្នួលនៃកម្ចីនោះ។

[4] ស្ងួនចំរើន,(២០១០),ស្ថាប័ន និងទីផ្សារហិរញ្ញវត្ថុ ទំព័រទី៦៦

### ១.៦.២. អត្ថប្រយោជន៍របស់ឥណទាន

ឥណទាន គឺមានអត្ថប្រយោជន៍ច្រើនសម្រាប់ធនាគារផ្ទាល់ អតិថិជនអ្នកប្រើប្រាស់ និងសង្គមផងដែរ។ ជាពិសេសឥណទានបានផ្តល់ឱកាសអោយអ្នកគ្មានដើមទុនបង្កើតអាជីវកម្ម និងអ្នកដែលមានបំណងចង់ពង្រីករបររបស់ពួកគេ។[5]

**ក. សម្រាប់ធនាគារ**

- ទទួលបាននូវការប្រាក់ និងធ្វើអោយ
- សាច់ប្រាក់នៅក្នុងធនាគារអាចចរាចរបាន។

**ខ. ចំពោះអតិថិជន**

- មានមូលធនគ្រប់គ្រាន់ក្នុងការពង្រីកអាជីវកម្ម
- ធ្វើអោយចំណូលកើនឡើង នាំអោយជីវភាពកាន់តែប្រសើឡើង។

**គ. ចំពោះសង្គម**

- ចរាចរលុយដំណើរការលើទីផ្សារ
- ផ្ទេរលុយពីអ្នកមានធនធាននៅទំនេរទៅអោយអ្នកខ្វះដើមទុន
- ធ្វើអោយវិនិយោគកើនឡើង
- សំបូរការងារធ្វើ
- និកម្មភាពថយចុះ
- ធ្វើអោយសេដ្ឋកិច្ចកើនឡើង។

**ឃ. តួនាទីឥណទាននៅក្នុងសេដ្ឋកិច្ច**

- ជួយជំរុញឲ្យសេដ្ឋកិច្ចប្រទេសមានភាពរីកចម្រើន
- ធ្វើឲ្យមានភាពងាយស្រួលក្នុងការដោះដូរទំនិញ និងសេវាកម្ម
- ជាដើមទុនសម្រាប់ពង្រីកអាជីវកម្ម និងពង្រីកទីផ្សារទំនិញ
- ឥណទានបានបង្កើតឲ្យមានប្រាក់បញ្ញើ
- ឥណទានជាប្រភពនៃការលើកទឹកចិត្តឲ្យបុគ្គលអាចចូលរួមទីផ្សារប្រកួតប្រជែង

[5] សួនចំរើន,(២០១៣),រូបិយវត្ថុ និង ធនាគារ ទំព័រ១១-១២

- ធ្វើឲ្យអាជីវកម្ម កសិកម្ម សិប្បកម្ម សហគ្រាស អាចបង្កើតនូវទ្រព្យសម្បត្តិជាសាច់ប្រាក់ ឬទ្រព្យវិនិយោគ ដូចជា អាគារ ដី រថយន្តជាដើម។
- ឥណទានបង្កើតឲ្យមានមានជីវភាពធូរធារតាមរយៈការងារថ្មី និងចំណូល
- ឥណទានធ្វើឲ្យក្រុមហ៊ុន សហគ្រាស មានការបង្កើតកាន់តែច្រើនឡើងដែលជាហេតុនាំឲ្យសម្បូរការងារធ្វើច្រើន
- ឥណទានបានកាត់បន្ថយអតិផរណា។

### ១.៦.៣. ប្រភេទនៃឥណទាន

ដោយសារការធ្វើឥណទានតែងតែមានសមាសភាពពីរចូលរួម គឺម្ចាស់បំណុល និងកូនបំណុល ដូច្នេះហើយយងអាចកំណត់នូវប្រភេទនៃឥណទានបានច្រើនប្រភេទដូចខាងក្រោម:

- ឥណទានជនបទ
- ឥណទានអន្តរធនាគារ
- ឥណទានពាណិជ្ជកម្ម
- ឥណទានអាជីវកម្ម
- ឥណទានកសិកម្ម
- ឥណទានគេហដ្ឋាន
- ឥណទានរថយន្ត
- ឥណទានវិបារូបរ៍
- ឥណទានបង្វិល
- ឥណទានភតិសន្យា
- ឥណទានរដ្ឋ
- ឥណទានអន្តរជាតិ។

### ១.៦.៤. ការចាត់ជាក្រុមនៃឥណទាន

#### ១.៦.៤.១. ឥណទានឯកជន

ឥណទានឯកជន គឺជាឥណទានដែលត្រូវបានប្រើប្រាស់ដោយបុគ្គល និងអ្នកជំនួញជាច្រើនក្នុងគោលបំណងដោះស្រាយរាល់ការចំណាយរបស់វិស័យឯកជននៅក្នុងសេដ្ឋកិច្ច។

**ក. ឥណទានសម្រាប់អ្នកប្រើប្រាស់** ( Consumer Credit )

ឥណទានសំរាប់អ្នកប្រើប្រាស់រួមមាន ឥណទានរាយ ឥណទានរំលស់រាយ ឥណទានរាយបង្វិល ឥណទានសេវា ឥណទានសាច់ប្រាក់ និងឥណទានអចលនវត្ថុ។

- ឥណទានរាយ (Retail Credit): គឺជាផ្នែកមួយនៃឥណទានដែលប្រើប្រាស់ដើម្បីទិញផលិតផលសម្រេចអាចជាទំនិញ ឬសេវាកម្មដោយផ្ទាល់ពីអ្នកលក់។[6]
- ឥណទានរំលស់រាយ(Retail Installment Credit): គឺជាផែនការឥណទានឬកម្មវិធីឥណទានដែលអនុញ្ញាតឲ្យអ្នកទិញទូទាត់នៅពេលអនាគតដោយសងជាលំដាប់លំដោយ(សេរី) ថេរហើយទៀងទាត់(regular payment)។ ឥណទានរាយរំលស់មានលក្ខណៈសម្គាល់ដូចខាងក្រោម៖[7]
  - ការសងទៀងទាត់ជាទូទៅសងប្រចាំខែ ឬទៅតាមគោលការណ៍
  - សំណងថេររួមមានទាំងប្រាក់ដើម ការប្រាក់ និងបន្ទុកហិរញ្ញវត្ថុផ្សេងទៀត
  - ត្រូវមានកិច្ចសន្យា
  - កិច្ចសន្យាត្រូវបានបញ្ចប់នៅពេលសងលើកចុងក្រោយរួចរាល់។
- ឥណទានរាយបង្វិល(Retail Revolving Credit): ឥណទានរាយបង្វិលអនុញ្ញាតឲ្យអ្នកទិញទទួលបានជម្រើសពីរ (១)សងបំណុលសរុបនៅចុងខែនីមួយៗ (២)សងបំណុលត្រឹមតែកម្រិតអប្បបរមាហើយចំណែកនៅពេលអនាគត។
- ឥណទានសេវា(Service Credit): ជាឥណទានដែលកើតឡើងពីអ្នកផ្គត់ផ្គង់សេវាយល់ព្រមផ្តល់សេវាកម្មហើយរងចាំសំណងពីតិថិជន។
- ឥណទានសាច់ប្រាក់(Cash Credit): ជាឥណទានដែលអ្នកខ្ចីទទួលបានសាច់ប្រាក់យកទៅប្រើប្រាស់ដោយតម្រូវឲ្យសងត្រលប់មកវិញទៅតាមកិច្ចសន្យាខ្ចីទាំងប្រាក់ដើម ការប្រាក់ និងបន្ទុកហិរញ្ញវត្ថុផ្សេងទៀត។

---

[6] Robert Cole & Lon Mishler 1998,´Credit Management´ Elventh Edition Page 39

[7] Robert Cole & Lon Mishler 1998,´Credit Management´ Elventh Edition Page 42

- ឥណទានអចលនទ្រព្យ(Real Estate Credit): ជាកម្ចីសម្រាប់ប្រើប្រាស់ក្នុងការទិញអចលនទ្រព្យ ឬបំណាងផ្សេងៗដែលក្នុងនោះលុយដែលផ្តល់ឲ្យអ្នកខ្ចី ត្រូវធានាដោយអចលនទ្រព្យដាក់បញ្ចាំសម្រាប់កម្ចីនោះ។

**ខ. ឥណទានសម្រាប់អាជីវកម្ម** ( Business Credit )

ឥណទានសម្រាប់អាជីវកម្មត្រូវបានគេបែងចែកជាពីរប្រភេទគឺ ឥណទានទំនិញ និង ឥណទានមូលធនហិរញ្ញវត្ថុសម្រាប់អាជីវកម្ម។

- ឥណទានទំនិញ (Merchandise Credit): ជាឥណទានសម្រាប់ទិញទំនិញ វត្ថុធាតុដើម និងសារពើភ័ណ្ឌសម្រាប់លក់បន្ត។ ជាទូទៅអតិថិជនទទួលបានទំនិញមុនហើយយល់ព្រមទូទាត់តាមលក្ខខ័ណ្ឌលក់របស់អ្នកលក់ និងអនុញ្ញាតិឲ្យអតិថិជនទូទាត់តាមពេលវេលាកំណត់។
- ឥណទានមូលធនហិរញ្ញវត្ថុសម្រាប់អាជីវកម្ម(Financial Capital for Operations): ជាឥណទានសម្រាប់ការចាប់ផ្តើមថែរក្សា និងប្រតិបត្តិការអាជីវកម្ម។[8]

### ១.៦.៤.២. ឥណទានសាធារណៈ

ឥណទានសាធារណៈ: ជាប្រភេទកម្ចីកំរិតរដ្ឋាភិបាលសម្រាប់ធ្វើហិរញ្ញប្បទាន(ខ្ចីប្រាក់) ទិញទំនិញសេវាកម្ម ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ កម្មវិធីសិក្សា និងកម្មវិធីសុខមាលភាពប្រជាពលរដ្ឋជាដើម។

## ១.៦.៥. ដំណើរការនៃការផ្តល់ឥណទាន

### ១.៦.៥.១. ការវិភាគឯកសារឥណទាន

ដំណាក់កាលទី១: អតិថិជនត្រូវមកធនគារដើម្បីសួរព័ត៌មានអំពីការសុំឥណទានក្នុងការស្វែរកព័ត៌មាននេះតម្រូវឲ្យអតិថិជនត្រូវយកពាក្យខ្ចីឥណទានពីធនាគារដើម្បីបំពេញ (Application Form) និងភ្ជាប់ជាមួយឯកសារដែលមានដូចជា អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារជាដើម។ បន្ទាប់ពីនោះដែរសំណុំបែបបទត្រូវបានផ្ញើរទៅភ្នាក់ងារឥណទានដើម្បីធ្វើការណាត់ជួបនៅពេល និងទីកន្លែងណាមួយ (កន្លែងជួបក៏អាចធ្វើឡើងនៅគេហដ្ឋានរបស់អតិថិជន)។

[8] Robert Cole & Lon Mishler 1998,´Credit Management´ Eleventh Edition Page 263-266

ដំណាក់កាលទី២: អតិថិជនត្រូវធ្វើការសម្ភាសន៍ផ្ទាល់ជាមួយមន្ត្រីឥណទានដោយផ្តល់ឱកាសឲ្យអតិថិជនរៀបរាប់ពីប្រវត្តិខ្លះៗពីប្រភពវត្ថុបញ្ចាំ ជាពិសេសគោលបំណងនៃការខ្ចី។ ការធ្វើកិច្ចសម្ភាសន៍នេះក៏មានសារៈសំខាន់ដែរព្រោះវាផ្តល់ភាពងាយស្រួលដល់មន្ត្រីឥណទានក្នុងការវាយតម្លៃអត្តចរិកស្មោះត្រង់ និងគោលបំណងនៃការខ្ចី។ បើកំឡុងពេលសម្ភាសន៍អតិថិជនបានបញ្ចេញកាយវិការបង្ហាញពីភាពមិនស្មោះត្រង់ គោលបំណងនៃការខ្ចីមិនច្បាស់លាស់ វាជាចំនុចអវិជ្ជមានក្នុងដំណាក់កាលសម្រេចចិត្តផ្តល់ឥណទាន គឺត្រូវបដិសេធសំណើរឥណទាន។

ដំណាក់កាលទី៣: មន្ត្រីឥណទានត្រូវធ្វើការចុះជួបអតិថិជនម្តងទៀត នៅគេហដ្ឋាន ទីតាំងអាជីវកម្ម ទីតាំងវត្ថុបញ្ចាំដើម្បីធ្វើការត្រួតពិនិត្យពីទ្រព្យសម្បត្តិដែលអតិថិជនមាន។ លើសពីនេះទៅទៀតមន្ត្រីឥណទានអាចស៊ើបសួរអំពីប្រវត្តិនៃការខ្ចីរបស់អតិថិជនតាមរយៈអតីតម្ចាស់ឥណទានរបស់អតិថិជន ថាតើការបង់ប្រាក់សងត្រលប់មកវិញ ទាន់ពេលវេលា គ្រប់ចំនួន និងបានល្អឬទេ?

ដំណាក់កាលទី៤: ដំណាក់កាលខាងលើត្រូវបានអនុវត្តន៍ល្អហើយមន្ត្រីឥណទានត្រូវស្នើសុំឯកសារសំខាន់ៗមួយចំនួនទៀតពីអតិថិជនដើម្បីធ្វើវត្ថុតាងសម្រាប់វាយតម្លៃបន្ថែមលើសំណើរសុំខ្ចី។

ដំណាក់កាលទី៥: មន្ត្រីឥណទានធ្វើការវាយតម្លៃលើអតិថិជន ដោយប្រើទ្រឹស្តី 6Cs ជាដើម។

ដំណាក់កាលទី៦: ជាដំណាក់កាលដែលមន្ត្រីឥណទានធ្វើការប៉ាន់ប្រមាណលើទ្រព្យដាក់បញ្ចាំ។ ជាទូទៅវត្ថុបញ្ចាំនោះត្រូវមានតម្លៃចាប់ពី២០០%នៃតម្លៃឥណទាន។

ដំណាក់កាលទី៧: មន្ត្រីឥណទានត្រូវធ្វើការចរចាជាមួយអតិថិជនអំពីការប្រាក់ ចំនួនទឹកប្រាក់ដែលសម្រេចឲ្យ និងរបៀបនៃការសង។ បើអតិថិជនយល់ព្រមហើយ មន្ត្រីឥណទានត្រូវឲ្យអតិថិជនចុះកិច្ចសន្យា។ ដំណាក់កាលចុងក្រោយធនាគារត្រូវបើកគណនេយ្យឲ្យអតិថិជនមួយដើម្បីដកសាច់ប្រាក់ដែលគាត់បានខ្ចីតាមកិច្ចសន្យាដែលបានព្រមព្រៀងខ្ចី។

### ១.៦.៥.២. ការវិភាគឥណទាន

នាយកដ្ឋានឥណទានត្រូវយល់ដឹងចំនុចសំខាន់ៗ៣ដែលពាក់ព័ន្ធនឹងពាក្យសុំខ្ចីប្រាក់នីមួយៗ។

ក. តើអ្នកសុំខ្ចីគួរឲ្យទុកចិត្តដែរឬទេ? តើត្រូវដឹងតាមវិធីណា?

ខ. តើការខ្ចីឥណទានត្រូវបានតាក់តែង និងចងក្រងឯកសារឲ្យត្រឹមត្រូវដែរឬទេ?

គ.តើធនាគារអាចសម្រេចបាននូវការទាមទាររកទ្រព្យសកម្ម ឬប្រាក់ចំណូលរបស់អតិថិជនបានដែរឬទេ?

ដូច្នេះនាយកដ្ឋានឥណទានត្រូវតែមានភាពប៉ិនប្រសព្វ និងទេព្យកោសល្យខ្ពស់ រួមផ្សំទាំងសមត្ថភាពដែលប្រកបដោយចំណេះដឹងនិងបទពិសោធន៍ក្នុងការត្រួតពិនិត្យទៅលើគុណសម្បត្តិអតិថិជនរបស់ខ្លួន។ គោលបំណងគឺដើម្បីកាត់បន្ថយហានិភ័យដែលអាចកើតមានឡើងក្រោយពេលផ្តល់ឥណទាន និងធានាអោយបានស្ថេរភាពសេដ្ឋកិច្ចជានិរន្តនៃស្ថាប័នរបស់ខ្លួន។ ហេតុបានជាតម្រូវឲ្យអតិថិជនបំពេញពាក្យជាលាយល័ក្ខអក្សរនៅក្នុងបែបបទនៃការស្នើសុំឥណទានដែលជាទូទៅមានដូចជា៖

- ពាក្យស្នើសុំខ្ចីប្រាក់
- កិច្ចសន្យាខ្ចីប្រាក់
- កិច្ចសន្យាដាក់បញ្ចាំ (ចលនទ្រព្យ និងអចលនទ្រព្យចំពោះឯកត្តជន)
- ប័ណ្ណឯកកម្មសិទ្ធិ (ចលនទ្រព្យ និងអចលនទ្រព្យចំពោះឯកត្តជន)

ក្នុងការវាយតម្លៃលើបែបបទស្នើសុំឥណទាន ភ្នាក់ងារឥណទានទទួលខុសត្រូវយ៉ាងយកចិត្តទុកដាក់ និងពិចារណាយ៉ាងល្អិតល្អន់ទៅលើកត្តា៧យ៉ាងដែលជាទូទៅគេឲ្យរូបមន្ត 6Cs រួមមាន៖

១. ចរិតលក្ខណៈ (Character)

សំដៅលើអ្នកខ្ចី និងអ្នកចូលរួមខ្ចី គឺត្រូវតែជាមនុស្សសុចរិត ទៀងត្រង់ មានភាពអំណត់អត់ធន ព្យាយាម ឧស្សាហ៍ ហ៊ានទទួលខុសត្រូវលើបំណុលដែលខ្លួនបានជំពាក់។

២. សមត្ថភាព (Capacity)

ធនាគារត្រូវឆ្វេងយល់ឲ្យបានច្បាស់ពីប្រភពចំណូល លំហូរសាច់ប្រាក់ និងលទ្ធភាពសងប្រាក់របស់អតិថិជន។ ដើម្បីវិភាគលើសមត្ថភាពសងរបស់អតិថិជន គឺត្រូវការឯកសារមួយចំនួនពីអតិថិជន៖

- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើអាជីវកម្ម
- របាយការណ៍ជាក់លាក់ពីចំណូលចំណាយ
- របាយការណ៍ស្តីពីទ្រព្យសកម្ម
- របាយការណ៍លំហូរសាច់ប្រាក់។

៣. សាច់ប្រាក់ (Cash)

សាច់ប្រាក់ គឺជាលំហូរនៃមូលនិធិជាសាច់ប្រាក់ (Liquidity Fund) ជាទូទៅទុនដែលអ្នកខ្ចីប្រើប្រាស់ក្នុងការសងត្រលប់នៃឥណទាន។ មន្ត្រីឥណទានត្រូវស្វែងយល់ថាតើអ្នកខ្ចីមានលទ្ធភាពគ្រប់គ្រាន់ដើម្បីរកសាច់ប្រាក់ក្នុងការសងឥណទានដែរឬទេ។ ធនាគារចាត់ទុកលំហូរសាច់ប្រាក់ជាប្រភពចំ

បងនៃការសងបំណុលរបស់អតិថិជនទៅឲ្យធនាគារដែលនឹងធ្វើឲ្យធនាគារមានលទ្ធភាពទាបំណុលកាន់តែតិចទៅ។ ប្រភពនៃលំហូរសាច់ប្រាក់បានមកពី៖

- សាច់ប្រាក់បានមកពីការលក់ និងចំណូលពីការលក់
- ទ្រព្យសកម្មដែលអាចលក់បាន ឬទ្រព្យដែលងាយបំលែងជាសាច់ប្រាក់
- មូលនិធិដែលប្រគល់បានមកពីការបោះផ្សាយនូវប័ណ្ណបំណុលផ្សេងៗ។

៤. វត្ថុបញ្ចាំ (Collateral)

សំដៅលើទ្រព្យសកម្មដែលត្រូវដាក់បញ្ចាំ ដើម្បីសម្រាប់ធានាដល់ការបាត់បង់នៃឥណទាន។ មន្ត្រីឥណទានត្រូវត្រួតពិនិត្យឲ្យបានច្បាស់លាស់នូវគុណភាពរបស់វត្ថុបញ្ចាំដោយត្រូវដឹងពីអាយុលក្ខខណ្ឌ និងវត្ថុមានតម្លៃ។ វត្ថុបញ្ចាំដែលមានតម្លៃនៅលើទីផ្សារត្រូវមានឯកសារច្បាស់លាស់ និងមានសុវត្ថិភាព។ គុណភាពឥណទានត្រូវអនុលោមតាមចំណុចដូចខាងក្រោម៖

- វត្ថុបញ្ចាំត្រូវមានភាពងាយស្រួលក្នុងការលក់ទៅលើទីផ្សារ និងមានស្ថេរភាពថ្លៃ
- ដែលមានតម្លៃនៅលើទីផ្សារដែលអាចលក់បានក្នុងរយៈពេលខ្លី
- ភាពស្របច្បាប់របស់វត្ថុបញ្ចាំ មានន័យថា វត្ថុបញ្ចាំជាកម្មសិទ្ធិស្របច្បាប់របស់អ្នកខ្ចី
- តម្លៃរបស់វត្ថុបញ្ចាំត្រូវសមស្របទៅនឹងគោលនយោបាយរបស់ឥណទានដែលបានកំណត់ដោយធនាគារ។

៥. លក្ខខណ្ឌ (Condition)

សំដៅលើការប្រើប្រាស់ឥណទាន និងការវិភាគទៅលើកត្តាខាងក្រៅ ឬខាងក្នុងដែលជះឥទ្ធិពលដែលនាំឲ្យអាជីវកម្មរបស់អ្នកសុំខ្ចីជួបវិបត្តិដែលនឹងនាំឲ្យអតិថិជនគ្មានសមត្ថភាពសង។ មន្ត្រីឥណទាន និងអ្នកវិភាគឥណទានត្រូវឲ្យច្បាស់ពីនិន្នាការ និងបម្រែបម្រួលនៃលក្ខខណ្ឌការងាររបស់អ្នកខ្ចីបម្រែបម្រួលនៃលក្ខខណ្ឌសេដ្ឋកិច្ចដែលមានឥទ្ធិពលលើឥណទាន។ មន្ត្រីឥណទានត្រូវស្វែងយល់ពី៖

- លក្ខខណ្ឌទីផ្សារៈ តើអាជីវកម្មរបស់អតិថិជនមានទីផ្សារយ៉ាងណាដែរ? ធំទូលាយ ឬតូចចង្អៀត? និងងាយស្រួលចូលទៅកាន់ទីផ្សារនៃអាជីវកម្មរបស់គាត់ដែរឬទេ?
- លក្ខខណ្ឌសេដ្ឋកិច្ចៈ យើងត្រូវដឹងពីបម្រែបម្រួលនៃសេដ្ឋកិច្ចបច្ចុប្បន្ន ហើយអាជីវកម្មរបស់អ្នកខ្ចីស្ថិតក្នុងសេដ្ឋកិច្ចបែបណា? ការកើនឡើងនៃអតិផរណាបណ្តាលមកពីបម្រែបម្រួលនៃអត្រាការប្រាក់។

៦. ការត្រួតពិនិត្យ (Control)

មន្ត្រីឥណទានមើលទៅលើការផ្លាស់ប្តូរច្បាប់របស់ប្រទេសដែលអាចប៉ះពាល់ដល់កិច្ចសន្យាឥណទាននោះតាមផ្លូវច្បាប់ ពីព្រោះដើម្បីធានាឲ្យបាននូវឥណទានមានប្រសិទ្ធិភាពខ្ពស់ ទោះបីជាប្រែប្រួលយ៉ាងណាក៏ដោយ។

**១.៦.៥.៣. ប្រភេទនៃវត្ថុបញ្ចាំ**

**ក. សន្និធិ**

ធនាគារផ្តល់ឥណទានដោយយកសន្និធិដូចជាទំនិញ វត្ថុធាតុដើមជាវត្ថុធានា។ ជាទូទៅធនាគារឲ្យខ្ចីក្នុងកម្រិត ៣០% ទៅ ៥០% នៃតម្លៃទីផ្សារ។

**ខ. ទ្រព្យសម្បត្តិជាក់ស្តែង**

ធនាគារយកទ្រព្យសម្បត្តិជាក់ស្តែងដូចជា ដី អាគារ និងសម្ភារៈរបស់ក្រុមហ៊ុនធ្វើជាវត្ថុធានាដោយស្ថិតក្រោមការវាយតម្លៃទីផ្សារ។

**គ. គណនីត្រូវទារ**

ធនាគារទទួលយកគណនីត្រូវទាររបស់អ្នកខ្ចីប្រាក់ធ្វើជា វត្ថុធានាឥណទានហើយអាចខ្ចីពីធនាគារក្នុងចំនួនចន្លោះពី ៥០% ទៅ ៩០%នៃគណនីត្រូវទារ។ នៅពេលដែលអតិថិជនរបស់អ្នកខ្ចីបានបញ្ជូនសាច់ប្រាក់ដើម្បីជម្រះបំណុលសាច់ប្រាក់នោះត្រូវសងទៅធនាគារវិញ។

**ឃ. ទ្រព្យសម្បត្តិផ្ទាល់ខ្លួន**

ធនាគារយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនដូចជា រថយន្ត ផ្ទះ គ្រឿងសង្ហារឹមដែលជារបស់អ្នកខ្ចីធ្វើជាវត្ថុធានា។ កិច្ចព្រមព្រៀងបញ្ចាំត្រូវបានចុះហត្ថលេខាដោយភាគីទាំងសងខាង។

**ង. ការធានាដោយបុគ្គល**

ការបញ្ចាំភាគហ៊ុន ទ្រព្យសម្បត្តិផ្ទាល់ខ្លួនផ្សេងៗទៀតត្រូវបានទាមទារធ្វើវត្ថុធានាសម្រាប់ឥណទាន។ ការធានាតែងតែទាមទារដោយធនាគារក្នុងការផ្តល់ឥណទានដល់អ្នកខ្ចី។ ហេតុនេះការយកទ្រព្យសម្បត្តិបុគ្គលធ្វើជាការធានាបានបង្ហាញបន្ថែមនូវឆន្ទៈរបស់ក្រុមហ៊ុនសងឥណទានដែលបានខ្ចី។

**១.៦.៦. ដំណើរការនៃការគ្រប់គ្រងឥណទាន**

**១.៦.៦.១. ការផ្សព្វផ្សាយ**

ដើម្បីធ្វើឲ្យអតិថិជនយល់កាន់តែច្បាស់ពីផលិតផលសេវាឥណទានរបស់ធនាគារត្រូវធ្វើការផ្សព្វផ្សាយ។ មធ្យោបាយនៃការផ្សព្វផ្សាយរួមមាន៖

- តាមប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ វិទ្យុ សារព័ត៌មាន

- តាមរយៈភ្នាក់ងារផ្សព្វផ្សាយ និងបុគ្គលិកធនាគារផ្ទាល់
- តាមរយៈអតិថិជនរបស់ធនាគារ
- ការចុះធ្វើយុទ្ធនាការផ្សព្វផ្សាយ(ចែកប័ណ្ណផ្សព្វផ្សាយ,ពន្យល់) និងទំនាក់ទំនងសាធារណៈ។

### ១.៦.៦.២. ការទាក់ទាញទឹកចិត្ត

ការទាក់ទាញទឹកចិត្ត គឺជាការធ្វើយ៉ាងណាដើម្បីជំរុញឲ្យមានការលក់ ឬង្កើនចំនួនអតិថិជនក្នុងការប្រើប្រាស់ផលិតផលឥណទាន។ ការទាក់ទាញទឹកចិត្តត្រូវអូសទាញឲ្យបាននូវអតិថិជនល្អៗ ទាំងអតិថិជនថ្មី និងអតិថិជនដែលមានស្រាប់ត្រូវលើកទឹកចិត្ត និងជំរុញឲ្យប្រើប្រាស់គណនីឥណទាននោះឲ្យបានច្រើនជាងមុន។ វិធីសាស្ត្រទាក់ទាញទឹកចិត្តអាចធ្វើតាមរយៈការផ្ញើសារផ្ទាល់ ការលក់ដោយលក្ខខណ្ឌពិសេស ការស្នើសុំផ្ទាល់ពីបុគ្គលិកលក់ និងតាមរយៈការផ្សព្វផ្សាយពាណិកម្ម។ ការផ្តល់ទំនុកចិត្ត ការបម្រើសេវាកម្មល្អ និងមានភាពងាយស្រួលក្នុងការស្នើរសុំឥណទានក៏ជាការទាក់ទាញទឹកចិត្តដែរ។

### ១.៦.៦.៣. ការជ្រើសរើសពាក្យស្នើសុំ

ការជ្រើសរើសពាក្យស្នើសុំត្រូវធ្វើឲ្យបានលឿន និងមានប្រសិទ្ធិភាពក្នុងការត្រួតពិនិត្យដើម្បីឲ្យឃើញថាអ្នកស្នើសុំមានលក្ខខណ្ឌមូលដ្ឋានត្រឹមត្រូវសម្រាប់បើកគណនីឥណទាន។ បច្ចុប្បន្ន អ្នកផ្តល់ឥណទានជាច្រើនបានប្រើប្រាស់ប្រព័ន្ធដាក់ពិន្ទុដើម្បីជ្រើសរើសពាក្យស្នើសុំឥណទាន។ ប្រព័ន្ធដាក់ពិន្ទុឥណទានគឺជាទម្រង់ស្ថិតិជាមូលដ្ឋានមួយ ឬកម្មវិធីកុំព្យូទ័រដែលកំណត់ពិន្ទុទៅតាមរបាយការណ៍ដែលមាននៅក្នុងបញ្ជីស្នើសុំ របាយការណ៍ហិរញ្ញវត្ថុ ឬរបាយការណ៍នៃការិយាល័យឥណទាន។ នៅក្នុងឥណទានអាជីវកម្ម ពិន្ទុដែលត្រូវបញ្ចូលផ្អែកលើការគណនាផលធៀបហិរញ្ញវត្ថុ ហើយការគណនានោះបានប្រើទ្រព្យសកម្ម បំណុល និងចំណូលរកបានពីអាជីវកម្មរបស់អ្នកស្នើសុំឥណទាន។ នៅក្នុងអាជីវកម្មឥណទានជម្រើសដំបូងក្នុងការផ្តល់ពិន្ទុតែងតែសិក្សា និងធ្វើការវិភាគលើរបាយការណ៍ហិរញ្ញវត្ថុ។ លទ្ធផលត្រូវបានគេប្រើប្រាស់ដើម្បីវាយតម្លៃលើសន្ទនីយភាពផលចំណេញ និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនស្នើសុំឥណទាន។

### ១.៦.៦.៤. ការស៊ើបអង្កេតឥណទាន

ការស៊ើបអង្កេតឥណទានគឺពាក់ព័ន្ធទៅនឹងជំហាននៅក្នុងមុខរបរអាជីវកម្ម ដើម្បីបញ្ជាក់ថាព័ត៌មានសំណើរសុំ និងកំណត់ពីអតិថិជននៃការបំពេញកាតព្វកិច្ចហិរញ្ញវត្ថុយ៉ាងដូចម្តេច? ការស៊ើប

អង្កេតឥណទានត្រូវធ្វើការសម្រេចចិត្តត្រឹមត្រូវ។ ភាពដ៏ល្អប្រសើបំផុតរបស់អ្នកគ្រប់គ្រងឥណទានគឺប្រមូលព័ត៌មានឲ្យបានគ្រប់គ្រាន់ដោយប្រើពេលវេលាតិច និងមិនចំណាយប្រាក់ច្រើនលើការស៊ើបអង្កេតមិនចាំបាច់។ អ្នកគ្រប់គ្រងឥណទាន ជាទូទៅនឹងទាក់ទងជាមួយភ្នាក់ងាររបាយការណ៍ពាណិជ្ជកម្ម ក្នុងកំឡុងពេលដំណាក់កាលនៃដំណើរការឥណទាននេះ។

### ១.៦.៦.៥ ការសម្រេចឥណទាន

ការសម្រេចចិត្តឥណទាន គឺជាការវិនិច្ឆ័យមួយដែលបានធ្វើដោយអ្នកគ្រប់គ្រងឥណទានដើម្បីទទួល ឬច្រានចោលសំណើរសុំទិញដោយឥណទាន។ សកម្មភាពដែលនាំឲ្យមានការសម្រេចត្រឹមត្រូវគឺផ្អែកលើភាពប៉ិនប្រសព្វ និងវិទ្យាសាស្ត្រ។ វិទ្យាសាស្ត្រពាក់ព័ន្ធទៅនឹងការវិភាគស្ថានភាពហិរញ្ញវត្ថុរបស់អ្នកស្នើសុំ។ ភាពប៉ិនប្រសព្វពាក់ព័ន្ធទៅនឹងបទពិសោធន៍ និងសមត្ថភាពរៀបចំសំនួរឲ្យបានសមរម្យដើម្បីព្យាករណ៍លទ្ធផលសំណង។

### ១.៦.៦.៦. ការត្រួតពិនិត្យគណនី

មុខងារត្រួតពិនិត្យ គឺមានតួនាទីត្រួតពិនិត្យគណនិឲ្យបានប្រាកដថាភាពជំពាក់បំណុលសរុបមានលក្ខណៈសមរម្យសម្រាប់បុគ្គលអតិថិជនឬទេ។ សកម្មភាពត្រួតពិនិត្យលើគណនីដើម្បីផ្ទៀងផ្ទាត់ថាផែនការសំណងចាប់ផ្ដើមសងតាមផែនការដែរឬទេ ហើយទំនាក់ទំនងរវាងអតិថជន និងអ្នកផ្ដល់ឥណទាននៅតែបន្តល្អដែលឬយ៉ាងណា។ សកម្មភាពនេះគឺតម្រូវឲ្យអ្នកគ្រប់គ្រងឥនទានបន្ថែមនូវព័ត៌មានថ្មីរបស់អតិថិជនក្នុងការសម្រេចបង្កើន ឬដាក់កំរិតបន្ទាត់ឥណទាន។ ហើយការត្រួតពិនិត្យនេះអាចជួយឲ្យមន្ត្រីឥណទានរកឃើញនូវគណនីសំណាងដែលមានការយឺតយ៉ាវ។

### ១.៦.៦.៧. ការប្រមូល

សកម្មភាពនៃការប្រមូល រួមមានការខិតខំប្រឹងប្រែងទាំងឡាយដើម្បីបានសំណាងវិក័យបត្រ ឬសំណងតាមនីតិវិធី។ ធនាគារត្រូវគិតគួរអំពីរកេរ្តិ៍ឈ្មោះរបស់អតិថិជនធ្វើយ៉ាងណាលើកទឹកចិត្ត និងបញ្ចុះបញ្ចូលអតិថិជនឲ្យធ្វើការសងទាន់ពេលវេលា ប៉ុន្តែក៏មិនត្រូវការពារកូនបំណុលពេកនោះទេព្រោះអាចឲ្យកូនបំណុលបានចិត្ត និងធ្វើឲ្យយឺតយ៉ាវក្នុងការសង។ ការឆ្លើយតបនឹងកម្មវិធីទារប្រមូល និងធ្វើឲ្យធនាគារអាចបង្កើនលំហូរសាច់ប្រាក់ រក្សាទំនាក់ទំនងល្អជាមួយអតិថិជន និងបង្កើនការសង។ មធ្យោបាយក្នុងការប្រមូលរួមមានៈ វិក័យបត្រ លិខិត ទូរស័ព្ទ និងប្រើវិធានការតាមផ្លូវច្បាប់ក្នុងករណីយឺតយ៉ាវសងធ្ងន់ធ្ងរ។

### ១.៦.៧. ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាហានិភ័យដែលបង្កឲ្យមានការខាតបង់ដល់ធនាគារក្នុងដំណើរការនៃការផ្ដល់ឥណទាន។ ហានិភ័យឥណទានរួមមាន៖[9]

- ហានិភ័យនៃការទូទាត់សង: ជាហានិភ័យដែលកើតមានឡើងនៅពេលកូនបំណុលមិនមានលទ្ធភាពសង ឬមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការសងបំណុលតាមកិច្ចសន្យា។
- ហានិភ័យវត្ថុធានា: កើតមានដោយសារការវាយតម្លៃមិនត្រឹមត្រូវលើទ្រព្យបញ្ចាំ និងទ្រព្យសកម្មផ្សេងទៀតរបស់មន្ត្រីឥណទាន។
- ហានីភ័យទីផ្សា: ជាហានិភ័យដែលបង្កឲ្យធនាគារមានការខាតបង់ដោយសារការប្រែប្រួលតម្លៃទ្រព្យសកម្មដែលជាវត្ថុធានានៃឥណទាននោះ។
- ហានិភ័យអត្រាការប្រាក់: ការប្រែប្រួលអត្រាការប្រាក់នៅលើទីផ្សាក៏ជាកត្តាដែលនាំឲ្យមានហានិភ័យឥណទានដែរ។

#### ១.៦.៧.១ ប្រភពនៃហានិភ័យឥណទាន

ហានិភ័យ គឺជាហេតុការណ៍ដែលបង្ករឲ្យមានការខូចខាតជាយថាហេតុ។ យោតាមការសិក្សាស្រាវជ្រាវកន្លងមក បានបង្ហាញឲ្យឃើញថាហានិភ័យឥណទានអាចកើតមានឡើងដោយអាស្រ័លើកត្តាបីយ៉ាងគឺ៖[10]

**ក-អតិថិជន**

- ការមិនយល់ពីលក្ខខណ្ឌនៃឥណទាន
- មានគំនិតមិនចង់សងបំណុល
- ការមិនគោរពតាមកិច្ចសន្យា
- បន្លំឯកសារ
- អតិថិជនជាអ្នកប្រព្រឹត្តល្បែងស៊ីសង និងអំពើអបាយមុខ
- អាជីវកម្មមានវិបត្តិ
- ការប្រើប្រាស់ខុសគោលដៅ។

**ខ-ធនាគារ**

[9] លោក សួន ចំរើន,(២០០៧),ស្ថាប័ន និង ទីផ្សារហិរញ្ញវត្ថុ, ទំព័រ៦

[10] Anthony Saunder & Linda Allen, (2010), "Credit Risk Management In and Out of the Financial Crisis",Third edition Page 24-33

- បុគ្គលិកដែលពាក់ព័ន្ធមិនបានយកចិត្តទុកដាក់ទៅលើការងាររបស់ខ្លួន
- ភ្នាក់ងារឥណទាន មិនបានយកចិត្តទុកដាក់បំពេញឯកសារឥណទានឲ្យបានត្រឹមត្រូវ
- ភ្នាក់ងារឥណទាន មិនបានយកចិត្តទុកដាក់ក្នុងការតាមដាន និងត្រួតនិពិត្យលើបំណុលឲ្យបានទាន់ពេលវេលា។

**គ-សង្គម និង ធម្មជាតិ**

- សង្គមៈ សង្គ្រាម ការប្រែប្រួលសេដ្ឋកិច្ច ការផ្លាស់ប្តូររដ្ឋាភិបាល និងនយោបាយ
- វិបត្តិសេដ្ឋកិច្ចៈ នាំឲ្យក្រុមហ៊ុន សហគ្រាស អជីវកម្ម ត្រូវប្រឈមមុខនឹងការក្ស័យធន
- គ្រោះធម្មជាតិៈ ទឹកជំនន់ គ្រោះរាំងស្ងួត និងមហន្តរាយផ្សេងៗដែលនាំឲ្យអតិថិជនបាត់បង់លទ្ធភាពសងបំណុលឲ្យធនាគារ

### ១.៦.៧.២ វិធីសាស្ត្រទប់ស្កាត់ហានិភ័យឥណទាន

ក្នុងនាមជាធនាគារមួយ ដែលជាអ្នកផ្តល់ឥណទានត្រូវតែមានវិធីសាស្ត្រយ៉ាងម៉ត់ចត់ក្នុងការគ្រប់គ្រងឥណទានឲ្យមានប្រសិទ្ធភាពដោយធនាគារបានចែងចេញជាពីចំណុចសំខាន់ៗដូចខាងក្រោមៈ

**ក-ចំពោះអតិថិជន**

ធ្វើការវាយតម្លៃឲ្យបានត្រឹមត្រូវអំពីអតិថិជនដូចជាៈ

- គោលបំណងសុំខ្ចី
- វិភាគរបាយការណ៍ហិរញ្ញវត្ថុ
- ពិចារណាលើគោលជំហរអ្នកសុំខ្ចី
- ត្រូវមានវត្ថុបញ្ចាំ ឬអ្នកធានា
- ផ្តល់យោបល់ក្នុងករណីផ្សេងៗដែលទាក់ទងនឹងការធ្វើអាជីវកម្មរបស់អតិថិជន។

**ខ-ចំពោះធនាគារ**

ពង្រីកសមត្ថភាពបុគ្គលិកដូចជាៈ

- ជ្រើសរើសបុគ្គលិកដែលមានចំណេះដឹងខាងផ្នែកឥណទាន
- បណ្តុះបណ្តាលបន្ថែមដល់បុគ្គលិក
- ដាក់ទោសចំពោះបុគ្គលិកដែលមានកំហុស

- លើកទឹកចិត្តដូចជា ផ្តល់ប្រាក់បន្ថែមលើប្រាក់បៀវត្សរ៍ ឬតំឡើងតំណែងដល់បុគ្គលិកណាដែលបំពេញការងារបានល្អ។

# ជំពូកទី២

# ស្ថានភាពទូទៅរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

## ២.១. ប្រវត្តិរបស់ធនាគារអេស៊ីលីដាភីអិលស៊ី

ដោយមានការគាំទ្រជាជំនួយមលនិធិពី កម្មវិធីអភវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDP)និងអង្គការពលកម្មអន្តរជាតិ (ILO) លើគម្រោងជួយស្តារឡើងវិញនូវសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា តាមរយៈការផ្សព្វផ្សាយលើការអភិវឌ្ឍសហគ្រាសខ្នាតតូច និងខ្នាតតូចបំផុត **អង្គការលីដា** (LEDA) ត្រូវបានបង្កើតឡើងនូវ **ខែធ្នូ ឆ្នាំ ១៩៩២** ក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ។[11]

**ក. ការកម្លាយដំណាក់កាលទី១: ១៩៩៣-១៩៩៦**

ដោយមានចំណាត់ការពីអង្គការ UNDP និង ILO ដើម្បីបង្កើតជាអង្គការសមាគម។ សមាជិក សមាជិកា និងបុគ្គលិករបស់អង្គការលីដា ទាំង ០៥ ខេត្ត-ក្រុង បានជួបជុំគ្នាក្នុងអង្គ មហាសន្និបាតលើកទី១នៅ **ថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៣** ដើម្បីធ្វើការផ្លាស់ប្តូរឈ្មោះអង្គការរបស់ខ្លួនពី **អង្គការលីដា** ទៅជា **អង្គការអេស៊ីលីដា**។

**ខ. ការកម្លាយដំណាក់កាលទី២ ១៩៩៦ - ១៩៩៨**

ពី **អង្គការអេស៊ីលីដា** មកជា **ស្ថាប័នមីក្រូហិរញ្ញវត្ថុអេស៊ីលីដា** ដោយយល់ឃើញនូវភាពចាំបាច់របស់អង្គការអេស៊ីលីដាដូចខាងក្រោមៈ

- ជានិរន្តរភាពស្វ័យហិរញ្ញវត្ថុរបស់អង្គការ
- ស្ថិតក្នុងអន្តរកាល នៃការកម្លាយខ្លួនជាស្ថាប័នមីក្រូហិរញ្ញវត្ថុ
- អង្គការអេស៊ីលីដាបានត្រៀម និងត្រូវបំពេញលក្ខខណ្ឌតម្រូវការជាចាំបាច់ចំនួន៣គឺៈ

1. ធ្វើការកែប្រែរចនាសម្ព័ន្ធនៃវឌ្ឍនាការពីអង្គការ អេស៊ីលីដា មកជាស្ថាប័នមីក្រូហិរញ្ញវត្ថុ
2. បង្កើតនូវនិរន្តតភាពហិរញ្ញវត្ថុ
3. ពង្រឹងនិងពង្រីកតំបន់ប្រតិបត្តិការ និងធ្វើការស្វែងរកមូលនិធិបន្ថែមពីអង្គការ ឬស្ថាប័នផ្តល់ជំនួយដទៃទៀត ដើម្បីនិរន្តរភាពហិរញ្ញវត្ថុ។

**គ. កម្លាយដំណាក់កាលទី៣: ១៩៩៨-២០០០**

[11] ឯកសារប្រវត្តិរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

ពី **ស្ថាប័នមីក្រូហិរញ្ញវត្ថុអេស៊ីលីដា** មកជា **ធនាគារ អេស៊ីលីដា លីមីធីត** ។ វ័យវឌ្ឍនាការដ៏ឆាប់រហ័ស នៃប្រតិបត្តិការ អេស៊ីលីដា ពីអង្គការមិនស្វែងរកប្រាក់ចំណេញ មកជាស្ថាប័នស្វ័យហិរញ្ញវត្ថុ ត្រូវបាននាំឲ្យ អេស៊ីលីដា ធ្វើដំណើរមកដល់ផ្លូវបំបែកមួយផ្សេងទៀតដែលតម្រូវឲ្យ អេស៊ីលីដា ធ្វើការកម្លាយខ្លួនពី **ស្ថាប័នមីក្រូហិរញ្ញវត្ថុ** មកជាធនាគារឯកទេសមួយគឺ **អនាគារ អេស៊ីលីដា លីមីធីត**។ តាមរយៈការសិក្សាជាច្រើន ដំណាក់កាល អេស៊ីលីដា មានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចក្លាយខ្លួនជាធនាគារឯកទេសបាន និងអាចទទួលបាននូវប្រយោជន៍ជាច្រើនទៀត។ ដោយមានការរីកចម្រើនឥតឈប់ឈរមានសក្តានុពលគ្រប់គ្រាន់មាននិរន្តរភាពលើគ្រប់វិស័យ (ការរៀបចំកកម្មវិធី បច្ចេកទេស រចនាសម្ព័ន្ធហិរញ្ញវត្ថុ) មានការគាំទ្រពីម្ចាស់ជំនួយ និងរាជរដ្ឋាភិបាល និងដម្បឆ្លើយតបទៅនឹងតម្រូវការទីផ្សារហិរញ្ញវត្ថុ អេស៊ីលីដាបានក្លាយខ្លួនទៅជាធនាគារ និងបានទទួលអាជាប័ណ្ណជាផ្លូវការនៅ **ថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០០** ជា **ធនាគារ អេស៊ីលីដា លីមីធីត។**

**ឃ. ការកម្លាយដំណាក់កាលទី៤: ២០០០-២០០៣**

ពី **ធនាគារ អេស៊ីលីដា លីមីធីត** មកជា **ធនាគារ អេស៊ីលីដា ភីអិលស៊ី** ។ ដោយមានធនធាន និងបច្ចេកវិជ្ជាព័ត៌មានគ្រប់គ្រាន់ ស្របតាមផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ធនាគារ អេស៊ីលីដា លីមីធីត មានឱកាស និងលទ្ធភាពគ្រប់គ្រាន់ក្នុងការកម្លាយខ្លួនទៅជាធនាគារពាណិជ្ជ។ ការកម្លាយខ្លួនទៅជាធនាគារពាណិជ្ជនេះ **ធនាគារ អេស៊ីលីដា លីមីធីត** មានគោលបំណង និងហេតុផលមួយចំនួនដូចតទៅ៖

- ដើម្បីអនុវត្តឲ្យបានត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេល ស្របតាមច្បាប់ ធនាគារ និងហិរញ្ញវត្ថុ
- ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការទទួលបាននូវប្រាក់កម្ចីពីធនាគារពាណិជ្ជ
- ដើម្បីឲ្យមានលទ្ធភាពគ្រប់គ្រាន់ ពេញលេញក្នុងការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុ ដូចជា៖ សេវាប្រាក់បញ្ញើ សេវាឥណទាន សេវាទូទាត់ និងសេវាផ្ទេរប្រាក់ជាដើម។
- ដើម្បីធ្វើឲ្យមានមូលដ្ឋានដើមទុនរឹងមាំ
- ដើម្បីឲ្យការបម្រើអតិថិជនមានការរីកលូតលាស់កាន់តែច្រើន
- ដើម្បីឆ្លើយតបទៅនឹងតម្រូការទីផ្សាហិរញ្ញវត្ថុ
- ដើម្បីផ្តល់សេវាកម្មឲ្យកាន់តែទូលំទូលាយថែមទៀត

**ធនាគារ អេស៊ីលីដា លីមីធីត** បានក្លាយខ្លួនទៅជា **ធនាគារ អេស៊ីលីដា ភីអិលស៊ី** បានទទួលអាជ្ញាប័ណ្ណជាផ្លូវការនៅ **ថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០៣** ជាមួយនឹងដើមទុនដែលបានចុះបញ្ជីចំនួន **១៣លានដុល្លារអាមេរិក** តំណាងឲ្យ ១៣លានភាគហ៊ុន តម្លៃភាគហ៊ុនដំបូងគឺ ០១ដុល្លារអាមេរិកក្នុងមួយហ៊ុន។

## ២.២. និមិត្តសញ្ញា និងអត្ថន័យ

### ២.២.១. និមិត្តសញ្ញា

### ២.២.២. អត្ថន័យនៃពាក្យ អេស៊ីលីដា

**អ** = អភិសមាចារ អភិវឌ្ឍន៍ អច្ឆរិយ

**ស** = សុខភាព សមត្ថភាព សីលធម៌

**ល** = លឿនទាន់ចិត្ត លទ្ធផលល្អ លើសលប់

**ដ** = ដឹងយល់ ដុះដាល ដល់គោលដៅ

គ.មូលហេតុដែលយកអក្សរ ធ្វើជានិមិត្តសញ្ញា

ជាទូទៅ គេតែងតែយកយករូបភាពផ្សេងៗធ្វើជានិមិត្តសញ្ញារបស់ក្រុមហ៊ុន ស្ថាប័ន ក្រសួង មន្ទី ។ល។ ប៉ុន្តែធនាគារអេស៊ីលីដា ភីអិលសស៊ី បានយកអក្សរខ្មែរ អេស៊ីលីដា និងអក្សរអង់គ្លេស ACLEDA ធ្វើជានិមិត្តសញ្ញា ដោយសារចង់ផ្សព្វផ្សាយជាសកលឲ្យមហាជនស្គាល់អក្សរខ្មែរតាមរយៈនិមិត្តសញ្ញានេះ ចំណែកការប្រើអក្សរអង់គ្លេស ព្រោះធនាគារ អេស៊ីលីដា ភីអិលស៊ី ផ្តល់សេវាហិរញ្ញវត្ថុទូលំទូលាយទូទាំងសកលលោក។

## ២.៣. ទស្សនៈ

ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាធនាគារពាណិជ្ជនាំមុខក្នុងប្រទេសកម្ពុជា ក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុល្អបំផុត ជូនដល់សាធារណជនគ្រប់មជ្ឈដ្ឋានក្នុងសហគមន៍ ។

## ២.៤. បេសកកម្ម

បេសកកម្មរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺផ្តល់ជូនសហគ្រិនខ្នាតតូចបំផុត ខ្នាតតូច ខ្នាតមធ្យម និងសាធារណជន នូវមធ្យោបាយក្នុងការគ្រប់គ្រង ចាត់ចែងធនធានហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីលើកស្ទួយជីវភាពរស់នៅឱ្យប្រសើរឡើង ដោយអនុវត្តឱ្យបាននូវនិរន្តរភាព និងបង្កើននូវអត្ថប្រយោជន៍ជូនដល់ភាគទុនិក កម្មករនិយោជិត ព្រមទាំងសហគមន៍ទាំងអស់ ។ យើងប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍សីលធម៌វិជ្ជាជីវៈ សង្គម ច្បាប់ និង បរិស្ថាន ប្រកបដោយកម្រិតខ្ពស់បំផុត ។

## ២.៥. វប្បធម៌ការងារ

- ការពេញចិត្តនឹងការងារ
- ព្យាយាមធ្វើការឲ្យមានប្រសិទ្ធិភាព
- ស្អាតស្អំ មិនពុករលួយ មិនស៊ីសំណូក
- ស្មោះត្រង់ មានសាមគ្គីភាព ឯកភាព
- មានការចូលរួមខ្ពស់ពីគ្រប់លំដាប់ថ្នាក់ និងគ្រប់ផ្នែកការងារ
- សុភាពរាបសារ ទន់ភ្លន់ តែម៉ឹងម៉ាត់ចំពោះការងារ
- ម្ចាស់ការលើការងារ ប្រកបដោយការទទួលខុសត្រូវ។

## ២.៦. គោលដៅ

គោលដៅរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺត្រូវផ្តល់ផលិតផលនិងសេវាកម្ម ធនាគារដ៏ល្អបំផុត និងមានសុវត្ថិភាពខ្ពស់តាមរយៈសាខា និងបណ្តាញនានាជាច្រើនរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ជូនដល់អតិថិជនគ្រប់ស្រទាប ដោយប្រមើលមើលលើតម្រូវការរបស់អតិថិជន និងត្រៀមលក្ខណៈរួមជាស្រេចដើម្បីឆ្លើយតបនឹងតម្រូវការទាំងនោះឲ្យបានឆាបរហ័សទានចិត្ត ផ្តល់នូវប្រតិបត្តការហិរញ្ញវត្ថុដ៏រឹងមាំ និង ជាក់លាក់ដោយរក្សាបាននូវបរិយាកាសការងារដែលអាចទាក់ទាញថែរក្សា និងអភិវឌ្ឍន៍កម្មករ និយោជិក ដែលមានឆន្ទៈការងារខ្ពស់ដែលបានរួមចំណែកក្នុងការធ្វើឲ្យធនាគារទទួលបានជោគជ័យ និងការគិតគូរដល់សហគមន៍ និងបរិស្ថានផងដែរ។

## ២.៧. ផលិតផល និងសេវាកម្ម

- ឥណទាន (Credits)
- សេវាបញ្ញើ-សន្សំ (Deposits)
- សេវាផ្ទេរប្រាក់ (Funds Transfers)

- សេវាចាត់ចែងសាច់ប្រាក់ (Cash Management)
- សេវាហិរញ្ញប្បទានពាណិជ្ជកម្ម (Trade Finance)
- សេវាធនាគារអេឡិចត្រូនិច (Electronic Banking Service)

## ២.៨. ភាគទុនិក

### ២.៨.១. ភាគទុនិកក្នុងស្រុក (កាន់កាប់ភាគហ៊ុន ៥១%)

- អង្គការអេស៊ីលីដា (ACLEDA NGO)
- ក្រុមហ៊ុន អេអេសអេអ៊ីន្ស (ASA, Inc. =សាជីវកម្មសមាគមបុគ្គលិកអេស៊ីលីដា)

### ២.៨.២. ភាគទុនិកបរទេស (កាន់កាប់ភាគហ៊ុន ៤៩%)

- ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (DEG)
- ធនាគារអភិវឌ្ឍន៍ហុល្លង់ដ៍ (FMO)
- សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)
- ធនាគារទ្រីយ៉ូដូស នៃប្រទេសហុល្លង់ដ៍ (Triodos-Doen)
- Triodos Fair Share Fund (TFSF)

**តារាងទី២.១: ភាគទុនិករបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៨**

| ភាគទុនិក | ភាគរយនៃកម្មសិទ្ធិ | មូលធនភាគហ៊ុន (ដុល្លារអាមេរិក) | ចំនួនភាគហ៊ុន |
|---|---|---|---|
| អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ | ២៦,០០០០% | ១០២.៧៥៨.២៦៧$ | ១០២.៧៥៨.២៦៧ |
| ក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី | ២៥,០០០០% | ៩៨.៨០៦.០៣៤$ | ៩៨.៨០៦.០៣៤ |
| Sumitomo Mitsui Banking Corporation | ១៨,២៥០០% | ៧២.១២៨.៣៩៦$ | ៧២.១២៨.៣៩៦ |
| COFIBRED | ១២,២៥០០% | ៤៨.៤១៤.៩៥២$ | ៤៨.៤១៤.៩៥២ |
| ORIX Corporation | ១២,២៥០០% | ៤៨.៤១៤.៩៥២$ | ៤៨.៤១៤.៩៥២ |
| Triodos Microfinance Fund | ២,៥៥០៨% | ១០.០៨១.៤១៨$ | ១០.០៨១.៤១៨ |
| Triodos Fair Share Fund | ២,១៨១៤% | ៨.៦២១.៣៤៣$ | ៨.៦២១.៣៤៣ |
| Triodos Sustainable Finance Foundation | ១,៥១៧៨% | ៥.៩៩៨.៧៤៣$ | ៥.៩៩៨.៧៤៣ |
| **សរុប** | **១០០%** | **៣៩៥.២២៤.១០៥$** | **៣៩៥.២២៤.១០៥** |

## ២.៩. ប្រវត្តិ និងទីតាំងភូមិសាស្ត្ររបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខ

### ក. ប្រវត្តិ

ធនាគារអេស៊ីលីដា ភីអិលស៊ី បានបើកសាខាថ្មីទី២៣៥ មានឈ្មោះថា "**សាខាវិមានចតុមុខ**" ដែលមានទីតាំងស្ថិតនៅខាងត្បូងវិមានឯករាជ្យ អគារលេខ១៩៥ មហាវិថីព្រះនរោត្តម កែងវិថីសម្តេចល្វីឯម ភូមិ៥ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ។ បានបើកជាផ្លូវការ **នៅថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១២** ដើម្បីស្វែងរកនូវចំណែកទីផ្សារ និងបំពេញតម្រូវការរបស់អតិថិជន។ ធនាគារអេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខ មានបុគ្គលិកចំនួន ១១០នាក់ ស្រីចំនួន ៦០នាក់ ប្រុស ៥០នាក់។

### ខ. ទីតាំងភូមិសាស្ត្រ



## ២.១០. រចនាសម្ព័ន្ធគ្រប់គ្រង និងអង្គការលេខសាខា



# ជំពូកទី៣
# គោលការណ៍ប្រតិបត្តិការឥណទានខ្នាតតូច

## ៣.១. សេចក្តីផ្តើម

ការបង្កើតនូវគោលការណ៍ប្រតិបត្តិការឥណទានខ្នាតតូចនេះឡើង គឺដើម្បីផ្តល់មូលនិធិដល់អ្នកខ្ចីក្នុងការផ្គត់ផ្គង់តម្រូវការប្រើប្រាស់គ្រប់ប្រភេទអាជីវកម្មរួមមាន ផលិតកម្ម ពាណិជ្ជកម្ម កសិកម្ម សេវាកម្ម និងទេសចរណ៍ ដើម្បីឲ្យអាជីវកម្មមានលទ្ធភាពពង្រីកមធ្យោបាយ បង្កើនប្រាក់ចំណូលក្នុងសកម្មភាពប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។[12]

## ៣.២. គោលបំណង

- ដើម្បីនិរន្តរភាពបង្កើនទ្រព្យសម្បត្តិធនាគារ និងតម្លៃភាគហ៊ុន។
- រួមចំណែកអភិវឌ្ឍ និងជំរុញឲ្យមាននិរន្តរភាពអាជីកម្ម។
- ទ្រទ្រង់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម តាមរយៈការប្រមូលធន និងដាក់ឲ្យមានចរាចរក្នុងផ្នែកផលិតកម្មដល់សង្គម ស្រូបយកផលប្រយោជន៍ពីប្រភពធនធានដែលមានក្នុងប្រទេស ដើម្បីបង្កើតការងារ និងបង្កើនប្រាក់ចំណូល។

## ៣.៣. ទំហំឥណទាន

ធនាគារអេស៊ីលីដា ភីអិលស៊ី ផ្តល់ឥណទានខ្នាតតូចដល់អតិថិជនជាប្រាក់រៀល ប្រាក់បាត និងប្រាក់ដុល្លារអាមេរិក ទៅតាមតម្រូវការជាក់ស្តែងរបស់អតិថិជន។ ទំហំឥណទានខ្នាតតូចត្រូវបានកំណត់ដូចខាងក្រោមៈ

### ៣.៣.១. ឥណទានជាប្រាក់រៀល

ឥណទានទោលជាប្រាក់រៀល ត្រូវបានបង្កើតឡើងសម្រាប់អតិថិជនដែលមានតម្រូវការជាឯកត្តជន ឬគ្រួសារ ដើម្បីប្រើប្រាសដ់ក្នុងការពង្រីកមុខរបរ។

- ទំហំឥណទាន: អតិបរមារហូតដល់ ១២០,០០០,០០០រៀល (មួយរយម្ភៃលានរៀល)។
- ឥណទានសម្រាប់: ឯកត្តជន ឬគ្រួសារ។
- ចន្លោះពេលសងប្រាក់ (Interval): ប្រចាំពីរសប្តាហ៍ ប្រចាំបួនសប្តាហ៍ ប្រចាំខែ។
- ការធានា: តម្រូវឲ្យមានទ្រព្យសម្បត្តិដាក់ធានា និង/ឬ មានអ្នកធានា។

[12] ធនាគារ អេស៊ីលីដា ភីអិលស៊ី, (២០១៦), "គោលការណ៍ប្រតិបត្តិឥណទានខ្នាតតូច" ទំព័រ១

❖ អ្នកមានសមត្ថកិច្ចអនុម័តឥណទាន អាចសម្រេចតាមសភាពជាក់ស្តែងអំពីតម្រូវការធានានេះ។

### ៣.៣.២. ឥណទានជាប្រាក់បាត

ឥណទានទោលជាប្រាក់រៀល ត្រូវបានបង្កើតឡើងសម្រាប់អតិថិជនដែលមានតម្រូវការជាឯកត្តជន ឬគ្រួសារ ដើម្បីប្រើប្រាស់ក្នុងការពង្រីកមុខរបរ។

- ទំហំឥណទាន: អតិបរមារហូតដល់ ១,២០០,០០០បាត (មួយលានពីររយពាន់បាត)។
- ឥណទានសម្រាប់: ឯកត្តជន ឬគ្រួសារ។
- ចន្លោះពេលសងប្រាក់ (Interval): ប្រចាំពីរសប្តាហ៍ ប្រចាំបួនសប្តាហ៍ ប្រចាំខែ។
- ការធានា: តម្រូវឲ្យមានទ្រព្យសម្បត្តិដាក់ធានា និង/ឬ មានអ្នកធានា។

❖ អ្នកមានសមត្ថកិច្ចអនុម័តឥណទាន អាចសម្រេចតាមសភាពជាក់ស្តែងអំពីតម្រូវការធានានេះ។

### ៣.៣.៣. ឥណទានជាប្រាក់ដុល្លារអាមេរិក

ឥណទានទោលជាប្រាក់រៀល ត្រូវបានបង្កើតឡើងសម្រាប់អតិថិជនដែលមានតម្រូវការជាឯកត្តជន ឬគ្រួសារ ដើម្បីប្រើប្រាស់ក្នុងការពង្រីកមុខរបរ។

- ទំហំឥណទាន: អតិបរមារហូតដល់ ៣០,០០០ដុល្លាអាមេរិក។
- ឥណទានសម្រាប់: ឯកត្តជន ឬគ្រួសារ។
- ចន្លោះពេលសងប្រាក់ (Interval): ប្រចាំពីរសប្តាហ៍ ប្រចាំបួនសប្តាហ៍ ប្រចាំខែ។
- ការធានា: តម្រូវឲ្យមានទ្រព្យសម្បត្តិដាក់ធានា និង/ឬ មានអ្នកធានា។

❖ អ្នកមានសមត្ថកិច្ចអនុម័តឥណទាន អាចសម្រេចតាមសភាពជាក់ស្តែងអំពីតម្រូវការធានានេះ។

## ៣.៤. សោហ៊ុយឥណទាន និងអត្រាការប្រាក់

### ៣.៤.១. សោហ៊ុយឥណទាន

– ធនាគារតម្រូវឲ្យអតិថិជនចេញសោហ៊ុយឥណទាន១%នៃបរិមាណឥណទានខ្នាតតូចដែលមានទំហំចាប់ពី១០,០០០ដុល្លារអាមេរិក ឬសមមូលឡើងទៅ។
– ករណីអតិថិជនស្នើឲ្យធនាគារ អេស៊ីលីដា ភីអិលស៊ី រត់ការសំណុំឯកសារបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចអតិថិជនត្រូវបង់ថ្លៃចំណាយរត់ការឯកសារទាំងនោះ តាមតម្លៃដែលបានចំណាយជាក់ស្តែង។

### ៣.៤.២. អត្រាការប្រាក់

#### ក. ឥណទានជាប្រាក់រៀលខ្មែរ

- ឥណទានខ្នាតតូចជាប្រាក់រៀលខ្មែរ មានអត្រាការប្រាក់អប្បបរមា ២.៤% ក្នុងមួយខែ សម្រាប់ឥណទានដែលមានទំហំរហូតដល់ ៦,០០០,០០០ រៀល។
- អត្រាការប្រាក់អប្បបរមា ១.៨០% ក្នុងមួយខែសម្រាប់ឥណទានដែលមានទំហំធំជាង ៦,០០០,០០០ រៀល រហូតដល់ ២០,០០០,០០០ រៀល។
- អត្រាការប្រាក់អប្បបរមា ១.៧០% ក្នុងមួយខែសម្រាប់ឥណទានដែលមានទំហំធំជាង ២០,០០០,០០០ រៀល រហូតដល់ក្រោម ៤០,០០០,០០០ រៀល។
- អត្រាការប្រាក់អប្បបរមា ១.៥០% ក្នុងមួយខែសម្រាប់ឥណទានដែលមានទំហំចាប់ពី ៤០,០០០,០០០ រៀល រហូតដល់ ១២០,០០០,០០០ រៀល។

#### ខ. ឥណទានជាប្រាក់បាត

ឥណទានខ្នាតតូចជាប្រាក់បាត មានអត្រាការប្រាក់អប្បបរមា ២.៤% ក្នុងមួយខែ សម្រាប់ឥណទានដែលមានទំហំរហូតដល់ ៦០,០០០ បាត។

- អត្រាការប្រាក់អប្បបរមា ១.៨០% ក្នុងមួយខែសម្រាប់ឥណទានដែលមានទំហំធំជាង ៦០,០០០ បាត រហូតដល់ ២០០,០០០ បាត។
- អត្រាការប្រាក់អប្បបរមា ១.៧០% ក្នុងមួយខែសម្រាប់ឥណទានដែលមានទំហំធំជាង ២០០,០០០ បាត រហូតដល់ក្រោម ៤០០,០០០ បាត។
- អត្រាការប្រាក់អប្បបរមា ១.៥០% ក្នុងមួយខែសម្រាប់ឥណទានដែលមានទំហំចាប់ពី ៤០០,០០០ បាត រហូតដល់ ១,២០០,០០០ បាត។

#### គ. ឥណទានជាប្រាក់ដុល្លារអាមេរិក

- ឥណទានខ្នាតតូចជាប្រាក់ដុល្លារអាមេរិក មានអត្រាការប្រាក់អប្បបរមា ២.៤% ក្នុងមួយខែសម្រាប់ឥណទានដែលមានទំហំរហូតដល់ ១,៥០០ ដុល្លារអាមេរិក។
- អត្រាការប្រាក់អប្បបរមា ១.៨០% ក្នុងមួយខែសម្រាប់ឥណទានដែលមានទំហំធំជាង ១,៥០០ ដុល្លារអាមេរិក រហូតដល់ ៥,០០០ ដុល្លារអាមេរិក។
- អត្រាការប្រាក់អប្បបរមា ១.៧០% ក្នុងមួយខែសម្រាប់ឥណទានដែលមានទំហំធំជាង ៥,០០០ ដុល្លារអាមេរិក រហូតដល់ក្រោម ១០,០០០ ដុល្លារអាមេរិក។

- អត្រាការប្រាក់អប្បបរមា ១.៥០% ក្នុងមួយខែសម្រាប់ឥណទានដែលមានទំហំចាប់ពី ១០,០០០ ដុល្លារអាមេរិក រហូតដល់ ៣០,០០០ ដុល្លារអាមេរិក។

**តារាងទី៣.១. តារាងសង្ខេបសោហ៊ុយឥណទាន និងអត្រាការប្រាក់**

| | ទំហំឥណទាន | អត្រាការប្រាក់ | សោហ៊ុយឥណទាន | សោហ៊ុយរៀបចំឯកសារ |
|---|---|---|---|---|
| ប្រាក់រៀល | រហូតដល់ ៦,០០០,០០០រៀល | អប្បបរមា ២.៤%ក្នុងមួយខែ | គ្មាន | គ្មាន |
| | ធំជាង ៦,០០០,០០០រៀល រហូតដល់២០,០០០,០០០ រៀល | អប្បបរមា១.៨០%ក្នុងមួយខែ | គ្មាន | គ្មាន |
| | ធំជាង ២០,០០០,០០០រៀល រហូតដល់ក្រោម ៤០,០០០,០០០រៀល | អប្បបរមា ១.៧០%ក្នុងមួយខែ | គ្មាន | គ្មាន |
| | ចាប់ពី ៤០,០០០,០០០រៀល រហូតដល់១២០,០០០,០០០ រៀល | អប្បបរមា១.៥០%ក្នុងមួយខែ | ១%នៃទំហំឥណទាន | គ្មាន |
| ប្រាក់បាត | រហូតដល់៦០,០០០បាត | អប្បបរមា ២.៤%ក្នុងមួយខែ | គ្មាន | គ្មាន |
| | ធំជាង៦០,០០០បាត រហូតដល់២០០,០០០បាត | អប្បបរមា១.៨០%ក្នុងមួយខែ | គ្មាន | គ្មាន |
| | ធំជាង២០០,០០០បាត រហូតដល់ក្រោម៤០០,០០០បាត | អប្បបរមា ១.៧០%ក្នុងមួយខែ | គ្មាន | គ្មាន |
| | ចាប់ពី៤០០,០០០បាតរហូតដល់១,២០០,០០០បាត | អប្បបរមា១.៥០%ក្នុងមួយខែ | ១%នៃទំហំឥណទាន | គ្មាន |
| ប្រាក់ដុល្លារអាមេរិក | រហូតដល់១,៥០០ដុល្លារ | អប្បបរមា ២.៤%ក្នុងមួយខែ | គ្មាន | |
| | ធំជាង១,៥០០ដុល្លារ រហូតដល់៥,០០០ដុល្លារ | អប្បបរមា១.៨០%ក្នុងមួយខែ | គ្មាន | គ្មាន |
| | ធំជាង៥,០០០ដុល្លារ រហូតដល់ក្រោម១០,០០០ដុល្លារ | អប្បបរមា ១.៧០%ក្នុងមួយខែ | គ្មាន | គ្មាន |
| | ចាប់ពី១០,០០០ រហូតដល់ ៣០,០០០ដុល្លារ | អប្បបរមា១.៥០%ក្នុងមួយខែ | ១%នៃទំហំឥណទាន | គ្មាន |

**ឃ. ការគណនាការប្រាក់**

ការប្រាក់ ត្រូវបានគណនាតាមរូបមន្តៈ

$$I = (P \times i\% \times N) \div 360$$

- I: ជាអត្រាការប្រាក់ដែលត្រូវទទួលបាន ឬអតិថិជនត្រូវសង (Interest Receivable)
- P: ជាចំនួនទឹកប្រាក់ដើមជាក់ស្តែង (Actual Principal During the Period)
- i%: ជាអត្រាការប្រាក់គិតក្នុងមួយឆ្នាំ (Interest Rate per Year)
- N: ជាចំនួនថ្ងៃគិតការប្រាក់ក្នុងរយៈពេលខ្ចី (Number of Day for Calculating Interest)
- 360: ជាចំនួនថ្ងៃគិតក្នុងមួយឆ្នាំ (Number of Day per Year)

## ៣.៥. រយៈពេលខ្ចី

រយៈពេលខ្ចីនៃឥណទាន ប្រែប្រួលជាអនុគមន៍ទៅតាទំហំប្រាក់កម្ចី។

### ៣.៥.១. ឥណទានជាប្រាក់រៀល

- រយៈពេលខ្ចីអតិបរមា ១២ខែ ចំពោះឥណទានដែលមានទំហំរហូតដល់ ៤០០,០០០រៀល។
- រយៈពេលខ្ចីអតិបរមា ២៤ខែ ចំពោះឥណទានដែលមានទំហំធំជាង ៤០០,០០០រៀល រហូតដល់ ៦,០០០,០០០រៀល។
- រយៈពេលខ្ចីអតិបរមា ៣៦ខែ ចំពោះឥណទានដែលមានទំហំធំជាង ៦,០០០,០០០រៀល រហូតដល់ ២០,០០០,០០០រៀល។
- រយៈពេលខ្ចីអតិបរមា ៤៨ខែ ចំពោះឥណទានដែលមានទំហំធំជាង ២០,០០០,០០០រៀល រហូតដល់ក្រោម ៤០,០០០,០០០រៀល។
- រយៈពេលខ្ចីអតិបរមា ៦០ខែ ចំពោះឥណទានដែលមានទំហំចាប់ពី ៤០,០០០,០០០រៀល រហូតដល់ ១២០,០០០,០០០រៀល។

### ៣.៥.២. ឥណទានជាប្រាក់បាត

- រយៈពេលខ្ចីអតិបរមា ១២ខែ ចំពោះឥណទានដែលមានទំហំធំជាង ៤,០០០បាត។
- រយៈពេលខ្ចីអតិបរមា ២៤ខែ ចំពោះឥណទានដែលមានទំហំធំជាង ៤,០០០បាត រហូតដល់ ៦០,០០០បាត។

- រយៈពេលខ្ចីអតិបរមា ៣៦ខែ ចំពោះឥណទានដែលមានទំហំធំជាង ៦០,០០០បាត រហូតដល់ ២០០,០០០បាត។
- រយៈពេលខ្ចីអតិបរមា ៤៨ខែ ចំពោះឥណទានដែលមានទំហំធំជាង ២០០,០០០បាត រហូតដល់ក្រោម ៤០០,០០០បាត។
- រយៈពេលខ្ចីអតិបរមា ៦០ខែ ចំពោះឥណទានដែលមានទំហំចាប់ពី ៤០០,០០០បាត រហូតដល់ ១,២០០,០០០បាត។

### ៣.៥.៣. ឥណទានជាប្រាក់ដុល្លារអាមេរិក

- រយៈពេលខ្ចីអតិបរមា ២៤ខែ ចំពោះឥណទានមានទំហំរហូតដល់ ១,៥០០ដុល្លារអាមេរិក។
- រយៈពេលខ្ចីអតិបរមា ៣៦ខែ ចំពោះឥណទានដែលមានទំហំធំជាង ១,៥០០ដុល្លារអាមេរិក រហូតដល់ ៥,០០០ដុល្លារអាមេរិក។
- រយៈពេលខ្ចីអតិបរមា ៤៨ខែ ចំពោះឥណទានដែលមានទំហំធំជាង ៥,០០០ដុល្លារអាមេរិក រហូតដល់ក្រោម ១០,០០០ដុល្លារអាមេរិក។
- រយៈពេលខ្ចីអតិបរមា ៦០ខែ ចំពោះឥណទានដែលមានទំហំចាប់ពី ១០,០០០ដុល្លារអាមេរិក រហូតដល់ ៣០,០០០ដុល្លារអាមេរិក។

## ៣.៦. លក្ខខណ្ឌកំណត់ទំហំឥណទាន និងការដាក់ធានា

- ការកំណត់ទំហំឥណទានត្រូវផ្អែកលើការជឿជាក់ និងលទ្ធភាព៖[13]
  - សុចរិតភាព ប្រវត្តិ កេរ្តិ៍ឈ្មោះ
  - សមត្ថភាព ជំនាញ ភាពប៉ិនប្រសព្វ ការទទួលខុសត្រូវ
  - សកម្មភាពជំនួញ
  - និរន្តរភាពហិរញ្ញវត្ថុ (ភាពខ្លាំងនៃហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់) ទីផ្សារ (សក្តានុពលទីផ្សារ)
  - ហានិភ័យ-សុវត្ថិភាព។
- ការសិក្សា វិភាគ ដោយឆ្លុះបញ្ចាំងលើប្រវត្តិនៃប្រតិបត្តិការមុខរបរគ្រាមុនរបស់ឯតិថិជន។ ដោយឡែកចំពោះទ្រព្យសម្បត្តិដែលដាក់ធានា ភាពត្រឹមត្រូវនៃទ្រព្យ ភាពងាយស្រួលលក់ កម្រិត

[13] ធនាគារ អេស៊ីលីដា ភីអិលស៊ី, (២០១៦), "គោលការណ៍ប្រតិបត្តិឥណទានខ្នាតតូច" ទំព័រ៦

ដែលអាចធានាសុវត្ថិភាពឥណទានបាន គឺជាកត្តាកំណត់ជាមួយគ្នានោះ ការចុះអង្កេតដល់ទីកន្លែងជាកត្តាមិនអាចខ្វះបាន។

### ៣.៦.១. ការកំណត់ទំហំឥណទាន

- ទំហំឥណទានត្រូវបានកំណត់ទៅតាមលទ្ធភាពសងមិនលើសពី ៦៧% នៃប្រាក់ចំណេញសុទ្ធ បន្ទាប់ពីដកប៉ាន់ស្មានចំណាយគ្រួសាររបស់អ្នកសុំខ្ចី (Net Profit) ឬផ្អែកលើលំហូរសាច់ប្រាក់ ស្ថានភាពរឹងមាំនៃហិរញ្ញវត្ថុ និងសកម្មភាពជំនួញ។
- ទំហំឥណទានមិនត្រូវច្រើនជាង ឬស្មើ ១០០% នៃតម្លៃទ្រព្យសម្បត្តិសុទ្ធផ្ទាល់ខ្លួន។
- ទំហំឥណទានត្រូវអនុលោមតាមលក្ខខណ្ឌនៃការដាក់ទ្រព្យសម្បត្តិតម្កល់ធានាអះអាង និងការដាក់ធានា។

### ៣.៦.២. ការដាក់ទ្រព្យសម្បត្តិធានា

ឥណទានទោលជាប្រាក់រៀល ប្រាក់បាត និងប្រាក់ដុល្លារអាមេរិក ទំហំឥណទានត្រូវបានកំណត់ទៅតាមប្រភេទនៃទ្រព្យដាក់ធានា ដូចខាងក្រោម៖

ក. ដាក់ធានាជាដី និងផ្ទះ ឬអាគារ

+ ទំហំឥណទានមិនត្រូវលើស ៨០% នៃតម្លៃប៉ាន់ប្រមាណងាយលក់នៃទ្រព្យសម្បត្តិដែលបានដាក់ធានា។ ការដាក់ធានាតម្រូវឲ្យមានការចុះហត្ថលេខា និងបោះត្រាបញ្ជាក់ដឹងឮដល់អាជ្ញាធរមូលដ្ឋានសម្រាប់ឥណទាន៖
    - ប្រាក់រៀលទំហំរហូតដល់ ១៥,០០០,០០០រៀល
    - ប្រាក់បាតទំហំរហូតដល់ ១៥០,០០០បាត
    - ប្រាក់ដុល្លារអាមេរិក ៤,០០០ដុល្លារអាមេរិក។
+ ទំហំឥណទានមិនត្រូវលើស ៨០% នៃតម្លៃប៉ាន់ប្រមាណងាយលក់នៃទ្រព្យសម្បត្តិដែលបានដាក់ធានា។ ការដាក់ធានាតម្រូវឲ្យមានប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) និងការចុះការីបន្ទុកដាក់ធានាពីមន្ទីរ ឬការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សម្រាប់ឥណទានដែលមានទំហំ៖
    - ប្រាក់រៀលមានទំហំធំជាង ១៥,០០០,០០០រៀល រហូតដល់ ១២០,០០០,០០០រៀល
    - ប្រាក់បាតមានទំហំធំជាង ១៥០,០០០បាត រហូតដល់ ១,២០០,០០០បាត

- ប្រាក់ដុល្លារអាមេរិកមានទំហំធំជាង ៥,០០០ដុល្លារអាមេរិក រហូតដល់ ៣០,០០០ ដុល្លារ។

+ ចំពោះដី ផ្ទះ ឬអាគារ ដែលមានប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) ជាកម្មសិទ្ធិរបស់អ្នកបញ្ចាំជំនួសអ្នកខ្ចីអាចទទួលយកបាន ក្នុងករណីដែលប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) អាចចុះការីបន្ទុកដាក់ធានាបានពីមន្ទីរ ឬការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

+ ករណីផ្សេងពីនេះ នាយកប្រតិបត្តិឥណទានជាអ្នកសម្រេច។

### ៣.៦.៣. ការទទួលយកទ្រព្យដាក់បញ្ចាំផ្សេងទៀត

សម្រាប់ឥណទានទោលដែលមានទំហំធំជាង ៥,០០០ដុល្លារអាមេរិក ឬសមមូល៖

- ទ្រព្យសម្បត្តិផ្សេងទៀតដែលមានអត្តសញ្ញាណសម្គាល់ អាចទទួលយកជាទ្រព្យដាក់ធានាបានដោយគួបផ្សំជាមួយទ្រព្យដាក់ធានាជាដី ផ្ទះ ឬអាគារ និងគណនីប្រាក់បញ្ញើ។ ទ្រព្យសម្បត្តិផ្សេងទៀតដែលទទួលយកជាការដាក់ធានានេះ ទោះជាមានតម្លៃខ្ពស់យ៉ាងណាក៏ដោយ សាខាត្រូវវាយតម្លៃឲ្យបានច្បាស់លាស់អំពីអាយុកាលប្រើប្រាស់ និងបម្រែបម្រួលនៃហានិភ័យ ដើម្បីប៉ាន់ប្រមាណលើការធានាសុវត្ថិភាពឥណទាន ធៀបទៅនឹងរយៈពេលនៃឥណទាន។
- ករណីចាំបាច់ នាយកប្រតិបត្តិឥណទាន ជាអ្នកសម្រេចក្នុងការទទួលយកទ្រព្យកម្មសិទ្ធិដាក់ធានាដែលពុំទាន់មានប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) ដោយមានសំណើរពីនាយក-នាយិកាសាខា "ក" ធនាគារ អេស៊ីលីដា ភីអិលស៊ី។

### ៣.៦.៤. អំពីលទ្ធកម្មនៃទ្រព្យដាក់ធានា

ទ្រព្យសម្បត្តិដាក់ធានារបស់អតិថិជនអាចជាកម្មវត្ថុនៃការធ្វើលទ្ធកម្មសម្រាប់បុគ្គលទូទៅលើកលែងតែបុគ្គលិកធនាគារ អេស៊ីលីដា ភីអិលស៊ី មួយចំនួនដែលត្រូវបានហាមឃាត់ ៖ ភ្នាក់ងារឥណទាន និងភ្នាក់ងារដោះស្រាយបំណុលដែលទទួលខុសត្រូវផ្ទាល់ចំពោះអតិថិជននោះ។ លទ្ធកម្មនៃទ្រព្យដាក់ធានាត្រូវបានធ្វើឡើងតាមលក្ខខណ្ឌដូចខាងក្រោម៖

- អតិថិជន ឬម្ចាស់កម្មសិទ្ធិនៃទ្រព្យដាក់ធានា ព្រមព្រៀងប្រកាសលក់ដោយពុំមានកាបង្ខិតបង្ខំ។
- មានប្រកាសលក់ជាឡាយឡុងជាសាធារណៈដោយតុលាការ។

ការធ្វើលទ្ធកម្មនៃទ្រព្យដាក់ធានាដោយកម្មករនិយោជិកធនាគារ អេស៊ីលីដា ភីអិលស៊ី ត្រូវតែបង្ហាញអំពីតម្លាភាពយ៉ាងច្បាស់លាស់។

## ៣.៧. ការសងត្រឡប់មកវិញនៃឥណទាន

### ៣.៧.១. របៀបសងប្រាក់

ការសងត្រឡប់មកវិញនៃឥណទានខ្នាតតូចអនុវត្តតាមតារាងកាលវិភាគសងប្រាក់ដែលបានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់។ ការសងប្រាក់នៃឥណទានអនុវត្តតាមការប្រែប្រួលសមតុល្យឥណទានប្រចាំថ្ងៃ (Current Balance Repayment Method) តាមរបៀបសងដូចខាងក្រោម៖

- សងការប្រាក់ និងសងប្រាក់ដើមរំលស់
- សងរំលស់ប្រាក់ដើមបូកការប្រាក់ថេរ (Annuity Instalment) ជារៀងរាល់ខែ
- សងការប្រាក់ និងសងប្រាក់ដើមគិតជាភាគរយ ហើយប្រាក់ដើមនៅសល់សងនៅចុងវគ្គ
- សងការប្រាក់ ហើយសងប្រាក់ដើមទៅតាមការព្រមព្រៀង
- សងតែការប្រាក់ និងសងប្រាក់ដើមនៅចុងបញ្ចប់នៃវគ្គខ្ចីប្រាក់ (Balloon Payment)។

### ៣.៧.២. ការសងត្រឡប់មកវិញនៃឥណទាន

ភ្នាក់ងារឥណទានត្រូវធ្វើកាលវិភាគ និងវាយតម្លៃលទ្ធភាពសងរបស់អតិថិជន ដើម្បីឲ្យប្រាកដថាឥណទានត្រូវបានសងត្រឡប់មកវិញទាំងប្រាក់ដើម ទាំងការប្រាក់ បានទាន់ពេលវេលា។ ការវាយតម្លៃប៉ាន់ស្មានលទ្ធភាពសងបំណុល ដោយផ្អែកសំខាន់បំផុតលើចំណូលអ្នកខ្ចីជាមូលដ្ឋាន គឺមិនផ្អែកទៅលើចំណូលដែលនឹងកើតមាន ឬប៉ាន់ស្មានលំហូរសាច់ប្រាក់ដែលនឹងទទួលនៅពេលអនាគតទេ។ ប្រសិនបើចំណូលសំខាន់ៗ ពីមុខរបរមិនគ្រប់គ្រាន់សម្រាប់សងបំណុលទេនោះអាចវិភាគលើចំណូលផ្សេងៗ តែត្រូវធ្វើការសិក្សាឲ្យបានល្អិតល្អន់ធ្វើយ៉ាងណាបង្ហាញឲ្យឃើញថា អ្នកខ្ចីពិតជាមានលទ្ធភាពអាចសងបំណុលបានទាំងស្រុង។

- ❖ ករណីអតិថិជនសងបំណុលបញ្ចប់មុនកាលបរិច្ឆេទនៃកិច្ចសន្យាខ្ចីប្រាក់ ការប្រាក់ត្រូវបានកាត់បន្ថយ។ ការប្រាក់ដែលត្រូវបានកាត់បន្ថយ ត្រូវគណនាសមាមាត្រទៅនឹងចំនួនថ្ងៃដែលសងដាច់មុនកាលកំណត់នោះ។

### ៣.៧.៣. ការធ្វើតារាងកាលវិភាគសងប្រាក់ឡើងវិញ

ការធ្វើតារាងកាលវិភាគសងប្រាក់ឡើងវិញ អាចអនុញ្ញាតឲ្យបានចំពោះអតិថិជនដែលសងបំណុលប្រាក់ដើមលើសពីចំនួនកំណត់ក្នុងតារាងកាលវិភាគសងប្រាក់តែប៉ុណ្ណោះ ដោយកាត់បន្ថយរយៈពេលខ្ចី ឬរក្សារយៈពេលខ្ចីនៅដដែល។

### ៣.៧.៤. រយៈពេលអនុគ្រោះ

រយៈពេលអនុគ្រោះការប្រាក់មិនបានផ្ដល់ជូនឡើយ។

### ៣.៧.៥. ការផ្ដល់ឥណទានបន្ថែម

ការផ្ដល់ឥណទានបន្ថែមលើសមតុល្យឥណទានចាស់ ត្រូវបានអនុញ្ញាត ដោយអនុលោមទៅតាមនីតិវិធី និងសិទ្ធិក្នុងការអនុម័តឥណទាន លុះត្រាតែៈ

- អតិថិជនមានមុខរបរីកចម្រើន-ចំណូលកើនឡើង ឬផ្ដល់ឥណទានលើកមុនមិនទាន់អស់លទ្ធភាព ហើយមុខរបរមានសក្ដានុពល។
- អតិថិជនត្រូវការដើមទុនពង្រីកមុខរបរបន្ថែម និងមានទ្រព្យសម្បត្តិធានាគ្រប់គ្រាន់។

## ៣.៨. ការខកខានសង និងការពិន័យ

### ៣.៨.១. ការខកខានសង

ឥណទានមួយត្រូវបានចាត់ទុកថាខកខានមិនបានសងតាមកិច្ចសន្យា កាលណាដល់ពេលវេលាសងហើយអ្នកខ្ចីមិនបានសងទាន់ពេលវេលា (ក្នុងថ្ងៃ) ដូចបានចែងក្នុងកិច្ចសន្យា និងតារាងកាលវិភាគសងប្រាក់។

- រយៈពេលខកខានសងប្រាក់ គឺជាចំនួនថ្ងៃដែលខកខានមិនបានសងតាមកិច្ចសន្យា រាប់ចាប់ពីថ្ងៃយឺតដំបូង ហើយរយៈពេលនេះត្រូវបានកាត់បន្ថយ ក្នុងករណីទំហំទឹកប្រាក់បានសងសមាមាត្រទៅនឹងទំហំទឹកប្រាក់នៃចន្លោះរយៈពេលយឺតយ៉ាវសងនោះ។
- ទឹកប្រាក់ខកខានសង គឺជាទឹកប្រាក់ដែលមិនបានសង ឬសងមិនគ្រប់ចំនួនចាប់ពីថ្ងៃដំបូង។ ទឹកប្រាក់ដែលសងក្រោយត្រូវយកទៅបំពេញឲ្យទឹកប្រាក់មិនបានសង ឬសងមិនគ្រប់ចំនួនពេលដំបូង រួចហើយកាត់សងបំពេញទៅទឹកប្រាក់មិនបានសង ឬសងមិនគ្រប់ចំនួននៅពេលបន្តបន្ទាប់។

#### ៣.៨.១.១. ការខកខានសងកម្រិតស្រាល (Minor Default)

ការខកខានសងកម្រិតស្រាល គឺជាការខកខានសងប្រាក់ ដែលទឹកប្រាក់ខកខានមិនបានសង ឬទឹកប្រាក់សងមិនគ្រប់ចំនួន ហួសកាលកំណត់នៃកិច្ចសន្យារយៈពេលតិចជាង ៣០ថ្ងៃ។

#### ៣.៨.១.២. ការខកខានសងធ្ងន់ធ្ងរ (Major Default)

ការខកខានសងធ្ងន់ធ្ងរ គឺជាការខកខានសងប្រាក់ ដែលទឹកប្រាក់ខកខានមិនបានសង ឬទឹកប្រាក់សងមិនគ្រប់ចំនួន ហួសកាលកំណត់នៃកិច្ចសន្យារយៈពេលចាប់ពី ៣០ថ្ងៃ។ នាយក-នាយិកាសាខា "ក" ធនាគារ អេស៊ីលីដា ភីអិលស៊ី អាចផ្ទេរការទទួលខុសត្រូវដោះស្រាយបញ្ហាឥណទានប្រភេទនេះ ពីភ្នាក់ងារឥណទានឲ្យទៅភ្នាក់ងារដោះស្រាយបំណុល អាស្រ័យលើការចាត់ចែងរបស់សាខានីមួយៗ។

### ៣.៨.២. ការពិន័យ

#### ៣.៨.២.១. ពិន័យ

- ការខកខានសងបំណុលចាប់ពីរយៈពេល ០៤ថ្ងៃឡើងទៅត្រូវបានគិតពិន័យ។ អត្រាពិន័យត្រូវបានគិតស្មើនឹង ២៤% (ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំ។
- ទឹកប្រាក់ពិន័យត្រូវបានគណនាតាមអត្រាពិន័យលើចំនួនទឹកប្រាក់ដែលខកខានមិនបានសងសមាមាត្រទៅចំនួនថ្ងៃដែលខកខានសងនោះចាប់គិតពីថ្ងៃទី០៤ នៃការយឺតយ៉ាវសងឡើងទៅ។

រូបមន្ត: $P = (A \times t \times N) \div 360$

P ជាចំនួនទឹកប្រាក់ពិន័យ

- A ជាចំនួនទឹកប្រាក់ដែលខកខានសង
- t ជាអត្រាពិន័យក្នុងមួយឆ្នាំ (២៤%)
- N ជាចំនួនថ្ងៃដែលខកខានសងហួសកិច្ចសន្យាគិតចាប់ពីថ្ងៃទី ០៤ នៃការយឺតយ៉ាវសងឡើងទៅ។
- 360 ជាចំនួនថ្ងៃគិតក្នុងមួយឆ្នាំ។

#### ៣.៨.២.២. ការលុបចោលប្រាក់ពិន័យ

នាយក-នាយិកាសាខា "ក" មានសិទ្ធិសម្រេចលុបចោលប្រាក់ពិន័យ ក្នុងករណីមានហេតុផលសមរម្យដែលស្នើរឡើងដោយភ្នាក់ងារឥណទាន និងមានសេចក្តីបញ្ជាក់ពី នាយក-នាយិកាសាខា "ខ"

ឬប្រធានភ្នាក់ឥណទានសាខា "ក"។ ដើម្បីលុបប្រាក់ពិន័យត្រូវតែមានឯកសារយោងសម្រាប់ចុះបញ្ជីគណនេយ្យឲ្យបានត្រឹមត្រូវ។

## ៣.៩. ការផ្សព្វផ្សាយ

ដើម្បីធ្វើឲ្យអតិថិជនយល់កាន់តែច្បាស់ពីផលិតផលសេវាឥណទានខ្នាតតូចរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ត្រូវធ្វើការផ្សព្វផ្សាយផលិតផលរបស់ធនាគារនៅក្នុងចំណោមកម្មករនិយោជិក និងនៅក្នុងសហគមន៍កសិករ អាជីវកម្មជំនួញមានសក្តានុពល។ ភ្នាក់ងារឥណទាន (Credit Officer) និងភ្នាក់ងារបម្រើអតិថិជន (Customer Service Officer) ត្រូវទទួលខុសត្រូវលើការផ្សព្វផ្សាយឲ្យបានជ្រួលជ្រាប និងស៊ីជម្រៅធ្វើយ៉ាងណាទាញយកចំណែកទីផ្សារឲ្យបានទូលំទូលាយនៅគ្រប់ទីកន្លែង គ្រប់តំបន់នៅក្នុងប្រទេសកម្ពុជា។

យុទ្ធសាស្ត្រផ្សព្វផ្សាយត្រូវបានយកមកប្រើ ដូចជា៖

- ការផ្សព្វផ្សាយពាណិជ្ជកម្មតាមប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ វិទ្យុ សារព័ត៌មាន
- តាមរយៈភ្នាក់ងារផ្សព្វផ្សាយ និងគ្រប់បុគ្គលិករបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី
- តាមរយៈអតិថិជនរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ការចុះធ្វើយុទ្ធនាការផ្សព្វផ្សាយ (ចែកប័ណ្ណផ្សព្វផ្សាយ, ពន្យល់) និងទំនាកទំនងសាធារណៈ។

## ៣.១០. ទីផ្សារគោលដៅ

ផលិតផលនេះត្រូវបានយកចិត្តទុកដាក់ជាពិសេសសម្រាប់បម្រើតម្រូវការទីផ្សារ ទៅតាមកម្រិតអាចទទួលយកបានរបស់អតិថិជនកម្ពុជាគ្រប់រូប នៅទីជនបទ ទីក្រុង និងតំបន់នានាទៀតក្នុងប្រទេសកម្ពុជា។ ទីផ្សារគោលដៅរបស់ធនាគារ គឺប្រជាជនកម្ពុជាគ្រប់រូបដែលស្ថិតក្នុងសមាគមន៍សេដ្ឋកិច្ច ចាប់ពីកម្រិតទាបបំផុតឡើងទៅ លក្ខណៈជាគ្រួសារ (ឯកត្តជន) ឬចងក្រងជាក្រុម ឬជាសហគ្រាសសិប្បកម្មដែលសកម្មភាពមុខរបរ អនុលោមទៅតាមលក្ខណៈវិនិច្ឆ័យរបស់មីក្រូហិរញ្ញវត្ថុ។

ទោះបីយ៉ាងណាក៏ដោយធនាគារ អេស៊ីលីដា ភីអិលស៊ី នឹងបន្តធ្វើការគាំទ្រដល់អតិថិជនរបស់ខ្លួនដែលជាបង្អែកដ៏រឹងមាំ ដើម្បីធ្វើឲ្យកំណើនសេដ្ឋកិច្ចមានការផ្លាស់ប្តូរទៅរកភាពរីកចម្រើនកាន់តែប្រសើរឡើង។

ក្រុមគោលដៅសម្រាប់ទីផ្សាឥណទានខ្នាតតូចរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺ៖

- មុខរបរមានទីតាំងនៅក្នុងប្រទេសកម្ពុជាដែលមានស្ថានភាពល្អនៅក្នុងទីផ្សា ហើយមុខរបរមានសក្តានុពល

- មានកេរ្តិ៍ឈ្មោះ និងទំនាក់ទំនងល្អ
- សកម្មភាពមុខរបរស្របច្បាប់
- មានតម្លាភាពអាជីវកម្ម លំហូរសាច់ប្រាក់មានស្ថិរភាព (ប៉ុន្តែអាចអនុញ្ញាត ចំពោះមុខរបរដែលមានលក្ខណៈតាមរដូវកាល)។

## ៣.១១. លក្ខណាមនុស្សដែលអាចទទួលឥណទាន

រូបវន្តបុគ្គលជានីតិជន (បុគ្គលដែលមានសិទ្ធិប្រកបការងារតាមផ្លូវច្បាប់) និងជានីតិជនដែលរស់នៅ និងមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានប្រវត្តិ និងអត្តចរិតល្អ ដែលអាចជឿទុកចិត្តបាន។
- ធានាផ្តល់ព័ត៌មានជូនធនាគារ ត្រឹមត្រូវ ច្បាស់លាស់ គ្រប់គ្រាន់ និងទាន់ពេលវេលា។
- មិនជាប់ពិរុទ្ធដែលពាក់ព័ន្ធនឹងបទល្មើសផ្សេងៗ។
- មានទីលំនៅអចិន្ត្រៃយ៍ក្នុងតំបន់ប្រតិបត្តិការរបស់សាខាធនាគារទទួលខុសត្រូវ និងបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរក្នុងតំបន់ដែលខ្លួនរស់នៅមានដូចជា សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណ។ល។
- មានមុខរបរ និងប្រាក់ចំណូលច្បាស់លាស់ ដែលបង្ហាញពីលទ្ធភាពអាចសងបំណុលបានគ្រប់ចំនួនមកវិញទាំងប្រាក់ដើម និងការប្រាក់។
- មានដី ផ្ទះ ឬទ្រព្យសម្បត្តិផ្សេងទៀតដែលអាចជំនួសបាន។
- មិនមានបំណងផ្លាស់ទីលំនៅទៅកន្លែងផ្សេង ក្រៅពីតំបន់ប្រតិបត្តិការរបស់សាខាធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលខ្លួនបានទទួលប្រាក់កម្ចី រហូតដល់ពេលសងបំណុលធនាគារចប់។

  មិនអនុញ្ញាតឲ្យខ្ចីឥណទានពីធនាគារ អេស៊ីលីដា ភីអិលស៊ី ចំពោះ៖

  ក. អនីតិជន (បុគ្គលដែលមិនមានសិទ្ធិប្រកបការងាតាមផ្លូវច្បាប់ក្រោមអាយុ ១៨ឆ្នាំ) និងជនពិការសតិ ញៀនគ្រឿងស្រវឹង និងញៀនថ្នាំ។

  ខ. បញ្ជីអាជីវកម្មដែលត្រូវបានហាមឃាត (Exclusion List) របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី (ឧបសម្ព័ន្ធ)។

## ៣.១២. តម្រូវការ និង សុវត្ថិភាពឥណទាន

### ក. តម្រូវការសម្រាប់អ្នកខ្ចី

- មានគម្រោងជំនួញច្បាស់លាស់ដែលអាចបង្ហាញថាមុខជំនួញមានសក្តានុពល និងមាននិរន្តរភាព។
- យល់ច្បាស់រាល់ប្រការ លក្ខខណ្ឌ និងនីតិវិធីឥណទានរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។
- មានការព្រមព្រៀងជាមុនគ្រប់ចំនុច លើរាល់លិខិតស្នាម និងផ្តិតមេដៃស្តាំនៅចំពោះមុខ។
- គោរពកាតព្វកិច្ចរបស់ខ្លួន និងលក្ខខណ្ឌទាំឡាយដែលមានចែងក្នុងកិច្ចសន្យា។
- មានលទ្ធភាពសងបំណុលទាន់ពេលវេលា និងយល់ព្រមបង់ប្រាក់ដល់ការិយាល័យធនាគារ អេស៊ីលីដា ភីអិលស៊ី។
- យល់ព្រមចុះកិច្ចសន្យាធានាអះអាងបំណុលក្នុងក្រុម។ ចំពោះឥណទានទោលករណីយល់ថាមិនអាចសងបំណុលបានទាន់ពេលវេលា អតិថិជនត្រូវតែរកអ្នកធានាដែលមានសមត្ថភាពអាចសងបំណុលជំនួសខ្លួនបាន។
- មានទុនផ្ទាល់ខ្លួនក្នុងមុខរបរ យ៉ាងតិច ២០%នៃទុនវិនិយោគសរុប។
- មានទ្រព្យសម្បត្តិដែលអាចធានាបំណុលបានទាំងស្រុង។
- យល់ព្រមដាក់ទ្រព្យសម្បត្តិធានា។

### ខ. តម្រូវការសម្រាប់ធានាសុវត្ថិភាពឥណទាន

តម្រូវការសម្រាប់ធានាសុវត្ថិភាពឥណទានគឺប្រែប្រួលទៅតាមប្រភេទទំហំ និងកម្រិតហានិភ័យនៃឥណទាន។ គ្រប់ប្រភេទនៃឥណទានតម្រូវការសម្រាប់ធានាសុវត្ថិភាពឥណទានគឺៈ

- មានទ្រព្យសម្បត្តិដាក់ធានាសម្រាប់ធានាសុវត្ថិភាពប្រាក់កម្ចី និងមានអ្នកធានា
- ករណីមានអ្នកធានា អ្នកធានាត្រូវមានមុខរបរដាច់ដោយឡែកពីអ្នកខ្ចី
- តម្រូវការផ្សេងទៀតក៏ត្រូវឲ្យមានផងដែរ ដោយយោងទៅតាមកម្រិតហានិភ័យដែលប៉ាន់ស្មាន។

## ៣.១៣. ការវាយតម្លៃឥណទាន

ដើម្បីមានមូលដ្ឋានសម្រាប់ធ្វើការសម្រេចចិត្តផ្តល់ឥណទាន ត្រូវមានព័ត៌មានគ្រប់គ្រាន់ និងច្បាស់លាស់អំពីអតិថិជន និងមុខរបរ (របស់អតិថិជន) ព្រមទាំងកត្តាផ្សេងៗទៀតនៅជុំវិញដែលជះឥទ្ធិពល ដើម្បីយកមកធ្វើការសិក្សា-វិភាគ និងវាយតម្លៃ អំពីសុចរិតភាព សមត្ថភាព និងសុវត្ថិភាព

ឥណទាន។

រាល់សំណើសុំឥណទាន ប្រតិបត្តិករត្រូវចូលយកព័ត៌មានឥណទាន ពីប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៃការិយាល័យឥណទាន "កម្ពុជា" (Credit Bureau "Cambodia" Co,,Ltd) ដើម្បីរកព័ត៌មានឥណទានដែលពាក់ព័ន្ធនឹងបំណុលរបស់អ្នកស្នើសុំខ្ចី។

ការសិក្សា វាយតម្លៃឥណទានត្រូវបែងចែកជាបី៖

- ការចុះសិក្សាដល់លំនៅឋាន និងទីកន្លែងប្រកបអាជីវកម្មរបស់អតិថិជន។
- ការផ្ទៀងផ្ទាត់ជាមួយព័តឥមានឥណទាននៃការិយាល័យឥណទាន "កម្ពុជា" (Credit Bureau "Cambodia" Co,,Ltd)។
- ការសិក្សាអំពីបំណុលហួសកម្រិត (Over-indebtedness)។

### ក. ការចុះសិក្សាដល់លំនៅឋាន និងទីកន្លែងប្រកបអាជីវកម្មរបស់អតិថិជន

ភ្នាក់ងារឥណទានត្រូវចុះដល់លំនៅឋាន និងទីកន្លែងប្រកបអាជីវកម្មរបស់អតិថិជន និងត្រូវផ្តោតការយកចិត្តទុកដាក់សិក្សា-វាយតម្លៃ កត្តាសំខាន់ជាគន្លឹះមួយចំនួន ដូចខាងក្រោម៖

១- ចរិតលក្ខណៈ (Character): ត្រូវអង្កេតប្រមូលព័ត៌មាន អំពីប្រវត្តិ អត្តចរិត លក្ខណសម្បត្តិ សមត្ថភាពគ្រប់គ្រង ជំនាញ បទពិសោធន៍ ទីផ្សារ កេរ្តិ៍ឈ្មោះ ចេតនាសងបំណុល...។ល។

២- ដើមទុន (Capital): វាយតម្លៃស្ថានភាពហិរញ្ញវត្ថុក្នុងមុខរបរ ដើមទុន និងប្រភពទុន។ ការវាយតម្លៃដើមទុន ត្រូវប្រមូលព័ត៌មានអំពីមុខរបរ ដែលជាទិន្នន័យសម្រាប់រៀបចំគម្រោងជំនួញរបស់អតិថិជនដើម្បីត្រួតពីនិត្យគោលបំណងនៃការប្រើប្រាស់ប្រាក់កម្ចី។

៣- សមត្ថភាព និងលំហូរសាច់ប្រាក់: វាយតម្លៃលំហូរសាច់របស់អតិថិជន ប្រាក់ចំណូលពីមុខរបរ (ចំណេញ-ខាត) និងចំណូលផ្សេងៗប្រចាំថ្ងៃ ប្រចាំខែ រដូវកាល តាមកាលៈទេសៈ ឲ្យបានច្បាស់លាស់ ត្រឹមត្រូវ ដើម្បីធ្វើការប៉ានប្រមាណតម្រូវការឥណទាន រយៈពេលឥណទាន និងលទ្ធភាពសងប្រាក់។

៤- ទ្រព្យធានា ឬតម្កល់ធានា (Collateral): ការវាយតម្លៃទ្រព្យសម្បត្តិដាក់ធានា ឬតម្កល់ធានាសុវត្ថិភាពឥណទាន ត្រូវធ្វើការត្រួតពិនិត្យដល់ទីកន្លែងជាក់ស្តែង។ អាចធ្វើការវាយតម្លៃពិចាណាតាម REALTOR ដូចខាងក្រោម៖

- Right collateral: ទ្រព្យសម្បត្តិស្របច្បាប់
- Estimate the value of collateral: តម្លៃប៉ាន់ស្មាននៃទ្រព្យដាក់តម្កល់ធានា

- Ability to sell collateral: លទ្ធភាពដែលអាចលក់ដូរបាននៃទ្រព្យធានា
- Location of collateral: ទីតាំងរបស់ទ្រព្យដាក់តម្កល់
- Type of collateral: ប្រភេទទ្រព្យដាក់តម្កល់
- Ownership: ភាពជាម្ចាស់កម្មសិទ្ធិនៃទ្រព្យដាក់តម្កល់
- Risk of collateral: ហានិភ័យនៃទ្រព្យដាក់តម្កល់។

៥- លក្ខខណ្ឌ (Conditions): ត្រូវធ្វើការសិក្សា និងវិភាគអំពីហានិភ័យទាំងឡាយដែលអាចបង្កការជះឥទ្ធិពលដល់ការសងប្រាក់របស់អតិថិជនដូចជា ហានិភ័យលើការគ្រប់គ្រង ហានិភ័យទីផ្សារ ហានិភ័យហិរញ្ញវត្ថុ ហានិភ័យទ្រព្យធានា និងហានិភ័យលើមុខរបរ។ អាចដាក់លក្ខខណ្ឌបន្ថែមសម្រាប់ការធានាសុវត្ថិភាពឥណទាន ដូចជាធ្វើការវាយតម្លៃទ្រព្យសម្បត្តិផ្សេងទៀត។

គ្រប់ចំណុចទាំង ៥ ដែលបានវាយតម្លៃខាងលើ ត្រូវធ្វើការសន្និដ្ឋាន ដោយអនុលោមតាមការណ៍ និងក្ខខណ្ឌឥណទាន ព្រមទាំងស្វែងរកចំណុចខ្លាំង ចំណុចខ្សោយ ដើម្បីវាយតម្លៃលទ្ធភាពខ្ចី និងសមត្ថភាពសងបំណុលរបស់អ្នកខ្ចីឲ្យបានត្រឹមត្រូវ។

**ខ. ការផ្ទៀងផ្ទាត់ជាមួយព័ត៌មានឥណទាននៃការិយាល័យឥណទាន "កម្ពុជា"**

ព័ត៌មានដែលប្រមូលបានពីការចុះសិក្សាដល់លំនៅឋាន និងទីកន្លែងប្រកបអាជីវកម្មការងាររបស់អតិថិជនត្រូវធ្វើការផ្ទៀងផ្ទាត់ជាមួយព័ត៌មានឥណទាន ដែលចូលយកក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៃការិយាល័យឥណទាន "កម្ពុជា" មុននឹងធ្វើការវិនិច្ឆ័យអំពីលទ្ធភាព និងសុវត្ថិភាពឥណទាន។

❖ សោហ៊ុយចំណាយសម្រាប់ការិយាល័យឥណទាន "កម្ពុជា" ជាបន្ទុករបស់អតិថិជនដោយកាត់ចេញពីគណនី ឬបង់ជាសាច់ប្រាក់ដោយផ្ទាល់នៅពេលទទួលឥណទាន។ ក្នុងករណីដែលធនាគារបដិសេធសំណើរសុំឥណទានរបស់អតិថិជន សោហ៊ុយចំណាយសម្រាប់ការិយាល័យឥណទាន "កម្ពុជា" ជាបន្ទុករបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។

❖ សោហ៊ុយចំណាយសម្រាប់ការិយាល័យឥណទាន "កម្ពុជា" ត្រូវជូនដំណឹងដោយនាយកដ្ឋានឥណទាន។

**គ. ការសិក្សាអំពីបំណុលហួសកម្រិត** (Over-indebtedness)

ដើម្បីចៀសវាងបាននូវការបន្តផ្តល់កម្ចីត្រួតជាន់គ្នាច្រើនស្ថាប័ន រហូតដល់អតិថិជនមានបំណុលហួសកម្រិត និងលើសពីលទ្ធភាពសងរបស់ខ្លួន តម្រូវឲ្យធ្វើការសិក្សាឆ្វេងយល់អំពីរាល់បំណុលដែលអតិថិជនកំពុងមានជាមួយឯកត្តជន និងស្ថាប័ននានាដោយៈ

១-មិនត្រូវផ្តល់កម្ចី ឬបន្តផ្តល់កម្ចីឡើវិញដល់អតិថិជនទាំងឡាយណាដែលកំពុងជំពាក់បំណុលនៅស្ថាប័នហិរញ្ញវត្ថុផ្សេងទៀតចាប់ពីបីស្ថាប័នឡើងទៅ (Bank & MFIs)។

២-ការកំណត់ចំនួនស្ថាប័នដូចបានរៀបរាប់ខាងលើ ផ្អែកទៅតាមរបាយការណ៍ដែលបានចូលត្រួតពិនិត្យក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន នៃការិយាល័យឥណទាន "កម្ពុជា" និងអាចតាមមធ្យោបាយដទៃទៀត។

៣-ឥណទានសម្រាប់ប័ណ្ណឥណទានអេស៊ីលីដា (ACLEDA Credit Card) ពុំត្រូវរាប់បញ្ចូលក្នុងករណី (១) ខាងលើឡើយ។

## ៣.១៤. ឥណទានដែលត្រូវទទួលបានការលើកលែង

រាល់ឥណទានទាំងឡាយណាដែលមានទំហំរហូតដល់ ៥,០០០ដុល្លារអាមេរិក ឬសមមូល និងដែលមិនបានបំពេញលក្ខខណ្ឌដូចក្នុងចំណុចដែលចែងអំពី ការវាតម្លៃឥណទាន អាចអនុញ្ញាតឲ្យផ្តល់ឥណទានទៅតាមលក្ខខណ្ឌ ដូចខាងក្រោមៈ

**ក- ស្វែងរក** Consumer Credit Report **ពីការិយាល័យឥណទាន "កម្ពុជា"**

ភ្នាក់ងារឥណទានទទួលបន្ទុក ត្រូវចូលយកព័ត៌មានឥណទានក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៃការិយាល័យឥណទាន "កម្ពុជា" (Credit Bureau "Cambodia" Co,,Ltd) ដើម្បីផ្ទៀងផ្ទាត់ជាមួយព័ត៌មានដែលទទួលបានពីអតិថិជន។

**ខ- លក្ខខណ្ឌក្នុងការផ្តល់ប្រាក់កម្ចី**

- ចរិតលក្ខណរបស់អ្នកខ្ចី (Character) ៖ អ្នកខ្ចីត្រូវមានប្រវត្តិ កេរ្តិ៍ឈ្មោះ អត្តចរិតល្អ និងមានចេតនាសងបំណុល...។
- មានសមត្ថភាពសងបំណុល ៖ មានចំណូល និងលំហូរសាច់ប្រាក់អាចជឿជាក់បាន ដែលបានមកពីប្រាក់ចំណូលពីមុខរបរផ្ទាល់ខ្លួន ឬចំណូលផ្ទាល់ខ្លួនបូកនឹងចំណីលមិនផ្ទាល់ខ្លួន (កូន ឬសាច់ញាតិផ្ញើមកឲ្យ) ឬចំណូលមិនផ្ទាល់ខ្លួនសុទ្ធសាធ។ ចំណូលមិនផ្ទាល់ខ្លួនសំដៅលើប្រភពចំណូលរបស់អ្នកខ្ចីដែលពឹងផ្អែកលើសមាជិកគ្រួសារ ដូចជាកូន, ប្អូន,

សាច់ញាតិ...ដែលមានមុខរបរ ឬធ្វើការងារនៅក្នុង ឬក្រៅប្រទេស ដែលផ្ញើប្រាក់មកអោយអ្នកខ្ចី។ ភ្នាក់ងារទទួលបន្ទុកត្រូវសិក្សាពីស្ថិរភាពនៃប្រភពសាច់ប្រាក់នោះ និងត្រូវធ្វើឲ្យប្រាកដថាអតិថិជនអាចសងបំណុលត្រឡប់មកវិញទាំងប្រាក់ដើម និងការប្រាក់។

- ភ្នាក់ងារឥណទានទទួលបន្ទុកត្រូវចុះត្រួតពិនិត្យដល់ទីតាំងទ្រព្យ ដោយត្រូវធ្វើឲ្យប្រាកដថាទ្រព្យដាក់ធានាងាយស្រួលលក់ និងមានតម្លៃគ្រប់គ្រាន់ដើម្បីធានាសុវត្ថិភាពឥណទាន។
- អ្នកខ្ចីអាចមានមុខរបរនៅនឹងមូលដ្ឋាន ឬមានមុខរបរឆ្ងាយពីមូលដ្ឋានដែលភ្នាក់ងារឥណទានពុំអាចចុំពិនិត្យមើលដល់ទន្លែងបាន។ ករណីដែលពុំអាចចុះពនិត្យមើលដល់ទិកន្លែងមុខរបរបានដោយមុខរបរនៅឆ្ងាយ ភ្នាក់ងារត្រូវវិភាគពីសមត្ថភាពសង និងលំហូរសាច់ប្រាក់ផ្ទាល់ខ្លួនរបស់អ្នកខ្ចី និងមានការអះអាងច្បាស់លាស់អំពីមុខរបរដែលអាចជឿទុកចិត្តបាន។
- ក្នុងករណីដែលអ្នកខ្ចីមានលទ្ធភាពសង ទ្រព្យដាក់ធានាមានតម្លៃគ្រប់គ្រាន់ និងបានបញ្ជាក់អះអាងច្បាស់លាស់ទទួលស្គាល់កាតព្វកិច្ចបំណុល ប្រាក់កម្ចីអាចងនុញ្ញាតឲ្យអតិថិជនខ្ចីក្នុងគោលបំណងយកទៅប្រើប្រាស់ផ្ទាល់ខ្លួន យកទៅឲ្យកូន ឬសាច់ញាតិ។
- មុខរបរត្រូវស្របច្បាប់ និងមិនស្ថិតក្នុងបញ្ជីអាជីវកម្មដែលត្រូវហាមឃាត (Exclusion List)។

**គ. លក្ខខណ្ឌបន្ថែម**

ករណីដែលព័ត៌មានឥណទានមិនគ្រប់គ្រាន់ អាចតម្រូវឲ្យមានអ្នកធានា និងត្រូវមានការបញ្ជាក់អះអាងពីភ្នាក់ងារឥណទានទទួលបន្ទុកអំពីហេតុផលដែលសមរម្យ ដើម្បីអាចឲ្យថ្នាក់មានសមត្ថកិច្ចមានមូលដ្ឋានក្នុងការសម្រេចចិត្តផ្តល់ឥណទាន។

## ៣.១៥. ភាគីខ្ចីប្រាក់

ភាគីខ្ចីប្រាក់ជាប្តី និងប្រពន្ធ ឬអ្នកស្នងមរតក ឬឪពុក ម្តាយ ត្រូវតែដឹងឮ និងទទួលខុសត្រូវពីការស្នើសុំឥណទានពីធនាគារ អេស៊ីលីដា ភីអិលស៊ី និងយល់ព្រមៈ

- សងបំណុលឲ្យបានទាន់ពេលវេលាតាមកិច្ចសន្យា ដោយមិនឲ្យយឺតយ៉ាវឡើយ។
- សុខចិត្តលក់ទ្រព្យសម្បត្តិរបស់គ្រួសារ ដើម្បីដោះស្រាយបញ្ហាខកខានសងបំណុលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។

## ៣.១៦. ការទទួលខុសត្រូវ និងសិទ្ធិអនុម័តឥណទាន

**ក- នាយក-នាយិកាសាខា "ខ" និងប្រធានភ្នាក់ងារឥណទានសាខា "ក" ធនាគារ មានសិទ្ធិអនុម័តៈ**

- ឥណទានក្រុម ជាប្រាក់រៀល និងប្រាក់បាត
- ឥណទានទោល ដែលមានទំហំរហូតដល់ ៨,០០០ដុល្លារអាមេរិក ឬសមមូល។

ឯកសារឥណទានដែលបញ្ជូនមកដើម្បីអនុម័ត ត្រូវមានសំណើ និងសេចក្តីបញ្ជាក់របស់ភ្នាក់ងារឥណទានទទួលបន្ទុកអតិថិជន។

**ខ- នាយក-នាយិកាសាខា "ក" ធនាគារ អេស៊ីលីដា ភីអិលស៊ី មានសិទ្ធិអនុម័តៈ**

- ឥណទានជាប្រាក់រៀល ដែលមានទំហំរហូតដល់១២០,០០០,០០០រៀល។
- ឥណទានជាប្រាក់បាត ដែលមានទំហំរហូតដល់ ១,២០០,០០០បាត។
- ឥណទានជាប្រាក់ដុល្លារអាមេរិក ដែលមានទំហំរហូតដល់ ៣០,០០០ដុល្លារអាមេរិក។

ឯកសារឥណទានដែលបញ្ជូនមកដើម្បីអនុម័ត ត្រូវមានសំណើ និងសេចក្តីបញ្ជាក់របស់ភ្នាក់ងារឥណទានទទួលបន្ទុកអតិថិជន និងមានសេចក្តីបញ្ជាក់របស់នាយក-នាយិកាសាខា "ខ" ឬប្រធានភ្នាក់ងារឥណទានសាខា "ក"។

- ❖ ករណីយល់ឃើញថា មានភាពមិនប្រក្រតីក្នុងការអនុម័តឥណទាន នាយក-នាយិកាសាខា "ក" ធនាគារ អេស៊ីលីដា ភីអិលស៊ី អាចព្យួរសិទ្ធិអនុម័តឥណទានរបស់នាយក-នាយិកាសាខា "ខ" ឬប្រធានភ្នាក់ងារឥណទានសាខា "ក"។
- ❖ នាយក-នាយិកាសាខា "ក" ធនាគារ អេស៊ីលីដា ភីអិលស៊ី អាចផ្ទេរសិទ្ធិអនុម័តឥណទានបាន។ រាល់ការផ្ទេរសិទ្ធិអនុម័តឥណទាន ធ្វើបានតែនាយក-នាយិកាសាខា "ក"។

## ៣.១៧. ការតាមដាន-ត្រួតពិនិត្យ

### ៣.១៧.១. ដំណើរការត្រួតពិនិត្យ

ដំណើរការត្រួតពិនិត្យ ត្រូវបានកំណត់ដោយចាប់ផ្តើមពីពេលអតិថិជនដាក់ពាក្យសុំចុះឈ្មោះខ្ចីប្រាក់រហូតដល់ប្រាក់សំណងចុងក្រោយត្រូវបានប្រមូល។

កិច្ចការនេះរួមមានៈ

- ការចុះបញ្ជីទទួលពាក្យសុំចុះឈ្មោះខ្ចីប្រាក់របស់អតិថិជន
- ការវាយតម្លៃឥណទាន

- ការបំពេញឯកសារឥណទាន
- ការអនុម័តឥណទាន
- ការរៀបចំកិច្ចសន្យា
- ការបញ្ចេញឥណទាន
- ការរៀបចំទុកដាក់ គ្រប់គ្រងឯកសារ
- ការប្រមូលប្រាក់សំណង និងតាមដានលើប្រាក់សំណង
- ការវិភាគឡើងវិញអំពីស្ថានភាពអ្នកខ្ចី។

### ៣.១៧.២. ប្រព័ន្ធត្រួតពិនិត្យឥណទាន

ប្រព័ន្ធត្រួតពិនិត្យឥណទានត្រូវតែបំពេញភារកិច្ចឲ្យបានល្អិតល្អន់ និងម៉ឺងម៉ាត់ដើម្បីមានលទ្ធភាពគ្រប់គ្រងព្រមទាំងកាត់បន្ថយបានជាងតិបរមានូវហានិភ័យអំពីឥណទាន មិនតែប៉ុណ្ណោះវានឹងផ្តល់អត្ថប្រយោជន៍ដទៃទៀតជាច្រើនក្នុងកិច្ចការធនាគារ។ ម្យ៉ាងទៀតជាការចាំបាច់ដែលត្រូវតែដឹងនូវបម្រែបម្រួលនៃហានិភ័យ ដើម្បីឈានឆ្ពោះទៅចាត់វិធានការទាន់ពេលវេលា និងមានប្រសិទ្ធិភាពក្នុងការងារគ្រប់គ្រងគុណភាពឥណទានរបស់ធនាគារ។

ប្រព័ន្ធត្រួតពិនិត្យឥណទានរួមមាន៖

- ប្រព័ន្ធ MIS (Management Information System)
- គោលនយោបាយ នីតិវិធី និងការណែនាំអំពីឥណទាន
- នាយកដ្ឋានពាក់ព័ន្ធ ៖ នាយកដ្ឋានឥណទាន, នាយកដ្ឋានហិរញ្ញវត្ថុ, ការិយាល័យសវនកម្មឥណទាន, ការិយាល័យគ្រប់គ្រងវិវាទ
- ថ្នាក់មានសមត្ថកិច្ចគ្រប់គ្រងផ្ទាល់ ៖ នាយក-នយិកាសាខា "ក", នាយក-នាយិកាសាខា "ខ", ប្រធានភ្នាក់ងារឥណទានសាខា "ក"។
- ភ្នាក់ងារឥណទាន និងភ្នាក់ងារដោះស្រាយបំណុល (ផ្នែកទី៣: គោលការណ៍ណែនាំស្តីពីប្រព័ន្ធនៃការត្រួតពិនិត្យគុណភាពឥណទាន និងការទទួលខុសត្រូវរបស់ត្រូវរបស់បណ្តាផ្នែកពាក់ព័ន្ធ)។

### ៣.១៧.៣. ការត្រួតពិនិត្យឥណទាន

#### ៣.១៧.៣.១. ការត្រួតពិនិត្យប្រចាំថ្ងៃ

ប្រើប្រាស់ប្រព័ន្ធ MIS តាមដាន ត្រួតពិនិត្យសមតុល្យឥណទាន ដើម្បីគ្រប់គ្រងបរិមាណ និងគុណភាពឥណទានប្រចាំថ្ងៃ។ ភ្នាក់ងារឥណទានត្រូវពិនិត្យរបាយការណ៍សងប្រាក់ប្រចាំថ្ងៃ ចំពោះអតិថិជនដែលខ្លួនកំពុងទទួលខុសត្រូវ។ ភ្នាក់ងារដោះស្រាយបំណុលត្រូវត្រួតពិនិត្យ តាមដានបញ្ជីខកខានសងប្រាក់ធ្ងន់ធ្ងរបំណុលលុបចេញពីបញ្ជី និងការប្រមូលបំណុលប្រចាំថ្ងៃ ចំពោះអតិថិជនដែលខ្លួនទទួលខុសត្រូវ។

#### ៣.១៧.៣.២. ការត្រួតពិនិត្យឥណទាន (Credit Review)

ការត្រួតពិនិត្យឥណទាន អនុវត្តចំពោះតែឥណទានទោល។ រៀងរាល់ប្រាំមួយខែម្តង ភ្នាក់ងារឥណទានត្រូវចុះទៅដល់ទីកន្លែងមុខរបរ និងលំនៅឋានអតិថិជន ដើម្បីត្រួតពិនិត្យដោយកចិត្តទុកដាក់ផ្តោតលើ៖

- ការប្រើប្រាស់ប្រភពទុន សកម្មភាពដំណើរការមុខរបរ និងទំនោរនៃមុខរបរ
- ស្ថានភាពហិរញ្ញវត្ថុ
- ស្ថានភាពទ្រព្យធានា ដូចជាការប្រែប្រួលតម្លៃ ទំហំ ឬភាពមិនប្រក្រតីចំពោះកម្មសិទ្ធិប្រភេទទ្រព្យសម្បត្តិ។

ការត្រួតពិនិត្យឥណទាននេះ ភ្នាកងារឥណទានទទួលខុសត្រូវរៀបចំរបាយការណ៍រក្សាទុកក្នុងសំណុំឯកសារឥណទានរបស់អតិថិជន (Client File)។ នាយកប្រតិបត្តិឥណទានជាអ្នកកំណត់ទំហំឥណទានសម្រាប់ធ្វើការត្រួតពិនិត្យឥណទាន (Credit Review) ដោយផ្អែកលើការវាយតម្លៃកម្រិតហានិភ័យ។

## ៣.១៨. ការធ្វើចំណាត់ថ្នាក់ឥណទាន ឥណទានរៀបចំឡើងវិញ និងការធ្វើសំវិធានធន

### ក. ការធ្វើចំណាត់ថ្នាក់ឥណទាន (Loan Classification)

គ្រប់ប្រភេទឥណទានទាំងអស់របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើសមត្ថភាពសងរបស់អ្នកខ្ចី។ សមត្ថភាបសងនេះត្រូវបានវាយតម្លៃតាមរយៈលក្ខណវិនិច្ឆ័យ ដូចខាងក្រោម៖

- ប្រវត្តិនៃការទុទាត់សង
- ស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីនាពេលបច្ចុប្បន្ន និងនៅពេលអនាគត

- គម្រោងលំហូរសាច់ប្រាក់ និងអាជីវកម្មសម្រាប់អនាគតដែលផ្អែកលើសម្មតិកម្មជាក់ស្តែង និងប្រុងប្រយ័ត្ន
- លទ្ធភាព និងឆន្ទៈក្នុងការសងត្រឡប់មកវិញរបស់អ្នកខ្ចី
- បរិស្ថានហិរញ្ញវត្ថុ និង
- គុណភាពនៃការរៀបចំឯកសារ។

ករណីប្រភពដំបូងនៃការទូទាត់សង មិនអាចធានាបានចំពោះការទូទាត់សងឥណទាន អាចត្រូវអាចត្រូវបានធ្វើចំណាត់ថ្នាក់ជាឥណទានឃ្លាំមើល ឬមិនដំណើរការ ទោះបីជាឥណទាននោះមានលក្ខណៈចរន្ត ឬអាចនឹងត្រូវទូទាត់ដោយវត្ថុធានាក៏ដោយ។ ការធ្វើចំណាត់ថ្នាក់ឥណទានឡើងវិញក៏អាចធ្វើផងដែរ ប្រសិនបើអ្នកខ្ចីមិនអាចបំពេញតាមលក្ខខណ្ឌដើមនៃការទូទាត់សង ឬបើឥណទានមិនដំណើរការនោះ ត្រូវបានដោះស្រាយដោយបច្ចេកទេសនៃការផ្លាស់ប្តូរលក្ខខណ្ឌ បុនហិរញ្ញប្បទាន ឬបុរេប្រទានបន្ថែម (Refinancing or Additional Advance)។ ក្នុងករណីដែលការធ្វើចំណាត់ថ្នាក់នីមួយៗ នៃឥណទានផ្អែកលើលក្ខណវិនិច្ឆ័យមិនច្បាស់លាស់ ការធ្វើចំណាត់ថ្នាក់ដ៏តឹងរ៉ឹងជាងនេះត្រូវតែអនុវត្ត។ ករណីដែលការវិភាគស្ថានភាពហិរញ្ញវត្ថុ សមត្ថភាព និងឆន្ទៈសងត្រឡប់មកវិញរបស់អ្នកខ្ចីបានបង្ហាញឲ្យឃើញថាមានស្ថានភាពធ្ងន់ធ្ងរនោះ ចំណាត់ថ្នាក់ឥណទានត្រូវធ្វើឡើងឲ្យកាន់តែមានភាពតឹងរ៉ឹងបន្ថែមទៀត។

**តារាងទី៣.២ ចំណាត់ថ្នាក់ឥណទានត្រូវចែកជា ៥ ប្រភេទដូចខាងក្រោម៖**

| ចំណាត់ថ្នាក់ និងលក្ខណវិនិច្ឆ័យ | ដំណើរការសងប្រាក់ |
|---|---|
| **១- ធម្មតា** (Normal)<br>- ទ្រព្យសកម្មប្រភេទនេះត្រូវបានធានាទាំងស្រុងដោយទ្រព្យសម្បត្តិ និងសមត្ថភាពទូទាត់សងរបស់អ្នកខ្ចីនាពេលបច្ចុប្បន្ន និងជាទ្រព្យសកម្មកំពុងដំណើរការ ដោយងនុលោមទៅតាមកិច្ចសន្យានិងរំពឹងថានៅតែបន្តដំណើរការបែបនេះរហូតតទៅ។ | - ទៀងទាត់ និង<br>- ហួសកាលកំណត់សងតិចជាង ៣០ថ្ងៃ |
| **២- ឃ្លាំមើល** (Special Mention)<br>- ទ្រព្យសកម្មប្រភេទនេះនឹងត្រូវបានធានា ប៉ុន្តែមានចំនុចខ្សោយខ្លះដែលជាសក្តានុពលនឹងធ្វើឲ្យគុណភាពទ្រព្យសកម្មចុះខ្សោយ ឬនាំឲ្យស្ថានភាពធនាគារមិនត្រូវបានការពារនៅពេលណាមួយខាងមុខបើចំនុចខ្សោយទាំងនោះ មិនត្រូវបានកែតម្រូវ | - ឥណទានវិបារូបត្រូវចាត់ថ្នាក់ "ឃ្លាំមើល" ប្រសិនបើប្រើលើស កម្រិតអនុម័តច្រើនជាង ៣០ថ្ងៃ ប៉ុន្តែតិចជាង៩០ថ្ងៃ ឬប្រសិនបើគណនីចរន្ត មិនមានសកម្មភាពរយៈពេល៣០ថ្ងៃ ឬប្រាក់បញ្ញើនៅក្នុងគណនីនោះមិនគ្រប់គ្រាន់ |

ទេនោះឧទាហរណ៍ខ្លះៗនៃ ចំ ណុចខ្សោយទាំងនោះ រួមមានភាពគ្មានលទ្ធភាពត្រួតពិនិត្យឲ្យបានសមស្របដោយ សារតែកិច្ចសន្យាខ្ចីប្រាក់មានចន្លោះប្រហោង ភាពអន់ថយនៃស្ថានភាព ឬការគ្រប់គ្រងវត្ថុធានា ការធ្លាក់ចុះនៃស្ថានភាពសេដ្ឋកិច្ច ឬនិន្នាការចុះខ្សោយនៃស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីហើយ បើមិនបានត្រួតពិនិត្យទេនឹងនាំឲ្យខូចខាតដល់ស្ថានភាពទូទាត់សង រួមទាំងហានិភ័យដែលអាចកើតមានឡើង ធំជាងហានិភ័យដែលបានគិតនាពេលចាប់ផ្តើមផ្តល់ឥណទាន។ ឥណទានប្រភេទនេះ មិនគួរប្រើប្រាស់ជាការសម្របសម្រួលនៅពេលចាត់ថ្នាក់ឥណទានធម្មតា និងឥណទានក្រោមស្តង់ដារទេ។

សម្រាប់ទូទាត់ការប្រាក់ បញ្ចូលជាប្រាក់ដើមនៅក្នុងគ្រាប្រើប្រាស់ឥណទាន។

- ឥណទាន ដែលហួសកាលកំណត់សងចំនួន ៣០ថ្ងៃ ឬលើសពីនេះ ប៉ុន្តែតិចជាង៩០ថ្ងៃត្រូវចាត់ថ្នាក់ជាឥណទានឃ្លាំមើលឬអន់ជាងនេះ។
- នៅពេល ដែលការទូទាត់សងការប្រាក់សម្រាប់រយៈពេល ៣០ថ្ងៃ ទៅ៩០ថ្ងៃត្រូវបានបញ្ចូលទៅជាប្រាក់ដើម ធ្វើបុនហិរញ្ញប្បទាន ឬបង្វិលជាឥណទានថ្មី (Rolled over loans) ឥណទាននេះត្រូវចាត់ថ្នាក់ជាឥណទានឃ្លាំមើល ឬអន់ជាងនេះ។

**៣-ក្រោមស្តង់ដារ** (Sub-Standard)

- ទ្រព្យសកម្មប្រភេទនេះ មិនត្រូវបានការពារគ្រប់គ្រាន់ដោយទ្រព្យសម្បត្តិ និងសមត្ថភាពសងបំណុលរបស់អ្នកខ្ចីឡើយ។ ជាពិសេសប្រភពធនធានចម្បងសម្រាប់សងបំណុលមានមិនគ្រប់គ្រាន់ ដើម្បីសងបំណុលដែលធនាគារត្រូវតែសម្លឹងមើលទៅប្រភពធនធានបន្ទាប់ដូចជាវត្ថុធានាការលក់អចលនទ្រព្យ បុនហិរញ្ញប្បទាន ឬក៏ការបំពេញទុនបន្ថែមសម្រាប់ទូទាត់បំណុល។ ឥណទានក្រោមស្តង់ដារបានបង្ហាញយ៉ាងច្បាស់ នូវចំណុចខ្សោយដែលធ្វើឲ្យប៉ះពាល់ដល់ការទូទាត់សងបំណុលត្រឹមត្រូវតាមលំដាប់លំដោយ។
- ឥណទានវិបារូបត្រូវចាត់ថ្នាក់ "ក្រោមស្តង់ដារ" ប្រសិនបើប្រើលើសកម្រិតអនុម័តច្រើនជាង ៩០ ថ្ងៃឬឥណទានវិបារូបដែលមានចំនួនទឹកប្រាក់តិចតួច នៅខ្វង់ឥណទានក្នុងរយៈពេល ៩០ ថ្ងៃឬលើសពីនេះ ឬប្រសិនបើ គណនីចរន្តមិនមានសកម្មភាពរយៈពេល ៩០ ថ្ងៃ ឬប្រាក់បញ្ញើនៅក្នុងគណនីនោះមិនគ្រប់គ្រាន់ សម្រាប់ទូទាត់ការប្រាក់បញ្ចូលជាប្រាក់ដើម នៅក្នុងគ្រាប្រើប្រាស់ឥណទាន។
- ឥណទាន ដែលហួសកាលកំណត់សងចំនួន ៩០ ថ្ងៃ ឬលើសពីនេះ ប៉ុន្តែតិចជាង២៨០ថ្ងៃត្រូវចាត់ថ្នាក់យ៉ាងទាបបំផុតក្រោមស្តង់ដារ។
- នៅពេលដែលទូទាត់សងការប្រាក់ សម្រាប់រយៈពេលពី ៩០ថ្ងៃត្រូវបានបញ្ចូលទៅជាប្រាក់ដើម ធ្វើបុនហិរញ្ញប្បទាន ឬបង្វិលជាឥណទានថ្មី (Rolled over loans) ឥណទាននេះ ត្រូវចាត់ថ្នាក់ជាឥណទានក្រោមស្តង់ដារ ឬអន់ជាងនេះ។

៤-សង្ស័យ (Doubtful)

- ទ្រព្យសកម្ម ប្រភេទនេះមានចំណុចខ្សោយដូចឥណទានក្រោមស្តង់ដារ ដោយបូកបន្ថែមលក្ខខណ្ឌដែលឥណទាន មិនមានការធានាបានល្អ ។ យោងតាមហេតុការណ៍ជាក់ស្តែងស្ថានភាព និងតម្លៃចំនុចខ្សោយទាំងនោះ បាននាំឲ្យមានការសង្ស័យថា ឥណទានមិនអាចប្រមូលបានមកវិញទាំងស្រុងទេ។ លទ្ធភាពបាត់បង់មានកម្រិតខ្ពស់ ប៉ុន្តែដោយសារតែមានការរង់ចាំលើព្រឹត្តិការណ៍ជាក់លាក់ និងសមស្របណាមួយដែល នឹងកាត់បន្ថយកម្រិតបាត់បង់នោះ បរិមាណពិតប្រាកដនៃបំណុលដែលត្រូវបាត់បង់ មិនអាចកំណត់បានទាំងស្រុង។ បើព្រឹត្តិការណ៍ដែលរង់ចាំនោះមិនបានកើតឡើងក្នុងរយៈពេល ១៨០ ថ្ងៃ ហើយការទូទាត់សងត្រូវបានពន្យាពេលបន្ថែមទៀតនោះ ការចាត់ថ្នាក់ទៅជាឥណទានបាត់បង់ ត្រូវតែអនុវត្ត។
- ឥណទានវិបារូបវ័ត្រូវចាត់ថ្នាក់ "សង្ស័យ" ប្រសិនបើ ប្រើលើសកម្រិតអនុម័តច្រើនជាង ១៨០ថ្ងៃ ឬឥណទានវិបារូបវ័ដែលមានចំនួនទឹកប្រាក់តិចតួច នៅខ្វង់ឥណទានក្នុងរយៈពេល ១៨០ថ្ងៃ ឬលើសពីនេះ ឬប្រសិនបើគណនីចរន្តមិនមានសកម្មភាពរយៈពេល១៨០ថ្ងៃ ឬ ប្រាក់បញ្ញើនៅក្នុងគណនីនោះមិនគ្រប់គ្រាន់ សម្រាប់ទូទាត់ការប្រាក់បញ្ចូលជាប្រាក់ដើម នៅក្នុងគ្រាប្រើប្រាស់ឥណទាន។
- ឥណទាន ដែលហួសកាលកំណត់សងចំនួន ១៨០ថ្ងៃ ឬលើសពីនេះត្រូវចាត់ថ្នាក់យ៉ាងទាបបំផុតជាបំណុលសង្ស័យ ឬអន់ជាងនេះ។
- នៅពេល ដែលការទូទាត់សងការប្រាក់ សម្រាប់រយៈពេលពី១៨០ថ្ងៃ ទៅ៣៦០ថ្ងៃ ត្រូវបានបញ្ចូលទៅជាប្រាក់ដើម ធ្វើហិរញ្ញប្បទាន ឬបង្វិលជាឥណទានថ្មី (Rolled over loans) ឥណទាននេះត្រូវចាត់ថ្នាក់ជាឥណទានសង្ស័យ ឬអន់ជាងនេះ។

៥-បាត់បង់ (Loss)

- ទ្រព្យសកម្មទាំងឡាយណាដែលត្រូវបានចាត់ទុកថាមិនអាចប្រមូលមកវិញបាន ឬនៅនៅមានតម្លៃតិចតួច ត្រូវចាត់ថ្នាក់ជាបំណុលបាត់បង់។ ការខាតបង់ត្រូវទទួលស្គាល់ក្នុងអំឡុងពេលដែល ឥណទានទាំងនោះត្រូវបានរកឃើញថាមិនអាចប្រមូលបាន។
- ឥណទានវិបារូបវ័ត្រូវចាត់ថ្នាក់ "បាត់បង់" ប្រសិនបើ ប្រើលើសកម្រិតអនុម័តច្រើនជាង ៣៦០ថ្ងៃ ឬឥណទានវិបារូបវ័ដែលមានចំនួនទឹកប្រាក់តិចតួច នៅខ្វង់ឥណទានក្នុងរយៈពេល ៣៦០ថ្ងៃ ឬលើសពីនេះ ឬប្រសិនបើគណនីចរន្តមិនមានសកម្មភាពរយៈពេល៣៦០ថ្ងៃ ឬប្រាក់បញ្ញើនៅក្នុងគណនីនោះមិនគ្រប់គ្រាន់ សម្រាប់ទូទាត់ការប្រាក់បញ្ចូលជាប្រាក់ដើម នៅក្នុងគ្រាប្រើប្រាស់ឥណទាន។
- ឥណទាន ដែលហួសកាលកំណត់សងចំនួន ៣៦០ថ្ងៃ ឬលើសពីនេះត្រូវចាត់ថ្នាក់ជាឥណទានបាត់បង់។
- នៅពេល ដែលការទូទាត់សងការប្រាក់ សម្រាប់រយៈពេល៣៦០ថ្ងៃ ឬលើសពីនេះត្រូវបានបញ្ចូលទៅជាប្រាក់ដើម ធ្វើហិរញ្ញប្បទាន ឬ

បង្វិលជាឥណទានថ្មី (Rolled over loans) ឥណទាននេះត្រូវចាត់ថ្នាក់ជាឥណទានបាត់បង់។

**កំណត់សម្គាល់**

- ឥណទានវិបារូបរ៍ ទោះជាជាមានរយៈប្រសិទ្ធភាពយ៉ាងណាក៏ដោយ ត្រូវតែបានប្រើប្រាស់សម្រាប់ហិរញ្ញប្បទានរយៈពេលខ្លីតែប៉ុណ្ណោះ។ ឥណទានវិបារូបរ៍ត្រូវទៅធ្វើចំណាត់ថ្នាក់ជាឥណទានរយៈពេលខ្លី។
- បើធនាគារផ្តល់ឥណទានច្រើនប្រភេទទៅអ្នកខ្ចីម្នាក់ ឬមួយក្រុម ប្រសិនបើមានឥណទានមួយត្រូវបានធ្វើចំណាត់ថ្នាក់ជាឥណទានមិនដំណើរការ ធនាគារត្រូវវាយតម្លៃឡើងវិញនូវឥណទានផ្សេងទៀតដែលបានផ្តល់ទៅអតិថិជននោះ និងត្រូវធ្វើចំណាត់ថ្នាក់ឥណទានទាំងនោះទៅក្នុងប្រភេទដូចគ្នានឹងឥណទានដែលបានធ្វើចំណាត់ថ្នាក់រួចហើយ។ ការធ្វើចំណាត់ថ្នាក់នេះត្រូវគិតបញ្ចូលទាំងកិច្ចសន្យាក្នុងខ្ទង់ក្រៅតារាតុល្យការ លើកលែងតែកិច្ចសន្យានោះមិនតម្រូវឲ្យធនាគារទូទាត់សងប្រាក់។ ប៉ុន្តែផលប័ត្រពាណិជ្ជកម្មរួមទាំងលិខិតឥណទានដែលបានទទួលធ្វើស្វីការដោយបបហារិត ហើយការទូទាត់សងបានទៀងទាត់ និងត្រឹមត្រូវ អាចរក្សាចំណាត់ថ្នាក់ធម្មតាបាន។

**ខ. ឥណទានរៀបចំឡើងវិញ** (Restructured Loans)

- ការរៀបចំឥណទានឡើងវិញ អាចត្រូវបានធ្វើចំពោះតែអ្នកខ្ចីណាដែលមានដំណើរការអាជីវកម្មល្អនាពេលខាងមុខ ហើយដែលកំពុងជួប ឬរំពឹងថានឹងជួបការលំបាកជាបណ្តោះអាសន្នក្នុងការសងត្រឡប់វិញនូវប្រាក់ដើម និងការប្រាក់។
- ត្រូវបានហាមឃាតចំពោះការអនុវត្តរៀបចំឥណទានឡើងវិញ ដោយគ្រាន់តែក្នុងគោលបំណងចៀសវាង៖
  - ការធ្លាក់ចំណាត់ថ្នាក់របស់ខ្លួនព្រោះតែចំណាត់ថ្នាក់ឥណទាន ឬ
  - ការកើនឡើងនូវសំវិធានធនលើឥណទានបាត់បង់ ឬ
  - បញ្ឈប់ការទទួលស្គាល់ចំណូលការប្រាក់លើមូលដ្ឋានបង្គរ។
- ឥណទានដែលនឹងត្រូវរៀបចំឡើងវិញត្រូវវិភាគលើមូលដ្ឋានទិសដៅអាជីកម្ម និងសមត្ថភាពសងប្រាក់ត្រឡប់វិញរបស់អ្នកខ្ចីទៅតាមការព្យាករណ៍លំហូរសាច់ប្រាក់ថ្មី ដែលស្របតាមស្ថាន

ភាពទីផ្សារ និងបច្ចុប្បន្នកម្មនៃទស្សនៈវិស័យអាជីវកម្ម ដោយផ្អែកលើសម្មតិកម្មជាក់ស្តែង និងប្រុងប្រយ័ត្ន។

- ការរៀបចំឥណទានឡើងវិញត្រូវធ្វើឡើងដោយក្រុមការងារឯករាជ្យមួយដាច់ដោយឡែកពីសាខាដែលពាក់ព័ន្ធនិងការផ្តល់ឥណទាន។
- បន្ទាប់ពីឥណទានត្រូវបានរៀបចំឡើងវិញ ធនាគារត្រូវធ្វើចំណាត់ថ្នាក់ឥណទាននោះ ដូចខាងក្រោម៖
  - មិនល្អជាងក្រោមស្តង់ដារ សម្រាប់ឥណទានដែលពីមុនមកត្រូវបានចាត់ថ្នាក់ជាឥណទានសង្ស័យ ឬបាត់បង់
  - មិនផ្លាស់ប្តូរសម្រាប់ឥណទានដែលពីមុនមកត្រូវបានចាត់ថ្នាក់ជាឥណទានធម្មតា ឃ្លាំមើលឬក្រោមស្តង់ដារ។

ការធ្វើចំណាត់ថ្នាក់នេះមិនត្រូវឲ្យល្អជាងមុនឡើយ លុះត្រាតែការប្រាក់ និងប្រាក់ដើមត្រូវបានសងមកវិញក្នុងកំឡុងបីគ្រាសងរំលស់ និងក្នុងរយៈពេលមិនតិចជាង៣ខែ។ បន្ទាប់ពីរយៈពេលនេះឥណទានដែលត្រូវបានរៀបចំឡើងវិញ អាចត្រូវបានចាត់ថ្នាក់ទៅតាមប្រភេទចំណាត់ថ្នាក់ឥណទាន។

**គ. ការធ្វើសំវិធានធន** (Provisioning)

ធនាគារត្រូវរក្សាសំវិធានធនសម្រាប់ឥណទានបាត់បង់ឲ្យបានគ្រប់គ្រាន់ ដើម្បីទូទាត់ការខាតបង់ក្នុងសម្ពាធឥណទានដែលអាចកើតឡើង។ សំវិធានធនមានពីរប្រភេទគឺ សំវិធានធនទូទៅ និងសំវិធានធនជាក់លាក់។

សំវិធានធនសរុប=សំវិធានធនទូទៅ+សំវិធានធនជាក់លាក់

១-សំវិធានធនទូទៅ (General Provision)

- សម្រាប់ឥណទានថ្នាក់ "ធម្មតា" (Normal): ១%នៃឥណទានដុល។

២-សំវិធានធនជាក់លាក់ (Specific Provision)

- សម្រាប់ឥណទានថ្នាក់ "ឃ្លាំមើល" (Special Mention): ៣%នៃឥណទានដុល
- សម្រាប់ឥណទានថ្នាក់ "ក្រោមស្តង់ដារ" (Sub-Standard): ២០%នៃឥណទានដុល
- សម្រាប់ឥណទានថ្នាក់ "សង្ស័យ" (Doubtful): ៥០%នៃឥណទានដុល
- សម្រាប់ឥណទានថ្នាក់ "បាត់បង់" (Loss): ១០០%នៃឥណទានដុល។

- ធនាគារត្រូវសក្សាការកត់ត្រាឲ្យបានត្រឹមត្រូវ ដើម្បីជាការគាំទ្រដល់ការវាយតម្លៃឥណទានដែលអាចបាត់បង់ និងធ្វើសំវិធានធនឲ្យបានគ្រប់គ្រាន់សម្រាប់ឥណទានបាត់បង់។
- សំវិធានធនជាក់លាក់ (Specific Provision) ត្រូវកត់ត្រានៅក្នុងគណនីរបស់ធនាគារ ហើយចាត់ទុកជាចំណាយនៅក្នុងរបាយការណ៍ចំណេញ-ខាត នៅក្នុងគ្រាដែលត្រូវធ្វើសំវិធានធននោះ។ សំវធានធនមិនត្រូវធ្វើរំលស់នៅតាមគ្រានោះទេ។ នៅពេលណាដែលសមតុល្យគណនីរបស់អតិថិជនមានបញ្ចូលមូលធនកម្មការប្រាក់ (Capitalized Interest) ដែលបានកត់ត្រាបដិភាគជាមួយការប្រាក់ព្យូរទុកមូលធនកម្មការប្រាក់នេះ មិនត្រូវយកមកគិតសម្រាប់គណនីសំវិធានធនទេ។

**<u>ការគិតការប្រាក់បង្គរដែលនឹងត្រូវទទួល</u>**

ស្របតាមមូលដ្ឋានបង្គរនៃណនេយ្យ (Accrual Basis Accounting) ការប្រាក់បង្គរលើគណនីអតិថិជនត្រូវបានកត់ត្រាជាចំណូលក្នុងគណនីចំណេញ-ខាត។ ប៉ុន្តែមិនត្រូវធនុវត្តតាមទម្រង់ការបែបនេះទេ ចំពោះទ្រព្យសកម្មទាំងឡាយណាដែលត្រូវបានចាត់ថ្នាក់ជាបំណុលក្រោមស្តងដារ បំណុលសង្ស័យ ឬបំណុលបាត់បង់។ ក្នុងស្ថានភាពនេះ ការប្រាក់បង្គរត្រូវកត់ត្រាខាងឥណទាននៃគណនីសម្រាប់ការប្រាក់ព្យូរ។

## ៣.១៩. ផ្សេងៗ

គុណភាពឥណទាន ត្រូវវាស់វែងដោយត្រាហានិភ័យនៃឥណទាន (%PAR) និងអត្រានៃការសងមកវិញនៃឥណទាន។

### ក-អត្រាហានិភ័យឥណទាន

អត្រាហានិភ័យឥណទាន (PAR) ត្រូវវាបានគណនាតាមរូបមន្តដូចខាងក្រោម៖

$$\mathbf{PAR} = \frac{\text{សមតុល្យឥណទានដែលខកខានមិនបានសងតាមកិច្ចសន្យា(ប្រាក់ដើម)}}{\text{សមតុល្យឥណទានសរុប(ប្រាក់ដើម)}} \times \mathbf{100}$$

ការកំណត់បទដ្ឋានហានិភ័យ សម្រាប់វាយតម្លៃគុណភាពឥណទាន ដូចខាងក្រោម៖

- PAR រហូតដល់ ១%: ការអនុវត្ត ត្រូវបានចាត់ទុកថាល្អណាស់
- PAR ធំជាង ១% រហូតដល់ ២%: ការអនុវត្ត ត្រូវបានចាត់ទុកថាល្អ
- PAR ធំជាង ២% រហូតដល់ ៣%: ការអនុវត្ត ត្រូវបានចាត់ទុកថាមធ្យម

- PAR ធំជាង ៣% រហូតដល់ ៥%: ការអនុវត្ត ត្រូវបានចាត់ទុកថានៅមានការខ្វះខាត ត្រូវកែលម្អ
- PAR ធំជាង ១% រហូតដល់ ២%: ការអនុវត្ត ត្រូវបានចាត់ទុកថាល្អ
- PAR ធំជាង ៥%: ការអនុវត្ត ត្រូវបានចាត់ទុកថាខ្សោយ ត្រូវមានវិធានការ។

**ខ-អត្រានៃការសងមកវិញ**

ឥណទានដែលខកខានមិនបានសងតាមកិច្ចសន្យា ត្រូវបានវាស់វែងគុណភាពនៃការសងត្រឡប់មកវិញតាមអត្រា ដូចបានគណនាដោយប្រើរូបមន្តៈ

$$\text{អត្រានៃការសងមកវិញ} = \frac{\text{សរុបទឹកប្រាក់ដែលត្រូវសងហើយបានសង(ឥណទានសកម្ម)}}{\text{សរុបទឹកប្រាក់ដែលត្រូវសង(ឥណទានសកម្ម)}} \times \mathbf{100}$$

**គ-បំណុលលុបចេញពីបញ្ជី** (Write Off)

បំណុលបាត់បង់ (Loss) ដែលបានធ្វើសំវិធានធនជាក់លាក់ ១០០%នឹងត្រូវបានលុបចេញពីបញ្ជី (Write Off) ដោយស្វ័យប្រវត្តិ បន្ទាប់ពីហួសរយៈពេល ៣៦០ថ្ងៃ នៃកាលបរិច្ឆេទសងប្រាក់ចុងបញ្ចប់ (After 360 Days Past Final Repayment Due Date)។

ទោះជាយ៉ាងណា បំណុលអាចត្រូវបានលុបចេញពីបញ្ជី ក្រោមការវិនិច្ឆ័យរបស់នាយកប្តិបត្តិឥណទានក្នុងករណីដែលធនាគារបាត់សិទ្ធិតាមកិច្ចសន្យាលើការគ្រប់គ្រងឥណទាន ឬពេលដែលរកឃើញថា ឥណទានមួយផ្នែក ឬទាំងមូល មិនអាចប្រមូលវិញបាន ឬគ្មានសង្ឃឹមថាឥណទាននេះ អាចប្រមូលបានមកវិញទេ។

ជាទូទៅករណីដូចខាងក្រោមជាសញ្ញាណអាចនាំទៅដល់ការលុបចោលនូវឥណទាន ឬមួយផ្នែកនៃឥណទានៈ

- ធនាគារបាត់សិទ្ធិតាមកិច្ចសន្យាក្នុងការគ្រប់គ្រងឥណទានទាំងស្រុង ឬមួយផ្នែក ដូចដែលបានសម្រេចដោយតុលាការ។
- គ្រប់ប្រភេទនៃទ្រព្យធានាដែលត្រូវបានរឹមអូស និងលក់បញ្ចេញ ប៉ុន្តែមិនគ្រប់គ្រាន់សម្រាប់ទូទាត់សងឥណទានទាំងមូល។
- ធនាគារមិនអាចប្រមូល ឬលែងមានមូលហេតុសមស្របក្នុងការធានាថានឹងប្រមូលឥណទានគ្រប់ចំនួនដែលត្រូវទារ ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាឥណទាន និងបុរេប្រទាន។

- អ្នកខ្ចីប្រាក់បានក្ស័យធន ឬកំពុងតែស្ថិតនៅក្នុងដំណាក់កាលស្តារនីតិសម្បទាផ្នែកហិរញ្ញវត្ថុ និងកំពុងតែជួបការលំបាកក្នុងការសងបំណុល។

អត្រាបំណុលលុបចេញពីបញ្ជី ត្រូវបានគណនាតាមរូបមន្ត ដូចខាងក្រោម៖

$$\text{អត្រាបំណុលលុបចេញពីបញ្ជី} = \frac{\text{សរុបបំណុលលុបចេញក្នុងគ្រា} - \text{ប្រមូលបំណុលចេញពីបញ្ជីក្នុងគ្រា}}{\text{សមតុល្យមធ្យមនៃឥណទានក្នុងគ្រា}} \times \mathbf{100}$$

ការកំណត់បទដ្ឋានវាយតម្លៃគុណភាពបំណុលលុបចេញពីបញ្ជី ដូចខាងក្រោម៖

- អត្រាស្មើ ០% ត្រូវបានចាត់ទុកថា អនុវត្តបានល្អណាស់
- អត្រាធមជាង ០% រហូតដល់១% ត្រូវបានចាត់ទុកថា អនុវត្តបានល្អ
- អត្រាធមជាង ១% រហូតដល់១.៥% ត្រូវបានចាត់ទុកថា អនុវត្តបានមធ្យម
- អត្រាធមជាង ១.៥% រហូតដល់២% ត្រូវបានចាត់ទុកថា អនុវត្តនៅមានការខ្វះខាតត្រូវកែលម្អ
- អត្រាធំជាង ២% ត្រូវបានចាត់ទុកថា អនុវត្តអន់ខ្សោយ ត្រូវមានវិធានការ។

## ៣.២០. ដំណើរការនៃការផ្តល់ឥណទានខ្នាតតូច

ដំណើរការនៃការផ្តល់ឥណទានសម្រាប់អាជីវកម្មខ្នាតតូចរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខ ត្រូវបានធ្វើឡើងជាប្រាំបីដំណាក់កាលគឺ៖

**១-ការដាក់ពាក្យសុំចុះឈ្មោះខ្ចីប្រាក់**

- អ្នកដាក់ពាក្យសុំខ្ចីប្រាក់មកជួបភ្នាក់ងារបម្រើអតិថិជននៅការិយាល័យធនាគារ
- ភ្នាក់ងារបម្រើអតិថិជនពន្យល់ពីគោលការណ៍ នីតិវិធីឥណទាន និងលក្ខណៈរួមស្តីការខ្ចីឲ្យបានច្បាស់លាស់ទៅកាន់អ្នកខ្ចី (ទំហំឥណទាន របៀបសង អត្រាការប្រាក់ អ្នកធានា ប្តីប្រពន្ធ)។
- ភ្នាក់ងារបម្រើអតិថិជនផ្តល់ពាក្យសុំចុះឈ្មោះខ្ចីទៅឲ្យអតិថិជន និងជម្រាបជូនអំពីលិខិតស្នាមចាំបាច់ដែលជាតម្រូវការរបស់ធនាគារ។
- ភ្នាក់ងារបម្រើអតិថិជនត្រូវជួយបំពេញរាល់ចំណុចខ្វះខាតនៅលើពាក្យសុំខ្ចី។
- ក្រោយទទួលពាក្យសុំចុះឈ្មោះខ្ចីប្រាក់ដែលមានការបំពេញត្រឹមត្រូវដោយអតិថិជន ភ្នាក់ងារបម្រើអតិថិជនយកឯកសារដែលបានពិនិត្យនោះ ដាក់ក្នុងប្រអប់ឯកសាររបស់

ភ្នាក់ងារណទានទទួលខុសត្រូវ។ អ្នកសុំខ្ចីប្រាក់ក៏អាចទំនាក់ទំនងដាក់ពាក្យនៅ មូលដ្ឋាន ក្នុងពេលដែលភ្នាក់ងារឥណទានបានចុះធ្វើការងារ។

**២-ការចុះទៅពិនិត្យដល់ផ្ទះអតិថិជន និងការវាយតម្លៃឥណទាន**

- ក្រោយពីទទួលបានពាក្យសុំខ្ចីប្រាក់ ភ្នាក់ងារឥណទានចុះទៅជួបអតិថិជនដល់ផ្ទះ ដើម្បីសាកសួរព័ត៌មានអំពីតម្រូវការខ្ចីប្រាក់។
- ភ្នាក់ងារឥណទានសាកសួរប្រមូលព័ត៌មានដែលទាក់ទងនឹង ព័ត៌មានទូទៅ ព័ត៌មានហិរញ្ញវត្ថុ គោលបំណង និងតម្រូវការនៃការប្រើប្រាស់កម្ចី ព័ត៌មានអំពីទ្រព្យដាក់ធានា និងកត្តាទាំងឡាយដែលអាចជះឥទ្ធិពលបង្កហានិភ័យ។
- ភ្នាក់ងារឥណទានធ្វើការត្រិះរិះពិចារណា សិក្សា វិភាគ និងវាយតម្លៃព័ត៌មានដែលប្រមូលបានទាំងនោះ ថាតើពិតជាត្រឹមត្រូវសម្រាប់ធ្វើការវាយតម្លៃតម្រូវការឥណទានហើយឬនៅ?
- ក្រោយពីបានធ្វើការវាយតម្លៃលទ្ធភាពរបស់អ្នកខ្ចីប្រាក់រួចមក ភ្នាក់ងារឥណទានត្រូវបានបញ្ជាក់ជូនអតិថិជនអំពីលទ្ធភាពដែលអាចទទួលឥណទានបាន។

**៣-ការផ្ទៀងផ្ទាត់ព័ត៌មាន**

- ការផ្ទៀងផ្ទាត់ព័ត៌មានដែលទទួលបានពេលចុះវាយតម្លៃ នឹងព័ត៌មានដែលទទួលបានពីការិយាល័យឥណទាន "កម្ពុជា"។
- ព័ត៌មាន ឬរបាយការណ៍ឥណទានដែទទួលបានពីការិយាល័យឥណទាន "កម្ពុជា" ត្រូវចាត់ចែងប្រគល់ឲ្យភ្នាក់ងារ និងថ្នាក់មានសមត្ថកិច្ចដែលពាក់ព័ន្ធដើម្បីយកទៅសិក្សាវិភាគអំពីហានិភ័យ និងភាពដែលអាចជឿជាក់បានរបស់អតិថិជន មុននិងធ្វើការសម្រេចចិត្តផ្តល់ឥណទាន។

**៤-ការរៀបចំឯកសារឥណទាន**

- បន្ទាប់ពីអតិថិជនមានការព្រមព្រៀង ភ្នាក់ងារឥណទានរៀបចំឯកសារសម្រាប់អតិថិជនខ្ចីប្រាក់ ក្នុងនោះមានគម្រោងជំនួយ និងពាក្យសុំខ្ចីប្រាក់។
- ភ្នាក់ងារឥណទានត្រូវសសេរយោបល់ និងសំណើដោយបញ្ជាក់ពីទំហំឥណទានរយៈខ្ចី និងអត្រាការប្រាក់ដើម្បីដាក់ស្នើសុំការអនុម័ត។

**៥-ការអនុម័តឥណទាន**

- ភ្នាក់ងារឥណទានបញ្ជូនឯកសារខ្ចីប្រាក់ដែលបានរៀបចំរួចរាល់ហើយនោះ ដើម្បីដាក់ជូនអ្នកគ្រប់គ្រង ដែលមានសិទ្ធិអនុម័តឥណទាន។

**៦-ការរៀបចំកិច្ចសន្យា**

- ភ្នាក់ងារឥណទានត្រូវទទួលខុសត្រូវលើការរៀបចំឯកសារទាំងអស់ ឲ្យបានត្រឹមត្រូវ ច្បាស់លាស់គ្រប់គ្រាន់។
- ភ្នាក់ឥណទានត្រូវរៀបចំកិច្ចសន្យាក្នុងនោះមាន កិច្ចសន្យាខ្ចីប្រាក់ កិច្ចសន្យាដាក់ធានា និងលិខិតស្នាមផ្សេងៗទៀតដែលទាក់ទង។
- បន្ទាប់ពីមានការព្រមព្រៀងហើយអតិថិជន និងអ្នកដែលទាក់ទងទាំងអស់ ត្រូវផ្តិតមេដៃ ឬចុះហត្ថលេខា។ ចំពោះឯកសារដែលត្រូវបញ្ជាក់ពីអាជ្ញាធរអតិថិជនត្រូវសុំបញ្ជាក់ហត្ថលេខា និងបោះត្រា។
- ភ្នាក់ងារឥណទានត្រូវប្រគល់ឯកសារមួយចំនួនទៀតជូនទៅភ្នាក់ងារបម្រើអតិថិជន។
- ក្រោយពីឯកសារត្រូវបានចុះហត្ថលេខាបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានរួចរាល់ អតិថិជនត្រូវកាន់ឯកសារនោះទៅការិយាល័យ ធនាគារ អេស៊ីលីដា ភីអិលស៊ីហើយប្រគល់ទៅឲ្យភ្នាក់បម្រើអតិថិជន។

**៧-ការរៀបចំបញ្ចូលទិន្នន័យ**

- ភ្នាក់ងារបម្រើអតិថិជនក្រោយពីទទួលឯកសារហើយ ត្រូវត្រួតពិនិត្យឯកសារទាំងនោះឲ្យបានត្រឹមត្រូវ។
  - + ពិនិត្យមើលការចុះហត្ថលេខារបស់ ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ និងសុរិយោដីនៅលើឯកសារឲ្យបានត្រឹមត្រូវ។
  - + ករណីបញ្ចេញឥណទានក្នុងប្រព័ន្ធ Globus ត្រូវបានបង្កើត CIF និងបើក Account ជូនអតិថិជន រួចហើយបញ្ជូនឯកសារឲ្យគណនេយ្យករ និងប្រាប់អតិថិជនឲ្យរង់ចាំបើកប្រាក់កម្ចី។
- គណនេយ្យករដែលពាក់ព័ន្ធ ត្រូវត្រួតពិនិត្យលើឯកសារទាំងនោះ៖
  - + ឯកសារទាំងនោះត្រូវតែមានភាពត្រឹមត្រូវ ច្បាស់លាស់ គ្រប់គ្រាន់។
  - + គណនេយ្យករត្រូវបញ្ចូលទិន្នន័យឥណទានទៅក្នុងប្រព័ន្ធ Globus ឬ Clickloans

+ បោះពុម្ពតារាងកាលវិភាគសងប្រាក់ តៀបចំបង្កាន់ដៃតម្កល់ទ្រព្យធានា "ឬប័ណ្ណចំណាយ(Click loan)" និងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធ។
+ គណនេយ្យករបញ្ជូនសំណុំឯកសារអតិថិជនជូនទៅថ្នាក់មានសមត្ថកិច្ចដើម្បីចុះហត្ថលេខា។

**៨-ការបញ្ចេញឥណទាន**

- គ្រប់ឯកសារទាំងអស់ទាក់ទង និងការបញ្ចេញឥណទាន ត្រូវតែរៀបចំឲ្យបានត្រឹមត្រូវមុនពេលបញ្ចេញឥណទាន រួចហើយបញ្ជូនទៅឲ្យបេឡាធិការរៀបចំប្រាក់ដើម្បីបើកជូនអតិថិជន។
- ពេលអតិថិជនមកដល់ការិយាល័យធនាគារ ភ្នាក់ងារបម្រើអតិថិជនត្រូវត្រួតពិនិត្យ និងអញ្ជើញអតិថិជនឲ្យទៅជួបបេឡាធិការដើម្បីបើកប្រាក់។
- មុនពេលបើកប្រាក់ បេឡាធិការត្រូវរំលឹកឡើងវិធីរបៀសងប្រាក់ និងការពិន័យលើការសងយឺតយ៉ាវ និងលក្ខខណ្ឌនៃការប្រគល់ទទួលប្រាក់។
- បេឡាធិការឲ្យអតិថិជនផ្តិតមេដៃលើប័ណ្ណចំណាយប្រាក់ឲ្យខ្ចី ឬប័ណ្ណដកប្រាក់ ហើប្រគល់ប្រាក់ជូនអតិថិជន។

## ៣.២១. លទ្ធផលនៃការបញ្ចេញឥណទាន

### ៣.២១.១. សមតុល្យឥណទានអាជីវកម្មខ្នាតតូចរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខ

តារាងទី៣.៣.សមតុល្យឥណទាន ពីឆ្នាំ២០១៣-២០១៥

| ឆ្នាំ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|
| សមតុល្យឥណទាន(ដុល្លារ) | ១,៣២៩,៨៦៨ | ២,៥២៨,២៩០ | ៣,៤២៦,៣៧០ |
| អត្រាបំរែបំរួល(ដុល្លារ) | - | ១,១៩៨,៤២២ | ២,០៩៦,៥០២ |
| អត្រាបំរែបំរួល(ជា%) | - | ៩០.១២% | ១៥៧.៦៥% |




យោងតាមទិន្នន័យ ដែលទទួលបានពីរបាយការណ៍ឥណទានប្រចាំឆ្នាំ ២១០៣ ដល់ ២០១៥ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខ បានបង្ហាញឲ្យឃើញថា នៅក្នុងឆ្នាំ ២០១៤ សមតុល្យឥណទាន បានកើនឡើងលើសឆ្នាំ ២០១៣ ចំនួន ១,១៩៨,៤២២ ដុល្លារអាមេរិក ដែលស្មើនឹងអត្រា ៩០.១២%។ ដូចគ្នានេះដែរ ឆ្នាំ២០១៥ លទ្ធផលនៃការបញ្ចេញឥណទានខ្នាតតូចប្រចាំឆ្នាំបានកើនឡើងចំនួន ២,០៩៦,៥០២ ដុល្លារអាមេរិក ស្មើនឹង ១៥៧.៦៥% បើធៀបជាមួយឆ្នាំ ២០១៣ ប៉ុន្តែបើធៀបនឹងឆ្នាំ២០១៤ គឺកើនត្រឹមតែ ៨៩៨,០៨០ ដុល្លារអាមេរិក ស្មើនឹង ៣៥.៥២%។ ដូច្នេះបង្ហាញឲ្យឃើញថាលទ្ធផលនៃការបញ្ចេញឥណាទានរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខក្នុងឆ្នាំ ២០១៣ ដល់២០១៥ គឺមានការកើនឡើងជាលំដាប់។

### ៣.២១.២.ចំនួនអតិថិជនប្រើប្រាស់ឥណទានអាជីវកម្មខ្នាតតូច

តារាងទី៣.៤. ចំនួនអតិថិជនប្រើប្រាស់ឥណទានអាជីវកម្មខ្នាតតូចឆ្នាំ ២០១៣-២០១៥

| ឆ្នាំ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|
| ចំនួនអតិថិជន | ១៤៧នាក់ | ២៨៨នាក់ | ៣៣៣នាក់ |
| អត្រាបំរែបំរួលជាចំនួន | - | ១៤១នាក់ | ១៨៦នាក់ |
| អត្រាបំរែបំរួលជា% | - | ៩៥.៩១% | ១២៦.៥៣% |




យោងតាមក្រាហ្វិកខាងលើ បានបង្ហាញឲ្យឃើញថាចំនួនអតិថិជន ដែលបានប្រើប្រាស់ឥណទានអាជីវកម្មខ្នាតតូចរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខក្នុងឆ្នាំ ២០១៤កើនលើសឆ្នាំ២០១៣ ចំនួន១៤១នាក់ ដែលស្មើនឹង៩៥.៩១%។ ចំណែកឯឆ្នាំ២០១៥បាន កើនឡើង១៨៦នាក់ ស្មើនឹង១២៦.៥៣% បើធៀបនឹងឆ្នាំ២០១៣ ប៉ុន្តែបើធៀបនឹងឆ្នាំ២០១៤ គឺកើនត្រឹមតែ៤៥នាក់ ដែលស្មើនឹង១៥.៦២%តែប៉ុណ្ណោះ។ នេះអាចបញ្ជាក់បានថាធនាគារ បានបម្រើសេវាកម្មបានល្អ មានភាពជឿជាក់ និងមានគោលនយោបាយត្រឹមត្រូវក្នុងការបញ្ចេញឥណទាន ទើបធ្វើឲ្យមានកំនើនអតិថិជនដូច្នេះ។

### ៣.២១.៣. អត្រាហានិភ័យឥណទាន ឆ្នាំ២០១៣-២០១៥

តារាងទី៣.៥.អត្រាហានិភ័យឥណទាន (PAR)

| ឆ្នាំ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|
| សមតុល្យឥណទានខកខានមិនបាសង(ដុល្លារ) | 0 | 0 | ៣៤២.៦៣៧ |
| សមតុល្យឥណទានសរុប(ដុល្លារ) | ១,៣២៩,៨៦៨ | ២,៥២៨,២៩០ | ៣,៤២៦,៣៧០ |
| អត្រាហានិភ័យឥណទាន | 0% | 0% | 0.0១% |



តាមរយៈតារាងខាងលើ បានបង្ហាញឲ្យឃើញថា អត្រាហានិភ័យឥណទានខ្ចាតតូចរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខក្នុងឆ្នាំ២០១៣ និងឆ្នាំ២០១៤ ពុំមានសោះឡើយ គឺមានន័យថាអត្រាឥណទានដែលខកខានមិនបានសងគឺស្មើនឹងសូន្យ។ ប៉ុន្តែក្នុងឆ្នាំ២០១៥ គឺមានត្រឹមតែ ០.០១%តែបុណ្ណោះ។ ដោយសារតែអត្រាហានិភ័យឥណទានមានតិចតួចបែបនេះអាចបញ្ជាក់បានថាធនាគារមានគោលការណ៍ត្រឹមត្រូវក្នុងការអនុវត្តការគ្រប់គ្រងហានិភ័យឥណទានបានយ៉ាងល្អ។

សរុបសេចក្តីមក តាមរយៈការវិភាគទិន្នន័យខាងលើនេះ អាចសន្និដ្ឋានបានថាការកើនឡើងនូវតម្រូវការឥណទានរបស់អតិថិជន រួមជាមួយនឹងកម្រិតនៃអត្រាហានិភ័យឥនទានស្មើតែពុំមានបែបនេះបានធ្វើឲ្យប្រតិបត្តិការអាជីវកម្មរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខមានភាពល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ។ ទាំងនេះដោយសារតែធនាគារបានបង្កើតនូវគោលការណ៍ និងនីតិវិធិក្នុងការផ្តល់ឥណទានដែលមានលក្ខណៈច្បាស់លាស់ ត្រឹមត្រូវ និងធ្វើឲ្យការអនុវត្តឥណទានទទួលបានប្រសិទ្ធភាពខ្ពស់។

### ៣.២២.ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

តាមរយៈការសិក្សាកន្លងមក យើងសង្កេតឃើញថា ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខមានចំណុចខ្លាំង និងចណុចខ្សោយដូចខាងក្រោមៈ

❖ **ចំណុចខ្លាំង**

- ធនាគារបានបង្កើតនូវគោលការណ៍ និងនីតិវិធីក្នុងការផ្តល់ឥណទានដែលមានលក្ខណៈច្បាស់លាស់ ត្រឹមត្រូវ និងការអនុវត្តឥណទានមានប្រសិទ្ធភាពខ្ពស់។
- ការពង្រឹងសមត្ថភាពបុគ្គលិកជំនាញ ធ្វើឲ្យបុគ្គលិកមានចំណេះដឹង ជំនាញនិងប្រសិទ្ធភាពខ្ពស់ប្រកបដោយវិជ្ជាជីវៈ។
- ការបម្រើសេវារហ័សទាន់ចិត្ត។
- មន្ត្រីឥណទានធ្វើការវាយតម្លៃឥណទាន និងទ្រព្យធានាបានត្រឹមត្រូវ និងច្បាស់លាស់។
- ប្រើប្រាស់ប្រព័ន្ធបច្ចេកទេសខ្ពស់ក្នុងការគ្រប់គ្រងទិន្នន័យ។
- មានផលិតផលឥណទានច្រើនប្រភេទសម្រាប់បម្រើជូនអតិថិជន។
- គ្មានការពិន័យ ក្នុងករណីអតិថិជនបង់ផ្តាច់។
- ផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការផ្តល់ឥណទាន។
- ដោះស្រាយបញ្ហា ខកខានមិនបានសងទាន់ពេលវេលា កាត់បន្ថយហានិភ័យឥណទាន។

- មានសាខាច្រើន
- មាននាយកដ្ឋាន ហ្វឹកហ្វឺន និងបណ្តុះបណ្តាលបន្ថែមទៀតលើនិស្សិតចុះកម្មសិក្សា និងបុគ្គលិកចូលថ្មីដើម្បីឲ្យពួកគេមានសមត្ថគ្រប់គ្រាន់ក្នុងការអនុវត្តការងារជាក់ស្តែង។
- បុគ្គលិកមានភាពរួសរាយរាក់ទាក់ មានក្រមសីលធម៌ល្អក្នុងការបំពេញការងារ និងប្រកបដោយវិជ្ជាជីវៈលើជំនាញរបស់ខ្លួន ព្រមទាំងមានការទទួលខុសត្រូវខ្ពស់លើមុខងារ និងតួទានីរៀងៗខ្លួន។

❖ **ចំណុចខ្សោយ**

- ការបញ្ចេញឥណទានជាប្រាក់ដុល្លារអាមេរិក ច្រើនជាងលុយរៀលខ្មែរដែលជាផ្នែកមួយធ្វើឲ្យប្រាក់រៀលខ្មែរពុំសូវមានចលនាលើទីផ្សារ។
- ធនាគារតម្រូវឲ្យអតិថិជនចេញសោហ៊ុយឥណទាន១%នៃបរិមាណឥណទានខ្នាតតូចដែលមានទំហំចាប់ពី១០,០០០ដុល្លារអាមេរិក ឬសមមូលឡើងទៅដែលធ្វើឲ្យអតិថិជនមិនសូវមានការពេញចិត្ត។
- ឯកសារទាក់ទងនឹងប្រភពចំណូល និងចំណាយរបស់អតិថិជនដែលមន្ត្រីឥណទានប្រមូលមិនទានមានលក្ខណៈច្បាស់លាស់។
- ធនាគារ គិតអត្រាការប្រាក់ខ្ពស់បើធៀបជាមួយធនាគារមួយចំនួន។

# សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

បន្ទាប់ពីការចុះកម្មសិក្សា និងស្រាវជ្រាវដោយយកចិត្តទុកដាក់កន្លងមកនៅធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខលើប្រធានទប "ដំណើរការនៃការផ្តល់ឥណទានខ្នាតតូច" ខ្ញុំអាចសន្និដ្ឋានបានថា គោលការណ៍ និងនីតិវិធីនៃការផ្តល់ឥណទានរបស់ធនាគារមានលក្ខណៈច្បាស់លាស់ និង អនុវត្តន៍បានល្អប្រសើរបង្កឲ្យធនាគារ និងអតិថិជនផ្ទាល់មានភាពពេញចិត្ត ទទួលយកបាន និងមានការគាំទ្រជាច្រើន។ ហើយការរៀបចំរចនាសម្ព័ន្ធបានត្រឹមត្រូវ និងទៅតាមតួនាទីបានល្អធ្វើឲ្យការផ្តល់ឥណទានប្រព្រឹត្តិទៅយ៉ាងរលូន និងមានប្រសិទ្ធភាពបំផុត។ បុគ្គលិករបស់ធនាគារគ្រប់ផ្នែកមានចំណេះជំនាញច្បាស់លាស់ក្នុងការអនុវត្តការងារ និងធ្វើការទៅតាមគោលដៅដែលធនាគារបានកំណត់បានយ៉ាងល្អ។ លើសពីនេះទៅទៀតធនាគារបានបង្កើនការយល់ដឹង និងពង្រឹងសមត្ថភាព ជំនាញដល់បុគ្គលិកឥណទាន តាមរយៈការផ្តល់ការហ្វឹកហ្វឺន និងធ្វការអប់រំវិជ្ជាជីវៈ វិន័យ សីលធម៌សង្គម ដើម្បីឲ្យបុគ្គលិកមានភាពស្អាតស្អំ និងសុចរិតភាព។

យោងតាមទិន្នន័យដែលទទួលបានពីធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខស្តីពីលទ្ធផលនៃការបញ្ចេញឥណទានខ្នាតតូច យើងឃើញថាការបញ្ចេញឥណទានមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ តាមទិន្នន័យបង្ហាញថាការបញ្ចេញឥណទានខ្នាតតូចនៅឆ្នាំ២០១៣ មានត្រឹមតែ ១,៣២៩,៨៦៨ ដុល្លារអាមេរិកប៉ុណ្ណោះ ប៉ុន្តែនៅឆ្នាំ២០១៤ បានកើនឡើងរហូតដល់ ២,៥២៨,២៩០ ដុល្លារអាមេរិក និងឆ្នាំ២០១៥ កើនរហូតដល់ ៣,៩២៦,៣៧០ ដុល្លារអាមេរិក។ ដូចនេះ យើងអាចសន្និដ្ឋានបានថាដំណើរការនៃការផ្តល់ឥណទានខ្នាតតូចរបស់ធនាគារ អេស៊ីលីដា សាខាវិមានចតុមុខ មានភាពល្អប្រសើរ ប្រកបដោយប្រសិទ្ធភាព និងទទួលបាននូវភាពជោគជ័យ។

## ២.ការផ្តល់អនុសាសន៍

តាមរយៈការចុះកម្មសិក្សានៅធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខ អំពីប្រធានបទឥណទានខ្នាតតូច រួចមកខ្ញុំសង្កេតឃើញថា ធនាគារទទួលបានភាពជោគជ័យនៅក្នុងប្រតិបត្តិការនេះក៏ប៉ុន្តែនៅមានចំណុចខ្វះខាតមួយចំនួនដែលធនាគារគួរត្រិះរិះពិចារណាក្នុងការកែលម្អ និង បំពេញបន្ថែម។ ដូច្នេះខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួនដល់ធនាគារ ដើម្បីឲ្យការផ្តល់ឥណទានមានលក្ខណៈកាន់តែប្រសើរឡើងគឺ៖

- បង្កើនប្រព័ន្ធផ្សព្វផ្សាយអំពីឥណទាននីមួយៗឲ្យបានធំទូលាយជាងមុនទៅដល់ប្រជាជន ដើម្បីឲ្យពួកគាត់យល់កាន់តែច្បាស់លាស់ និងងាកមកប្រើផលិតផលឥណទានរបស់ធនាគារ អេស៊ីលីដា បន្ថែមទៀត។
- បង្កើតផលិតផលឥណទានថ្មីៗ បន្ថែមទៀតដើម្បីឲ្យអតិថិជនមានជំរើសកាន់តែច្រើន។
- កាត់បន្ថយអត្រាការប្រាក់ឲ្យនៅកំរិតមួយទាបតាមដែលអាចធ្វើទៅបាន។
- កាត់បន្ថយចំណាយសោហ៊ុយឥណទាន និងចំណាយលើការរៀបចំឯកសារមួយចំនួនដើម្បីទាក់ទាញអតិថិជនឲ្យប្រើប្រាស់សេវាឥណទានរបស់ធនាគារកាន់តែច្រើន។
- ជំរុញ និងលើកទឹកចិត្តអតិថិជនឲ្យប្រើប្រាស់ឥណទានជាប្រាក់រៀលខ្មែរឲ្យបានច្រើនដើម្បីជួយលើកកម្ពស់ប្រាក់រៀលខ្មែរឲ្យកាន់តែមានតម្លៃ។
- រឹតបណ្តឹងមន្ត្រីឥណទានដែលចុះប្រមូលឯកសារចំណូលចំណាយរបស់អតិថិជន។
- កាត់បន្ថយឯកសារស្នើសុំឥណទានមួយចំនួន តាមដែលអាចធ្វើទៅបាន ដើម្បីឲ្យអតិថិជន ក៏ដូចជាមន្ត្រីឥណទានមានភាពងាយស្រួល និងចំណាយពេលតិច។
- បន្ថែមរយៈពេលខ្ចី ឲ្យមានរយៈពេលវែងជាងពេលបច្ចុប្បន្ន ដើម្បីឲ្យអតិថិជនមានពេលវេលាគ្រប់គ្រាន់ក្នុងការសងត្រលប់មកវិញ។

តាមរយៈការផ្តល់អនុសាសន៍ខាងលើនេះ ខ្ញុំសង្ឃឹមថាធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាវិមានចតុមុខនឹងទទួលយកបានដោយក្តីអនុគ្រោះ និងសូមជូនពរឲ្យធនាគារកាន់តែទទួលបានភាពរីកចម្រើនជានិច្ចនិរន្តរ៍។

# ឯកសារយោង

## ❖ ឯកសារយោងជាភាសាខ្មែរ


- សូន ចំរើន,(២០១៣),រូបិយវត្ថុ និងធនាគារ
- សូន ចំរើន,(២០១៧),ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ
- ឈាង ហ៊ុយ,(២០១៧),លំនាំដើមឥណទាន
- ជា គឹមឡេង,(២០១៦),រូបិយវត្ថុ និងធនាគារ
- ធនាគារអេស៊ីលីដា ភីអិលស៊ី(២០១៦),គោលការណ៍ប្រតិបត្តិការឥណទានខ្នាតតូច
- ធនាគារអេស៊ីលីដា ភីអិលស៊ី(២០១៦),គោលការណ៍ណែនាំ ស្តីពីប្រព័ន្ធនៃការត្រួតពិនិត្យគុណភាពឥណទាន
- ធនាគារអេស៊ីលីដា ភីអិលស៊ី(២០១៣),ប្រវត្តិអេស៊ីលីដា
- ធនាគារជាតិនៃកម្ពុជា,(១៩៩៩),ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ


## ❖ ឯកសារយោងជាភាសាអង់គ្លេស


- Rose, P. ( 1990 ). Commercial Bank Management.
- Robert Cole & Lon Mishler, 1998, ‶Credit Management″, Eleventh Edition
- https://km.wikipedia.org/wiki/ធនាគារកណ្តាល
- www.acledabank.com.kh, 01 may ,2019